សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

*Royal University of Law and Economics*

# សារណាបញ្ចប់ការសិក្សា

# ប្រៀបធៀបប្រភេទទោសព្រហ្មទណ្ឌ

## ឆ្នាំ ១៩០៩ និងឆ្នាំ ២០០៩

ស្រាវជ្រាវ ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៤ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៤

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ភេង ថិរៈ**

**ក.ហុង ស្រីពេជ្រ**

សាស្ត្រាចារ្យណែនាំ

លោក **ជួន ម៉ុនធី**

ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ

ជំនាន់ទី ១៤

ឆ្នាំចូលសិក្សា ២០១០

ឆ្នាំសរសេរសារណា ២០១៤

# មាតិកា

ទំព័រ

**សេចក្ដីផ្ដើម** ............................................................ ០១
**ជំពូកទី ១ ប្រភេទទោសឆ្នាំ ១៩០៩**
**១.១.ឧក្រិដ្ឋទោស** ............................................................ ០៦
**១.១.១. និយមន័យនៃឧក្រិដ្ឋទោស** ............................................................ ០៦
**១.១.២. សណ្ឋាននៃឧក្រិដ្ឋទោស** ............................................................ ០៦
១.១.២.១.ការពិឃាតជីវិតបង់ ............................................................ ០៧
១.១.២.២.ការដាក់គុកបង្ខំឱ្យធ្វើការជាទម្ងន់អស់មួយជីវិត ............................................................ ០៨
១.១.២.៣.ការធ្វើទោសបញ្ជជយ្យំ(ការបំបរបង់) ............................................................ ០៨
១.១.២.៤.ការដាក់គុកឱ្យធ្វើការជាទម្ងន់មានកំណត់ ............................................................ ០៩
១.១.២.៥.ការដាក់គុកទុកពី ៥(ប្រាំ) ឆ្នាំ ទៅដល់ ២០(ម្ភៃ) ឆ្នាំ ឱ្យនៅដោយពួកមិនឱ្យច្រឡំនឹងគ្នា ............................................................ ០៩
១.១.២.៦.ការដាក់គុកឱ្យនៅកន្លែងស្ងាត់តែម្នាក់ឯងពី ៥ (ប្រាំ) ឆ្នាំ ទៅដល់ ១០(ដប់)ឆ្នាំ ១០
១.១.២.៧.ការធ្វើទានិរទេសមានកំណត់ ............................................................ ១១
១.១.២.៨.ការបន្ថយយសស័ក្តិ ............................................................ ១១
**១.២.មជ្ឈិមទោស** ............................................................ ១៣
**១.២.១. និយមន័យនៃមជ្ឈិមទោស** ............................................................ ១៣
**១.២.២. សណ្ឋាននៃមជ្ឈិមទោស** ............................................................ ១៣
១.២.២.១.ការដាក់គុក ............................................................ ១៤
១.២.២.២.បញ្ញត្តិហាមមិនឱ្យមានអំណាចខ្លះពីយសស័ក្តិ ............................................................ ១៤
១.២.២.៣.ការពិន័យ ............................................................ ១៤
**១.៣.លហុទោស** ............................................................ ១៥
**១.៣.១. និយមន័យនៃលហុទោស** ............................................................ ១៥
**១.៣.២. សណ្ឋាននៃលហុទោស** ............................................................ ១៦
១.៣.២.១.ទោសសណ្ឋានទី១ ............................................................ ១៦
១.៣.២.២.ទោសសណ្ឋានទី២ ............................................................ ១៦
១.៣.២.៣.ទោសសណ្ឋានទី៣ ............................................................ ១៧
**ជំពូកទី ២. ប្រភេទទោសឆ្នាំ ២០០៩**
**២.១.មូលទោស** ............................................................ ២០
**២.១.១. និយមន័យនៃមូលទោស** ............................................................ ២០
**២.១.២. ប្រភេទនៃមូលទោស** ............................................................ ២០

២.១.២.១. ទោសដាក់ពន្ធនាគារ ........................................................................ ២១
២.១.២.២. ទោសពិន័យជាប្រាក់ ........................................................................ ២២
**២.២.ទោសបន្ថែម** ........................................................................ ២៤
**២.២.១. និយមន័យនៃទោសបន្ថែម** ........................................................................ ២៥
**២.២.២. ប្រភេទទាំង ១៩ នៃទោសបន្ថែម** ........................................................................ ២៥
២.២.២.១. ការដក់សិទ្ធិខ្លះជាពលរដ្ឋ ........................................................................ ២៥
២.២.២.២.ការហាមឃាតចំពោះការប្រកបវិជ្ជាជីវៈណាមួយ ដែលបទល្មើសនេះបានប្រព្រឹត្ត នៅក្នុងពេលដែលប្រកបវិជ្ជាជីវៈនេះ ........................................................................ ២៦
២.២.២.៣.ការហាមឃាត់ចំពោះការបើកបរយានយន្តគ្រប់ប្រភេទ ........................................................................ ២៦
២.២.២.៤.ការព្យួរលិខិតបើកបរ ........................................................................ ២៦
២.២.២.៥.ការហាមឃាត់ចំពោះការស្នាក់នៅទីកន្លែងមួយចំនួននៃព្រះរាជាណាចក្រ កម្ពុជា ........................................................................ ២៧
២.២.២.៦.ការហាមឃាត់ចំពោះការចាក់ចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា ....... ២៧
២.២.២.៧.ការហាមឃាត់ចំពោះការចូល និង ការស្នាក់នៅលើដែនដីនៃព្រះរាជាណាចក្រ កម្ពុជា ........................................................................ ២៨
២.២.២.៨.ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុដែលប្រើប្រាស់ក្នុងពេលប្រព្រឹត្តបទល្មើស ឬ ដែលទុកសម្រាប់ប្រព្រឹត្តបទល្មើស ........................................................................ ២៨
២.២.២.៩.ការរឹបអូសវត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស ........................................................................ ២៩
២.២.២.១០.ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ....... ២៩
២.២.២.១១.ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬចលនវត្ថុដែលលំអរទីកន្លែងប្រព្រឹត្តបទ ល្មើសត្រូវបានប្រព្រឹត្ត ........................................................................ ២៩
២.២.២.១២.ការរឹបអូសយានជំនិះដែលជារបស់ទណ្ឌិត ........................................................................ ៣០
២.២.២.១៣.ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និង គ្រាប់រំសេវគ្រប់ប្រភេទ ........................................................................ ៣០
២.២.២.១៤.ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ ........................................................................ ៣១
២.២.២.១៥.ការបិទគ្រឹះស្ថានដែលប្រើប្រាស់ដើម្បីត្រៀម ឬប្រព្រឹត្តបទល្មើស ............ ៣២
២.២.២.១៦.ការហាមឃាត់ចំពោះការធ្វើអាជីវកម្មនៅក្នុងគ្រឹះស្ថានដែលបើកចំហសម្រាប់ សាធារណៈជន ឬដែលប្រើប្រាស់ដោយសាធារណៈជន ........................................................................ ៣៣
២.២.២.១៧.ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស ........................................................................ ៣៣
២.២.២.១៨.ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារពត៌មានសរសេរ ........... ៣៤
២.២.២.១៩.ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសតាមគ្រប់មធ្យោបាយ ........................................................................ ៣៥

**២.៣.ទោសជំនួស** ........ ៣៥
**២.៣.១. និយមន័យនៃទោសជំនួស** ........ ៣៥
**២.៣.២. ប្រភេទនៃទោសជំនួស** ........ ៣៦
២.៣.២.១. ទោសការងារសហគមន៍ ........ ៣៦
ក.និយមន័យនៃការងារសហគមន៍ ........ ៣៦
ខ.របបគតិយុត្តិនៃការងារសហគមន៍ ........ ៣៧
គ.អ្នកមិនទទួលផលប្រយោជន៍នៃការងារសហគមន៍ ........ ៣៨
ឃ.គោលការណ៍ជួសជុលការខូចខាតដល់អ្នកដទៃ ........ ៣៨
២.៣.២.២. ទោសស្តីបន្ទោស ........ ៣៩
ក.អត្ថន័យនៃទោសស្តីបន្ទោស ........ ៣៩
ខ.របបគតិយុត្តិនៃការស្តីបន្ទោស ........ ៣៩
**ជំពូកទី ៣ ការប្រៀបធៀបប្រភេទទោស**
**៣.១.ចំនុចដូចគ្នានៃប្រភេទទោស** ........ ៤១
**៣.១.១. រូបភាពនៃប្រភេទទោស** ........ ៤១
៣.១.១.១. រូបភាពជាមូលទោសក្នុងក្រមចាស់ ........ ៤២
៣.១.១.២. រូបភាពជាទោសបន្ថែមក្នុងក្រមចាស់ ........ ៤២
ក.ការដកសិទ្ធិខ្លះជាពលរដ្ឋ ........ ៤២
ខ.ការហាមឃាត់ចំពោះការស្នាក់នៅ ........ ៤៤
គ.ការហាមឃាត់ចំពោះការចូល និងការស្នាក់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជាចំពោះទណ្ឌិតដែលជាជនបរទេស ........ ៤៥
ឃ.ការរឹបអូស ........ ៤៦
ង.ការបិទផ្សាយសេចក្តីសម្រេច ........ ៤៧
**៣.១.២. ទម្ងន់នៃប្រភេទទោស** ........ ៤៨
៣.១.២.១. ទម្ងន់នៃទោសឧក្រិដ្ឋ ........ ៤៨
៣.១.២.២. ទម្ងន់នៃទោសមជ្ឈិម ........ ៤៩
៣.១.២.៣. ទម្ងន់នៃទោសលហុ ........ ៤៩
**៣.១.៣. របៀបសម្គាល់នូវប្រភេទនៃទោសចំពោះបទល្មើស** ........ ៥០
៣.១.៣.១. លក្ខណៈសម្គាល់នៃទោសឧក្រិដ្ឋ ........ ៥១
៣.១.៣.២. លក្ខណៈសម្គាល់នៃទោសមជ្ឈិម ........ ៥២
៣.១.៣.៣. លក្ខណៈសម្គាល់នៃទោសលហុ ........ ៥៣
**៣.១.៤. បុគ្គលដែលត្រូវទទួលរងនូវប្រភេទទោស** ........ ៥៥
៣.១.៤.១. អ្នកប្រព្រឹត្តដោយផ្ទាល់ ........ ៥៥
៣.១.៤.២. អ្នកប្រព្រឹត្តដោយប្រយោល ........ ៥៦

**៣.២.ចំនុចខុសគ្នានៃប្រភេទទោស** ........ ៥៨
**៣.២.១. ការកំណត់ឈ្មោះ និងការបង្កើតថ្មីនៃប្រភេទទោស** ........ ៥៨
៣.២.១.១. ការកំណត់ឈ្មោះនៃប្រភេទទោស ........ ៥៩
ក.មូលទោស ........ ៥៩
ខ.ទោសបន្ថែម ........ ៥៩
៣.២.១.២. ការបង្កើតថ្មីនៃប្រភេទទោស ........ ៦០
**៣.២.២. សណ្ឋាននៃប្រភេទទោសដែលលុបចេញពីក្រមចាស់** ........ ៦០
៣.២.២.១. ទោសប្រហារជីវិត ........ ៦១
៣.២.២.២. សណ្ឋាននៃទោសដាក់ពន្ធនាគារ ........ ៦១
**៣.២.៣.បុគ្គលដែលត្រូវទទួលខុសត្រូវប្រភេទទោសជានីតិបុគ្គល** ........ ៦២
៣.២.៣.១. មូលទោសក្នុងប្រភេទជាទោសពិន័យ ........ ៦២
៣.២.៣.២. ទោសបន្ថែមទាំង ១៤ ចំនុច ........ ៦៣
**៣.២.៤.អាជ្ញាយុកាលនៃប្រភេទទោស** ........ ៦៥
**សេចក្តីសន្និដ្ឋាន** ........ ៦៧
**អនុសាសន៍** ........ ៧១
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# អារម្ភកថា

រយៈពេលបួនឆ្នាំ នៅក្នុងការសិក្សាក្នុងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បានកន្លងផុតទៅយ៉ាងឆាប់រហ័ស ។ នៅពេលជាមួយគ្នានេះដែរ ការសិក្សាក៏បានឱ្យនិស្សិតគ្រប់រូបទទួលបាននូវចំណេះដឹងថ្មីជាច្រើន ក្រោមការបង្ហាត់បង្រៀនយ៉ាងយកចិត្តទុកដាក់ពីសំណាក់លោកសាស្ត្រាចារ្យទាំងឡាយ ដែលបានចំណាយពេលវេលាដ៏មានដំលៃរបស់លោកបានជួយបណ្តុះបណ្តាលធនធានមនុស្ស ដើម្បីជំរុញការអភិវឌ្ឍប្រទេសជាតិឱ្យឈានទៅទៅរកវឌ្ឍនភាព និងភាពសម្បូររុងរឿងដូចបណ្តាប្រទេសនានានៅលើពិភពលោក ។

ដើម្បីឆ្លើយតបទៅនឹងការខិតខំប្រឹងប្រែងរបស់សាស្ត្រាចារ្យ ក៏ដូចជាការបំពេញតំរូវការដ៏ចាំបាច់របស់សាកលវិទ្យាល័យ ដែលតំរូវឱ្យនិស្សិតដែលទទួលបានចំណាត់ថ្នាក់តាមការកំណត់របស់សាកលវិទ្យាល័យ ត្រូវរៀបចំជាសារណា ឬរបាយការណ៍ នៅពេលបញ្ចប់ការសិក្សា និងដើម្បីទុកជាស្នាដៃក៏ដូចជាឯកសារសម្រាប់ប្អូន និស្សិតជំនាន់ក្រោយបានធ្វើការស្រាវជ្រាវបន្ថែម ព្រមទាំងធ្វើយ៉ាងណាមិនឱ្យការសិក្សារយៈពេលបួនឆ្នាំកន្លងទៅដោយឥតប្រយោជន៍ផងនោះ យើងខ្ញុំបានខិតខំប្រឹងប្រែងឱ្យអស់ពីលទ្ធភាព សមត្ថភាព និងចំណេះដឹងដែលបានទទួលកន្លងមក គួបផ្សំនឹងការពិភាគ្សា ក៏ដូចជាសុំយោបល់ពីសាស្ត្រាចារ្យមួយចំនួនចុងក្រោយក៏បានសម្រេចនូវរូបរាងសារណានេះឡើង ។

ទោះបីជាយើងខ្ញុំទាំងពីរនាក់ខិតខំស្វែងរកនូវឯកសារដ៏សំខាន់ជាច្រើន ដែលទាក់ទងនឹងប្រធានបទនេះមកសរសេររៀបរៀងជាសារណានេះក៏ដោយ ក៏យើងខ្ញុំទាំងពីរនាក់គិតថាសារណានេះនៅមានចំនុចខ្វះចន្លោះជាពិសេសទៅលើអក្ខរាវិរុទ្ធ និងខ្លឹមសារពុំទាន់បានស៊ីជម្រៅ និងបានត្រឹមត្រូវមួយរយភាគរយនោះទេ ។

យើងមានសេចក្តីរីករាយយ៉ាងខ្លាំង ប្រសិនបើនិស្សិត លោកសាស្ត្រាចារ្យ និងមិត្តអ្នកអានទាំងអស់ ចូលរួមកែតម្រូវរាល់កំហុសខុសឆ្គងទាំងឡាយដែលកើតឡើងដោយអចេតនាក្នុងន័យស្ថាបនា ដើម្បីបំពេញអត្ថន័យអោយកាន់តែស៊ីជម្រៅថែមទៀត។

លើសពីនេះទៅទៀតយើងខ្ញុំទាំងពីរនាក់សង្ឃឹមថាសារណានេះ នឹងក្លាយជាវិភាគទានដ៏សំខាន់ដល់មិត្តអ្នកអានដែលកំពុងសិក្សាតាមគ្រឹះស្ថានឧត្តមសិក្សា និងស្ថាប័ននានាទូទាំងព្រះរាជាណាចក្រកម្ពុជា ។

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំទាំងពីរនាក់ ឈ្មោះ កេង វិរៈ និង កញ្ញា ហុង ស្រីពេជ្រ ជានិស្សិតថ្នាក់ បរិញ្ញាបត្រនីតិសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា២០១៣-២០១៤។

## សូមថ្លែងអំណរគុណ

ចំពោះ **មាតា បិតា** ដែលបានផ្តល់កំណើតសំរាប់ការរស់នៅ និងការសិក្សារបស់កូនរហូតទទួលបានការបញ្ចប់ការសិក្សា ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រដោយជោគជ័យ ។ គុណូបការៈរបស់លោកទាំងពីរមានទំហំធំធេងឥតមានរកអ្វីប្រៀបផ្ទឹមពុំបានឡើយ ។ មិនតែប៉ុណ្ណោះព្រហ្មវិហារធម៌របស់លោកទាំងពីរធ្វើឱ្យកូនចងចាំជានិច្ចមិនអាចភ្លេចបានឡើយ ។

ចំពោះឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង និងលោក លោកស្រីទាំងអស់ដែលជាសាស្ត្រាចារ្យបម្រើការងារ នៅក្នុងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលបានលះបង់ពេលវេលាព្រមទាំងកំលាំងកាយចិត្ត ដើម្បីបង្ហាត់បង្រៀនដល់យើងខ្ញុំទាំងពីរនាក់អស់រយៈពេល បួនឆ្នាំ ដើម្បីឱ្យយើងខ្ញុំទាំងពីរនាក់មានសមត្ថភាពយល់ដឹងផ្នែកនីតិសាស្ត្រ លើបញ្ហានានាដែលពាក់ព័ន្ធទៅនឹងច្បាប់នៅក្នុងប្រទេសព្រមទាំងច្បាប់អន្តរជាតិថែមទៀត ។

ចំពោះលោកសាស្ត្រាចារ្យ **ជួន ម៉ុនធី** ជាសាស្ត្រាចារ្យដឹកនាំក្នុងការសរសេរសារណានេះដែលបានខិតខំចំណាយពេលវេលាដ៏មានតម្លៃ ជួយពន្យល់ណែនាំដល់យើងខ្ញុំទាំងពីរនាក់ក្នុងការសរសេរសារណានេះរហូតបានទទួលជោគជ័យ ។

យើងខ្ញុំទាំងពីរនាក់សូមថ្លែងអំណរគុណ និងសូមបួងសួងដល់វត្ថុសក្តិសិទ្ធក្នុងលោកសូមជួយថែរក្សាដល់លោកទាំងអស់ឱ្យជួបតែពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លាងឃ្លាតឡើយ ព្រមទាំងឧទ្ទិសដល់ទេវតាឥន្ទព្រហ្មជួយឱ្យប្រទេសជាតិរបស់យើងទាំងអស់គ្នាជួបតែសន្តិភាព និងការអភិវឌ្ឍរីកចំរើនឈ្មោះទៅមុខជានិច្ច និងចាក់ឆ្ងាយពីសត្រូវឈ្លានពានដែលមានចេតនាទុច្ចរិតចង់បង្ករភាពវឹកវរដល់ភាពសុខក្សេមក្សាន្តរបស់ប្រជាពលរដ្ឋ ក៏ដូចជាអធិបតេយ្យភាពរបស់ប្រទេសកម្ពុជាយើងផងដែរ ។

# សេចក្តីផ្តើម

## ១.លំនាំបញ្ហានៃការស្រាវជ្រាវ

តាំងពីសម័យបុរាណកាលរហូតដល់បច្ចុប្បន្នកាលនេះ សង្គមនីមួយៗតែងតែមានការផ្លាស់ប្តូរ មិនថានៅក្នុងសង្គមដែលមានការរីកចំរើន ឬសង្គមដែលមានការអភិវឌ្ឍតិចតួចនោះទេ គ្រាន់តែខុសគ្នាត្រង់ថា សង្គមខ្លះមានការប្រែប្រួលច្រើន និងសង្គមខ្លះមានការប្រែប្រួលតិចតែប៉ុណ្ណោះ។ ទន្ទឹមនឹងការរីកចំរើន ក៏ដូចជាការប្រែប្រួលនៃសង្គមនីមួយៗ វិធានច្បាប់ដែលត្រូវបានបង្កើតឡើងដើម្បីគ្រប់គ្រងទៅលើសង្គមនោះ ក៏មានការប្រែប្រួលទៅតាមការប្រែប្រួលនៃសង្គមផងដែរ ។

បើយើងធ្វើការពិនិត្យមើលទៅលើប្រទេសកម្ពុជាយើងវិញ មុននឹងឈានមកដល់បច្ចុប្បន្នកាលនេះ ប្រទេសកម្ពុជាមានការប្រែប្រួលជាច្រើន ។ ការប្រែប្រួលនេះ គឺប្រទេសកម្ពុជាបានឆ្លងកាត់នូវរបបនយោបាយនៃការគ្រប់គ្រងប្រទេសជាច្រើនសម័យកាល ហើយវិធានច្បាប់សម្រាប់គ្រប់គ្រងប្រទេសនាសម័យនោះ ក៏ត្រូវបានបង្កើតឡើងឱ្យស្របទៅនឹងស្ថានភាពសង្គមនាពេលនោះផងដែរ ។ វិធានច្បាប់នេះ គឺសំដៅទៅលើបណ្តាច្បាប់ទាំងឡាយដែលគ្រប់គ្រងទៅលើវិស័យជាច្រើនផ្សេងៗគ្នានៅក្នុងប្រទេស នៅក្នុងនោះមានវិធានច្បាប់ដែលទាក់ទងទៅនឹងការគ្រប់គ្រងទៅលើបទល្មើសដែលកើតមាននៅក្នុងសង្គមនីមួយៗ គឺវិធានច្បាប់ព្រហ្មទណ្ឌ ។

វិធានច្បាប់ព្រហ្មទណ្ឌ គឺជាវិធានដ៏សំខាន់បំផុតសម្រាប់គ្រប់គ្រងរាល់ទំនាក់ទំនងនៅក្នុងសង្គមឱ្យចាក់ឆ្ងាយពីបទល្មើសដែលតែងតែបង្ករភាពអសកម្មជាច្រើន ក៏ដូចជាបង្ករការប៉ះពាល់ដល់សណ្តាប់ធ្នាបសាធារណៈផងដែរ ។ នៅក្នុងវិធានច្បាប់ព្រហ្មទណ្ឌ មានផ្ទុកទៅនូវបណ្តាច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិផ្សេងទៀតជាច្រើន ដែលត្រូវបានបង្កើតឡើងក្នុងគោលបំណងដើម្បីគ្រប់គ្រងទៅលើបទល្មើស ហើយច្បាប់ទាំងអស់នោះត្រូវបានតាក់តែងដោយអាស្រ័យទៅតាមប្រភេទនៃបទល្មើស ក៏ដូចជាអាស្រ័យទៅតាមវិស័យផ្សេងៗគ្នា ប៉ុន្តែក្រមព្រហ្មទណ្ឌ គឺជាច្បាប់មួយដែលមានកំណត់អំពីបទល្មើសច្រើនជាងច្បាប់ដ៏ទៃទៀត ។

បើយើងពិនិត្យទៅលើក្រមព្រហ្មទណ្ឌ វាមានចំនួនច្រើនបើចាប់រាប់ពីសម័យមុនមកដល់បច្ចុប្បន្ននេះ ពីព្រោះតែវាក៏ត្រូវបានផ្លាស់ប្តូរទៅតាមសម័យកាលនោះដែរ ហេតុនេះហើយប្រសិនបើយើងចង់ធ្វើការសិក្សាទៅលើក្រមព្រហ្មទណ្ឌនៅក្នុងសម័យកាលនីមួយៗ យើងត្រូវស្រាវជ្រាវទៅលើក្រមព្រហ្មទណ្ឌទាំងអស់។ ការសិក្សាទៅលើក្រមនេះ ដើម្បីឱ្យកាន់តែច្បាស់លាស់ និងស៊ីជម្រៅថែមទៀតនោះ យើងត្រូវយកក្រមព្រហ្មទណ្ឌណាមួយដែលបង្កើតមុនមកសិក្សាប្រៀបធៀបទៅនឹង

ក្រមព្រហ្មទណ្ឌដែលបង្កើតក្រោយ ។ ការធ្វើបែបនេះ គឺជាមធ្យោបាយមួយដ៏ល្អបំផុត ដើម្បីធ្វើឱ្យយើងដឹងអំពីចំណុចដូចគ្នា និងចំណុចខុសគ្នារវាងក្រមទាំងពីរដែលយើងធ្វើការប្រៀបធៀប ។

ការបញ្ជាក់ឱ្យកាន់តែច្បាស់ទៅលើការប្រៀបធៀបនេះ ត្រូវបានលើកយកមកបង្ហាញតាមរយៈការប្រៀបធៀបទៅលើក្រមព្រហ្មទណ្ឌចំនួនពីរ គឺ ក្រមព្រហ្មទណ្ឌខេមរៈឆ្នាំ ១៩០៩ និងក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ ។ ប៉ុន្តែការប្រៀបធៀបក្រមព្រហ្មទណ្ឌទាំងពីរនេះ គឺ យើងសូមលើកឡើងនូវចំណុចមួយយកមកធ្វើការប្រៀបធៀបតែប៉ុណ្ណោះ គឺ ការប្រៀបធៀបទៅលើប្រភេទទោសដែលមានចែងនៅក្នុងក្រមទាំងពីរនេះ ។ មុននឹងឈានទៅដល់ការប្រៀបធៀប យើងត្រូវលើកឡើងនូវការបកស្រាយទៅលើប្រភេទទោសនៅក្នុងក្រមព្រហ្មនីមួយៗជាមុនសិន ក្នុងគោលបំណងដើម្បីបង្ហាញនូវលក្ខណៈនៃប្រភេទទោសនៅក្នុងក្រមចាស់ និងក្រមថ្មី ហើយយកការបកស្រាយទាំងពីរនេះមកថ្លឹមគ្នាដើម្បីទាញបាននូវចំណុចដូចគ្នា និងចំណុចខុសគ្នា ។

ការបកស្រាយទៅលើចំណុចខាងលើនេះត្រូវបានលើកឡើងក្រោមប្រធានបទ ***ការប្រៀបធៀបប្រភេទទោសព្រហ្មទណ្ឌឆ្នាំ ១៩០៩ និង ឆ្នាំ ២០០៩*** ។

## ២.ចំណោទបញ្ហានៃការស្រាវជ្រាវ

មកដល់ពេលនេះ ចំណុចដែលបកស្រាយអំពីប្រភេទទោសក្នុងក្រមទាំងពីរ និងការប្រៀបធៀបបានក្លាយទៅជាចម្ងល់ដ៏សំខាន់មួយសម្រាប់អ្នកសិក្សាស្រាវជ្រាវ ដោយចោទឡើងជាសំនួរថា តើប្រភេទទោសនៃក្រមទាំងពីរមានលក្ខណៈយ៉ាងដូចម្តេច? ហើយ ចំណុចដូចគ្នា និងចំណុចខុសគ្នានៃប្រភេទទោសទាំងពីរមានទៅលើចំណុចណាខ្លះ? ។

## ៣.កម្មវត្ថុនៃការស្រាវជ្រាវ

កម្មវត្ថុនៃការស្រាវជ្រាវរួមមានដូចបង្ហាញខាងក្រោម÷

- ស្វែងយល់អំពីលក្ខណៈនៃប្រភេទទោស ដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌខេមរៈឆ្នាំ ១៩០៩
- ស្វែងយល់អំពីលក្ខណៈនៃប្រភេទទោស ដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩
- ធ្វើការវិភាគទៅលើប្រភេទទោសក្នុងឆ្នាំនីមួយៗ រួចហើយទាញនូវចំណុចដូចគ្នា និងចំណុចខុសគ្នានៃប្រភេទទោសទាំងពីរ
- ធ្វើសេចក្តីសន្និដ្ឋាន និងផ្តល់អនុសាសន៍ ដើម្បីរួមចំណែកនៅក្នុងការកែលម្អទៅលើប្រភេទទោសនីមួយៗ និងការផ្តល់យោបលខ្លះៗចំពោះការអនុវត្តនូវទោសព្រហ្មទណ្ឌនៅក្នុងពេលបច្ចុប្បន្ន ។

## ៤.ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

នៅក្នុងការបកស្រាយទៅលើប្រធានបទនេះ យើងខ្ញុំទាំងពីរនាក់សូមលើកយកមកបកស្រាយតែទៅលើលក្ខណៈនៃប្រភេទទោសព្រហ្មទណ្ឌនៅក្នុងឆ្នាំនីមួយៗ តែប៉ុណ្ណោះ ។ លក្ខណៈនៃប្រភេទទោសនៅក្នុងឆ្នាំទាំងពីរ គឺបង្ហាញអំពីចំនួននៃប្រភេទទោសនៅក្នុងឆ្នាំនីមួយៗ និងធ្វើការបកស្រាយទៅលើប្រភេទទោសទាំងនោះ ហើយបន្ទាប់មកធ្វើការប្រៀបធៀបរវាងប្រភេទទោសនៅក្នុងឆ្នាំទាំងពីរដែលមានចំណុចដូច និងចំណុចខុសគ្នា ។ យើងមិនធ្វើការបកស្រាយទៅលើចំណុចមួយចំនួនផ្សេងទៀតទេ ដូចជា ការប្រកាសទោស របបពាក់កណ្តាលសេរីភាព ការបែងចែកទោសជាប្រភាគ និងវិធានផ្សេងទៀតដែលពាក់ព័ន្ធទៅនឹងប្រភេទទោសឡើយ ។

## ៥.គំរោងនៃការស្រាវជ្រាវ

គំរោងនៃការស្រាវជ្រាវនេះបានបែងចែកជា៤ តំណាក់កាលធំៗដូចខាងក្រោម:

- តំណាក់កាលទី១: រំលឹកឡើងវិញ និងស្វែងយល់បន្ថែមទៅលើទ្រឹស្តីទូទៅនៃទោសព្រហ្មទណ្ឌតាមរយៈឯកសារដែលធ្លាប់បានសិក្សាកន្លងមក និងឯកសារតាមបណ្ណាល័យ និងនៅតាមអ៊ិនធឺណេត។
- តំណាក់កាលទី២: ស្វែងយល់អំពីការប្រភេទទោសនៅក្នុងឆ្នាំនីមួយៗ តាមរយៈការសិក្សាទៅលើក្រមព្រហ្មទណ្ឌខេមរៈឆ្នាំ ១៩០៩ និងក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ ។
- តំណាក់កាលទី៣: ធ្វើការវិភាគទៅលើការបកស្រាយចំពោះលក្ខណៈនៃប្រភេទទោស ហើយស្វែងរកនូវចំណុចដូច និងចំណុចខុសគ្នាយកមកបង្ហាញ ។
- តំណាក់កាលទី៤: ធ្វើសេចក្តីសន្និដ្ឋាន និងផ្តល់ជាអនុសាសន៍ ដើម្បីរួមចំណែកនៅក្នុងការកែលម្អទៅលើប្រភេទទោសនីមួយៗ និងការផ្តល់យោបលខ្លះៗចំពោះការអនុវត្តនូវទោសព្រហ្មទណ្ឌនៅក្នុងពេលបច្ចុប្បន្ន ។

## ៦.វិធីសាស្ត្រនៃការស្រាវជ្រាវ

ដើម្បីជម្រុញ ឱ្យការសិក្សាស្រាវជ្រាវនេះទទួលបានជោគជ័យ គឺចាំបាច់ទាមទារនូវការសិក្សាស្រាវជ្រាវទៅលើឯកសារដែលពាក់ព័ន្ធជាច្រើន និងការប្រមូលពតិមានដែលពាក់ព័ន្ធសម្រាប់ធ្វើជាមូលដ្ឋានការស្រាវជ្រាវប្រធានបទខាងលើ។ ដូចនេះ ការសិក្សាស្រាវជ្រាវនេះត្រូវបានប្រមូលពីប្រភពឯកសារពីរប្រភេទ គឺ ឯកសារចម្បង និងឯកសារបន្ទាប់បន្សំ។ តាមលទ្ធភាពជាក់ស្តែងនៃការសិក្សាស្រាវជ្រាវយើងមានវិធីសាស្ត្រប្រមូលពត៍មានដូចខាងក្រោម:

- **ឯកសារចំបង**
  - ឯកសារដែលបានមកពីច្បាប់ដែលពាក់ព័ន្ធសំខាន់ៗ គឺ ក្រមព្រហ្មទណ្ឌខេមរៈឆ្នាំ ១៩០៩ និងក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩
- **ឯកសារបន្ទាប់បន្សំ**
  - ឯកសារដែលបានមកពី មេរៀនដែលធ្លាប់បានសិក្សាកន្លងមក
  - ឯកសារដែលបានពីសៀវភៅទោសព្រហ្មទណ្ឌ
  - ឯកសារដែលបានមកពីការស្រាវជ្រាវតាមអ៊ិនធឺណេរ
  - ឯកសារដែលបានមកពីការណែនាំរបស់សាស្ត្រាចារ្យដឹកនាំ។
  - ឯកសារដែលបានមកពីការណែនាំ ក៏ដូចជាការពិភាក្សាជាមួយសាស្ត្រាចារ្យផ្សេងទៀត

## ៧.សារៈសំខាន់នៃការស្រាវជ្រាវ

សារៈប្រយោជន៍ដែលទទួលបានពីការស្រាវជ្រាវនេះមានៈ

- **ចំពោះយើងខ្ញុំទាំងពីរនាក់ផ្ទាល់ៈ**
  - ជាភស្តុងតាងដែលបញ្ជាក់ពីលទ្ធផលនឹងស្នាដៃ ដែលបានខិតខំសិក្សាថ្នាក់បរិញ្ញាបត្រអស់រយៈពេល៤ឆ្នាំកន្លងមក។
  - ពង្រីក និងបង្កើនូវចំណេះដឹងផ្ទាល់ខ្លួនផ្នែកព្រហ្មទណ្ឌដោយយល់ដឹងទៅលើក្រមព្រហ្មទណ្ឌដែលបានបង្កើតកន្លងទៅយូរណាស់មកហើយ ហើយយកមកប្រៀបធៀបនឹងក្រមព្រហ្មបច្ចុប្បន្ន ។
  - ជាស្ពានសំរាប់ឱ្យយើងខ្ញុំទាំងពីរអាចសិក្សាបន្តថ្នាក់ឧត្តមសិក្សា។
- **ចំពោះសាធារណៈជនៈ**
  - ជាប្រភពព័តិមានបន្ថែមសំរាប់ការស្វែងយល់អំពីប្រភេទទោសព្រហ្មទណ្ឌដែលមាននៅក្នុងឆ្នាំ ១៩០៩ បន្ថែមទៅលើប្រភេទទោសព្រហ្មទណ្ឌដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ដល់សាធារណៈ ជនមិត្តនិសិត្សទាំងឡាយ និង និសិត្សជំនាន់ក្រោយៗ។
  - ជាប្រភពពិតមានមួយសំរាប់ស្វែងយល់ពីចំណុចដូច និងចំណុចខុសគ្នានៃប្រភេទទោសទាំងពីរ ដែលបង្ហាញឱ្យឃើញនូវការវិវត្តន៍របស់ច្បាប់ដែលប្រែប្រួលទៅតាមចរន្តនៃការប្រែប្រួលរបស់សង្គម ។

## ៨.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

រចនាសម្ព័ន្ធនៃការស្រាវជ្រាវចែកចេញជា៣ ជំពូកដូចជា:

- **សេចក្តីផ្តើម**
- **ជំពូកទី១** ប្រភេទទោសព្រហ្មទណ្ឌឆ្នាំ ១៩០៩
- **ជំពូកទី២:** ប្រភេទទោសព្រហ្មទណ្ឌឆ្នាំ ២០០៩
- **ជំពូកទី៣:** ការប្រៀបធៀបប្រភេទទោសទាំងពីរ
- **សេចក្តីសន្និដ្ឋាន**
- **អនុសាសន៍**
- **ឯកសារយោង**
- **ឧបសម្ព័ន្ធ**

# ជំពូកទី ១
# ប្រភេទទោសព្រហ្មទណ្ឌឆ្នាំ ១៩០៩

ក្រមព្រហ្មទណ្ឌខេមរៈ ឆ្នាំ១៩០៩ (ក្រមចាស់) ត្រូវបានតាក់តែងឡើងនៅថ្ងៃទី៨ ខែមេសា ឆ្នាំ ១៩០៩ បានធ្វើការបែងចែកប្រភេទនៃទោសព្រហ្មទណ្ឌជា ០៣ (បី) ប្រភេទ រួមមាន៖

-ឧក្រិដ្ឋទោស

-មជ្ឈិមទោស

-លហុទោស

បន្ទាប់ពីធ្វើការរៀបរាប់ពីប្រភេទនៃទោសព្រហ្មទណ្ឌរួចមក យើងនឹងធ្វើការបកស្រាយចំពោះប្រភេទទោសនីមួយៗ (១.១) ឧក្រិដ្ឋទោស (១.២) មជ្ឈិមទោស និង(១.៣ )លហុទោស។

## ១.១. ឧក្រិដ្ឋទោស

ឧក្រិដ្ឋទោស គឺជាប្រភេទទោសមួយក្នុងចំណោមប្រភេទទោសទាំងបីដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌខេមរៈឆ្នាំ១៩០៩ ហើយត្រូវបានយកមកបកស្រាយដោយមានការបែងចែកជាពីរចំណុច គឺ (១.១.១) និយមន័យ និង(១.១.២) សណ្ឋាននៃឧក្រិដ្ឋទោស ។

### ១.១.១. និយមន័យនៃឧក្រិដ្ឋទោស

យោងតាមក្រមព្រហ្មទណ្ឌខេមរៈឆ្នាំ ១៩០៩ បានឱ្យនិយមន័យចំពោះឧក្រិដ្ឋទោស គឺមានន័យថា ឧក្រិដ្ឋទោស ឬគរុទោស មហន្តទោស សំដៅលើសេចក្តីខុសដែលច្បាប់ធ្វើទោសដល់ខ្លួន ឬ ធ្វើខ្លួនអ្នកនោះឱ្យខូចកេរ្តិ៍ឈ្មោះយសស័ក្តិមិនរាប់អានតទៅទៀតនោះ [1]។ ម្យ៉ាងទៀតឧក្រិដ្ឋទោស គឺជាប្រភេទនៃទោសដែលមានកម្រិតធ្ងន់ជាងគេក្នុងចំណោមប្រភេទនៃទោសទាំងបី ។

### ១.១.២. សណ្ឋាននៃឧក្រិដ្ឋទោស

នៅក្នុងក្រមព្រហ្មទណ្ឌខេមរៈឆ្នាំ ១៩០៩ បានកំណត់សណ្ឋាននៃឧក្រិដ្ឋទោសជា ០៨(ប្រាំបី) សណ្ឋានរួមមាន៖

- សណ្ឋាន ១ គឺឱ្យពិឃាតជីវិតបង់
- សណ្ឋាន ២ គឺដាក់គុកប្រដៅឱ្យធ្វើការជាទម្ងន់អស់មួយជីវិត
- សណ្ឋាន ៣ គឺឱ្យធ្វើទោសបញ្ជាជយ្យុំ(ការបំបរបង់)ប្រោសនៅទីឯណាមួយ
- សណ្ឋាន ៤ គឺឱ្យដាក់គុកបង្ខំឱ្យធ្វើការជាទម្ងន់មានកំណត់

[1]មាត្រា ១ នៃក្រមព្រហ្មទណ្ឌខេមរៈ ចុះថ្ងៃទី ៨ ខែ មេសា ឆ្នាំ ១៩០៩

- សណ្ឋាន ៥ គឺឱ្យដាក់គុក ទុកពី ៥(ប្រាំ)ឆ្នាំ ទៅដល់ ២០(ម្ភៃ)ឆ្នាំ ឱ្យនៅដោយពួកមិនឱ្យច្រឡំនឹងគ្នា
- សណ្ឋាន ៦ គឺឱ្យដាក់គុកកន្លែងស្ងាត់នៅតែម្នាក់ឯងពី៥ (ប្រាំ) ឆ្នាំ ទៅដល់ ១០(ដប់)ឆ្នាំ
- សណ្ឋាន ៧ គឺឱ្យធ្វើនិរទេសមានកំណត់
- សណ្ឋាន ៨ គឺឱ្យបន្ថយយសស័ក្តិ [2]។

បន្ទាប់ពីបានធ្វើការរៀបរាប់នូវសណ្ឋាននៃបទឧក្រិដ្ឋរួចមក យើងសូមលើកឡើងនូវការបកស្រាយលម្អិតទៅលើសណ្ឋាននីមួយៗ ដូចខាងក្រោម៖

**១.១.២.១. ការពិឃាតជីវិតបង់**

ការពិឃាតជីវិតបង់ ឬ ទោសប្រហារជីវិតសំដៅលើទោសដែលមនុស្សណាដែលមានទោសដល់ស្លាប់ ត្រូវកាត់ក្បាលចេញ [3]។ ការពិឃាតជីវិតបង់ ឬទោសប្រហាជីវិតនេះត្រូវបានកំណត់ក្នុងសណ្ឋាន ១ នៃក្រមព្រហ្មទណ្ឌខេមរៈឆ្នាំ ១៩០៩ ដោយសារតែទោសនេះ គឺជាទោសដែលធ្ងន់ធ្ងរជាងគេក្នុងចំណោមទោសទាំងអស់ ។

ទោសពិឃាតជីវិតបង់ ឬ ទោសប្រហារជីវិតនោះនឹងធ្វើគុតវេលាថ្ងៃបុណ្យ ថ្ងៃសីលមិនបាន[4] មានន័យថាជនដែលត្រូវផ្តន្ទាទោសទោសពិឃាតជីវិតបង់នេះ គឺមិនត្រូវបានឱ្យធ្វើការសម្លាប់នៅថ្ងៃបុណ្យ និង ថ្ងៃសីលទេ ក្រៅពីថ្ងៃទាំងពីរនេះគឺអាចធ្វើការសម្លាប់បាន ព្រោះនៅក្នុងក្រមព្រហ្មទណ្ឌខេមរៈឆ្នាំ១៩០៩ បានធ្វើការកំណត់យ៉ាងច្បាស់លាស់ចំពោះថ្ងៃ ដែលអាចធ្វើការពិឃាតបាន។ចំណែកឯទីកន្លែងដែលនឹងពិឃាត គឺត្រូវយកតាមក្នុងសេចក្តីសាលក្រម [5]។ ប៉ុន្តែក៏នៅតែមានករណីអញ្ញត្តិកម្មមួយចំពោះមនុស្សស្រីដែលមានទោសដល់ស្លាប់ ហើយបើស្រីនោះឆ្លើយថាមានផ្ទៃពោះ ពិនិត្យទៅឃើញពិតមែន នោះត្រូវទុកឱ្យសម្រាលកូនរួច ទើបយកទៅសម្លាប់បាន [6]។ ការធ្វើការពិនិត្យនេះគឺត្រូវធ្វើឡើងដោយមន្ត្រីជំនាញ និង មានការទទួលស្គាល់ដោយតុលាការ ។ ក្រោយពីធ្វើការកាត់ទោសសម្លាប់រួចរាល់ហើយ បើឪពុកម្តាយ ឬញាតិសាលោហិតមកសុំយកទៅធ្វើបុណ្យលើកខ្មោចត្រូវឱ្យបាន តែនឹងធ្វើជារុងរឿងពុំបានឡើយ ។

[2]មាត្រា ៦ នៃក្រមព្រហ្មទណ្ឌខេមរៈ ចុះថ្ងៃទី ៨ ខែ មេសា ឆ្នាំ ១៩០៩

[3]មាត្រា ១០ នៃក្រមព្រហ្មទណ្ឌខេមរៈ ចុះថ្ងៃទី ៨ ខែ មេសា ឆ្នាំ ១៩០៩

[4]មាត្រា ១៩ នៃក្រមព្រហ្មទណ្ឌខេមរៈ ចុះថ្ងៃទី ៨ ខែ មេសា ឆ្នាំ ១៩០៩

[5]មាត្រា ២០ នៃក្រមព្រហ្មទណ្ឌខេមរៈ ចុះថ្ងៃទី ៨ ខែ មេសា ឆ្នាំ ១៩០៩

[6]មាត្រា ២១ នៃក្រមព្រហ្មទណ្ឌខេមរៈ ចុះថ្ងៃទី ៨ ខែ មេសា ឆ្នាំ១៩០៩

ឧទាហរណ៍៖ យោងតាមមាត្រា ៧៧ នៃក្រមព្រហ្មទណ្ឌខេមរៈ ឆ្នាំ ១៩០៩ បានកំណត់ថា ទោះឈ្មោះណា ទៅប្រុងពិឃាដអម្ចាស់ផែនដី សម្តេចព្រះវររាជនី សម្តេចព្រះមហាឧបរាជ សម្តេចព្រះមហាឧបរាជ សម្តេចព្រះអគ្គមហេសី និង ព្រះភិក្ខុសង្ឃសាមណេរ នោះត្រូវធ្វើទោសសម្លាប់ជីវិតបង់។

**១.១.២.២ ការដាក់គុកបង្ខំឱ្យធ្វើការជាទម្ងន់អស់មួយជីវិត**

ការដាក់គុកបង្ខំឱ្យធ្វើការជាទម្ងន់អស់មួយជីវិត គឺជាទោសដែលធ្វើការឃុំខ្លួនមនុស្សទាំងពួងដែលត្រូវទោសដាក់គុកបង្ខំឱ្យធ្វើការជាទម្ងន់នេះតោងប្រើឱ្យធ្វើការជាធ្ងន់យ៉ាងបំផុត [7]។ ទោសនេះគឺជាទោសដែលមានកម្រិតធ្ងន់បន្ទាប់ពីទោសពិឃាតជីវិតបង់ ហើយទោសនេះ គឺមានរយៈពេលអស់មួយជីវិត ។

ឧទាហរណ៍៖ យោងតាមមាត្រា ៩២ នៃក្រមព្រហ្មទណ្ឌខេមរៈឆ្នាំ ១៩០៩ បានចែងថា ទោះឈ្មោះណា ក្លែងធ្វើសិតមាសប្រាក់ ឬ ធ្វើលាយបញ្ចូលជាតិគ្នា គឺមាសប្រាក់ដែលទម្លាប់ច្បាប់បើកឱ្យចាយក្នុងស្រុកខ្មែរ ឬ ជួយយកមាសប្រាក់ដែលក្លែងដូចមាននិយាយខាងលើនេះយកចេញមកចាយ ឬក៏ទទួលយកពីក្រៅ ចូលមកចាយក្នុងដែនអាណាខេត្តក្រុងកម្ពុជាធិបតី នោះត្រូវធ្វើទោសដាក់គុកឱ្យធ្វើការជាទម្ងន់អស់មួយជីវិត ។

**១.១.២.៣. ការធ្វើទោសបញ្ជាជយ្យុំ(ការបំបរបង់)**

ការធ្វើទោសបញ្ជាជយ្យុំ (ការបំបរបង់) ប្រោសនៅទីឯណាមួយ សំដៅលើមនុស្សដែលមានទោសបញ្ជាជយ្យុំ (ទោសគួរដល់ការបណ្តេញចេញ) នោះត្រូវនាំខ្លួនទៅឱ្យនៅនាទីកន្លែងណាមួយ ក្រៅពីដែនក្រុងកម្ពុជាដែលច្បាប់បានបញ្ញត្តិសម្រាប់បញ្ជាជយ្យុំ ។ បើមនុស្សដែលមានទោស បញ្ជាជយ្យុំនោះគេចវេសត្រលប់ចូលមកនៅក្នុងដែនកម្ពុជាវិញ ហើយស្គាល់ជាក់ប្រាកដជាខ្លួននោះនឹងត្រូវយកមកធ្វើទោសបញ្ជាជយ្យុំវិញ លុះត្រាអស់ជីវិត [8]។

ចំពោះរយៈពេលនៃការធ្វើទោសបញ្ជាជយ្យុំនេះវិញ គឺមិនបានកំណត់ពីរយៈពេលនៃការធ្វើទោសនៅក្នុងសណ្ឋាននោះទេ ប៉ុន្តែវាបានកំណត់នៅក្នុងបទល្មើសនីមួយៗ ។ ម្យ៉ាងទៀតការធ្វើទោសបញ្ជាជយ្យុំនេះអាចធ្វើបន្ថែមពីលើទោសដាក់គុក មានន័យថាបន្ទាប់ពីធ្វើទោសដាក់គុករួចរាល់ហើយ នោះត្រូវធ្វើទោសបញ្ជាជយ្យុំបន្តទៀត ។

---

[7] មាត្រា ១២ នៃក្រមព្រហ្មទណ្ឌខេមរៈឆ្នាំ ១៩០៩

[8] មាត្រា ១៣ នៃក្រមព្រហ្មទណ្ឌខេមរៈឆ្នាំ ១៩០៩

ឧទាហរណ៍៖

- យោងតាមមាត្រា ៨៣ បានបញ្ញត្តិថា បើរាជការមានបង្គាប់ ឬ ចាត់ប្រើភ្នាក់ងារក្រសួងឱ្យទៅកែនប្រមូលពួកសេនាទាហាន ឬឱ្យកែនរាស្ត្របញ្ចូលជាទាហានតាមច្បាប់ ហើយឈ្មោះណាមានអំណាចទៅបញ្ចុះបញ្ចូលរាស្ត្រ ឱ្យលើកគ្នាមករឹងទទឹងឃាត់ឃាំង មិនឱ្យក្រសួងភ្នាក់ងារប្រមូលប្រជុំទាហាន ឬ កែនរាស្ត្រដែលត្រូវបញ្ចូលជាទាហានបាន នោះត្រូវធ្វើទោសបញ្ជាជឃ្យុំពី ៥(ប្រាំ)ឆ្នាំ ទៅដល់ ២០(ម្ភៃ)ឆ្នាំ ។
- យោងតាមមាត្រា ១៩៤ ដែលបានបញ្ញត្តិពីការធ្វើទោសដាក់គុកឃុំឱ្យនៅកន្លែងស្ងាត់តែម្នាក់ឯង និង មាត្រា ១៩៥ ដែលបានបញ្ញត្តិធ្វើទោសបញ្ជាជឃ្យុំបន្ថែមពីលើទោសដាក់គុកដែលមាត្រា ១៩៥ នេះបានបញ្ញត្តិថា ឯតួមេនាយ ឬ ស្មុគ្របក្សពួក នោះបើតុលាការយល់ឃើញថាជាវេលាវាគ្រប់កំណត់ទោសដាក់គុកហើយ ល្មមគួរនឹងសម្រេចទោសបញ្ជាជឃ្យុំវាទៀតឱ្យទៅនៅទីឯណាមួយក្រៅពីដែនក្រុងកម្ពុជាក៏បាន តែទោសនេះមិនត្រូវឱ្យហួសពី ១០(ដប់)ឆ្នាំ ឡើងទៅឡើយ ។

**១.១.២.៤. ការដាក់គុកឱ្យធ្វើការជាទម្ងន់មានកំណត់**

ការដាក់គុកឱ្យធ្វើការជាទម្ងន់មានកំណត់ គឺទោសដាក់ឱ្យធ្វើការជាទម្ងន់មានកំណត់នោះបើតិចណាស់ត្រឹម ៥(ប្រាំ)ឆ្នាំ និង យ៉ាងច្រើនដល់ ២០ (ម្ភៃ) ឆ្នាំ [9]។

ឧទាហរណ៍៖ យោងតាមមាត្រា ៩៣ នៃក្រមព្រហ្មទណ្ឌខេមរៈឆ្នាំ ១៩០៩ បានចែងថា ទោះឈ្មោះណាក្លែងធ្វើសិត ឬលាយបញ្ចូលជាតិលុយសេន ដែលទម្លាប់ច្បាប់បើកឱ្យចាយក្នុងអាណាខេត្តខ្មែរ ឬជួយយកចេញមកចាយលុយសេនដែលក្លែងធ្វើសិត ឬ លាយបញ្ចូលជាតិគ្នា ឬ ជួយទទួលយក (ពីក្រៅ) លុយសេនទាំងនោះយកមកចាយក្នុងដែនអាណាខេត្តក្រុងកម្ពុជាធិបតី នោះត្រូវធ្វើទោសដាក់គុកឱ្យធ្វើការជាទម្ងន់មានកំណត់ ។

**១.១.២.៥. ការដាក់គុក ទុកពី ៥(ប្រាំ)ឆ្នាំ ទៅដល់ ២០(ម្ភៃ)ឆ្នាំ ឱ្យនៅដោយពួកមិនឱ្យច្រឡំនឹងគ្នា**

បើឈ្មោះណាមួយត្រូវទោសដាក់គុកឱ្យនៅដោយពួកនោះ ត្រូវដាក់គុកនៅក្នុងនគរផ្សេងពីគុកធម្មតា បំបែកចេញពីមនុស្សដែលត្រូវទោស ជាមជ្ឈិម ជាឧក្រិដ្ឋ បើនឹងនិយាយទៅមករកគ្នាបានតែនឹងមនុស្សដែលនៅក្នុងគុកជាមួយគ្នា ក្រៅពីនោះបានតែមនុស្សដែលច្បាប់បានអនុញ្ញាត ។ ទោសដាក់គុកឱ្យនៅដោយពួកនេះនឹងកាត់ឱ្យថយពី ៥(ប្រាំ) ឆ្នាំ ឬ ឱ្យលើសពី ២០(ម្ភៃ)ឆ្នាំពុំបាន

[9] មាត្រា ១៤ នៃក្រមព្រហ្មទណ្ឌខេមរៈ ចុះថ្ងៃទី ៨ ខែ មេសា ឆ្នាំ ១៩០៩

លើកលែងតែទោសដែលបានបញ្ញត្តិក្នុងមាត្រា ២៧[10] នៃក្រមព្រហ្មទណ្ឌខេមរៈឆ្នាំ ១៩០៩ ដែលបានបញ្ញត្តិថា ″ បើមិនទាន់គ្រប់កំណត់ទោសនិរទេសទេ មនុស្សនោះគេចត្រឡប់ចូលមកដែនក្រុងកម្ពុជាវិញហើយស្គាល់ជាក់ប្រាកដជាខ្លួនវា ត្រូវគិតតថ្ងៃខែទោសនិរទេសដែលនៅសល់ប៉ុន្មាននោះយកមកធ្វើទោសដាក់គុកវាឱ្យនៅដោយពួក ត្រាតែគ្រប់កំណត់ទោសនិរទេស ″ មានន័យថាទោសដាក់គុកឱ្យនៅដោយពួកនេះ គឺមានរយៈពេលចន្លោះពី ៥ឆ្នាំ ទៅ ២០ឆ្នាំ ប៉ុន្តែមានករណីលើកលែងដែលបានបញ្ញត្តិក្នុងមាត្រា ២៧ ដោយរយៈពេលដែលនៅសល់ពីទោសនិរទេសត្រូវយកមកធ្វើទោសដាក់គុកឱ្យនៅដោយពួក ពីព្រោះទោសនិរទេសរយៈពេលនៃការធ្វើទោស គឺយ៉ាងច្រើនត្រឹម ១០(ដប់) ឆ្នាំ ។

ឧទាហរណ៍៖ យោងតាមមាត្រា ៧២ បានបញ្ញត្តិថា បើមន្ត្រី ឬខ្ញុំរាជការសេវកាមាត្យណាមួយរាជការបានប្រគល់ឱ្យរក្សាផែនទីបន្ទាយ រោងធ្វើគ្រឿងសាត្រាវុធ ទ្វារព្រះនគរ ហើយបានឱ្យផែនទីទាំងនោះទោះតិចក្តី ច្រើនក្តីទៅសត្រូវឬប្រើសត្រូវ នោះត្រូវធ្វើទោសសម្លាប់ជីវិតបង់ ។

ប៉ុន្តែបើឱ្យផែនទីទាំងនោះ ទៅប្រទេសដ៏ទៃក្រៅប្រើ ដែលនៅជាកណ្តាលមិនជាមិត្តមិនជាសត្រូវ ឬ ជាមិត្ត នោះត្រូវធ្វើទោសដាក់គុកឱ្យនៅដោយពួកពី ៥(ប្រាំ)ឆ្នាំ ទៅដល់ ២០(ម្ភៃ)ឆ្នាំ ។

**១.១.២.៦. ការដាក់គុកឱ្យនៅកន្លែងស្ងាត់នៅតែម្នាក់ឯងពី ៥ (ប្រាំ)ឆ្នាំ ទៅដល់ ១០ (ដប់)ឆ្នាំ**

ការដាក់គុកឱ្យនៅកន្លែងស្ងាត់នៅតែម្នាក់ឯង សំដៅលើមនុស្សណាមួយទោះប្រុសក្តីស្រីក្តី បើត្រូវដាក់គុកបង្ខាំងតែម្នាក់ឯង នោះឱ្យដាក់គុកហើយប្រើធ្វើការផង ។ ការកំណត់ទោសនេះបើតិចណាស់ត្រឹម ៥ (ប្រាំ) ឆ្នាំ បើច្រើនណាស់ ១០ (ដប់) ឆ្នាំ [11]។

ឧទាហរណ៍៖ យោងតាមមាត្រា ១៩៧ បានបញ្ញត្តិថា ទោះនាម៉ឺនសព្វមុខមន្ត្រី ឬ ភ្នាក់ងារខ្ញុំរាជការជាចៅក្រសួង ត្រូវទទួលធ្វើតាមបង្គាប់រាជការ (មានប៉ូលីសជាដើម) ណាមួយហៅយកមកបង្គាប់ ឬប្រើឱ្យទៅហៅតាមបង្គាប់បម្រើរាជការ (គឺប៉ូលីសជាដើម) ឱ្យរឹងទទឹងមិនឱ្យសម្រេចតាមច្បាប់សណ្ឋានណាក្តី ឬ រឹងទទឹងនឹងព្រះរាជប្រកាសណាមួយក្តី ឬ រឹងទទឹងនឹងរាជការទារពន្ធដែលតាមច្បាប់ត្រូវឱ្យបង់ក្តី ឬ រឹងទទឹងមិនឱ្យសម្រេចតាមសេចក្តីសាលក្រម ឬ សំបុត្រដីកាពីក្រុមតុលាការឱ្យកោះក្តី ឬ បង្គាប់អ្វីនីមួយពីរាជការ ដែលចេញមកឱ្យធ្វើនោះ ត្រូវធ្វើទោសដាក់គុកឃុំឱ្យនៅស្ងាត់តែម្នាក់ឯង ។

---

[10]មាត្រា ១៥ នៃក្រមព្រហ្មទណ្ឌខេមរៈ ចុះថ្ងៃទី ៨ ខែ មេសា ឆ្នាំ ១៩០៩

[11]មាត្រា ១៦ នៃក្រមព្រហ្មទណ្ឌខេមរៈ ចុះថ្ងៃទី ៨ ខែ មេសា ឆ្នាំ ១៩០៩

### ១.១.២.៧. ការធ្វើទោសនិរទេសមានកំណត់

ការធ្វើទោសនិរទេសមានកំណត់ សំដៅលើឈ្មោះណាត្រូវទោសនិរទេស ហើយត្រូវរាជការបញ្ជូនខ្លួនទៅឱ្យនៅក្រៅក្រុងកម្ពុជា កំណត់ទោសនិរទេសនេះយ៉ាងតិច ១ (មួយ)ឆ្នាំ យ៉ាងច្រើនត្រឹម ១០(ដប់)ឆ្នាំ [12] ។ ការធ្វើទោសនិរទេសនេះ មានលក្ខណៈប្រហាក់ប្រហែលនឹងការធ្វើទោសបញ្ជាជយ៉ុំដែរ ដែលទោសទាំងពីរនេះ គឺត្រូវធ្វើទោសដោយការបញ្ជូនខ្លួនឱ្យនៅក្រៅដែនក្រុងកម្ពុជាដូចគ្នា ។ ប៉ុន្តែខុសគ្នាត្រង់ការធ្វើទោសនិរទេសបានកំណត់រយៈពេលច្បាស់លាស់នៅក្នុងសណ្ឋាន ចំណែកឯការធ្វើទោសបញ្ជាជយ៉ុំវិញមិនបានកំណត់ពីរយៈពេល ដែលត្រូវបណ្តេញចេញច្បាស់លាស់នៅក្នុងសណ្ឋានទេ ប៉ុន្តែបានកំណត់ពីរយៈពេលដែលធ្វើទោសនៅក្នុងបទល្មើសនីមួយៗ។

ម្យ៉ាងទៀតបើមិនទាន់គ្រប់កំណត់ទោសនិរទេសទេ មនុស្សនោះរត់គេចត្រឡប់ចូលមកដែនក្រុងកម្ពុជា ហើយស្គាល់ជាក់ប្រាកដជាខ្លួនវា ត្រូវគិតថ្ងៃខែទោសនិរទេសដែលនៅសល់ប៉ុន្មាននោះ យកមកធ្វើទោសដាក់គុកវាឱ្យនៅដោយពួក ត្រាតែគ្រប់កំណត់ទោសនិរទេស [13]។

<u>ឧទាហរណ៍៖</u> យោងតាមមាត្រា ៧៥ បានបញ្ញត្តិថា ទោះឈ្មោះណា បានធ្វើសេចក្តីអ្វីពីរឿងចម្បាំងដែលរាជការពុំបានយល់ព្រមឱ្យអនុញ្ញាតទេ ហើយនាំដំណើរ និងឱ្យកើតហេតុជាចម្បាំងឡើងនោះត្រូវធ្វើទោសនិរទេស ។

### ១.១.២.៨. ការបន្ថយយសស័ក្តិ

ទោសបន្ថយអំណាចយសស័ក្តិនោះគឺ៖

- មិនឱ្យមនុស្សដែលបានត្រូវទោសនោះធ្វើជារាជការធំតូច ជាតំណាងប្រយោជន៍ជនានុជនឬ ធ្វើយសស័ក្តិអ្វី ។
- មិនឱ្យរាប់អានជារាស្ត្រអ្នកស្រុក មានមុខដូចគេ ហើយមិនឱ្យកាន់ការអ្វី ក្នុងរាជការដែនដីព្រះនគរ ។
- មិនឱ្យមានអំណាចពាក់គ្រឿងឥស្សរិយយស ។
- មិនឱ្យមានអំណាចធ្វើជាស្មេរក្សីនសាក្សី ក្នុងសេចក្តីដល់តុលាការ តែបើតុលាការត្រូវការ នឹងយកមកសួរជាដំណឹងបំភ្លឺតុលាការបាន ។
- មិនឱ្យមានអំណាចធ្វើជាអាណាព្យាបាល មិនឱ្យធ្វើជាសេនាទាហានហ្លួង ហើយមិនឱ្យតាំងសាលាបង្រៀន ឬប្រៀនប្រដៅអ្នកទាំងពួងឡើយ [14]។

[12]មាត្រា ២៦ នៃក្រមព្រហ្មទណ្ឌខេមរៈ ចុះថ្ងៃទី ៨ ខែ មេសា ឆ្នាំ ១៩០៩

[13]មាត្រា ២៧ នៃក្រមព្រហ្មទណ្ឌខេមរៈ ចុះថ្ងៃទី ៨ ខែ មេសា ឆ្នាំ ១៩០៩

ទោសបន្ថយអំណាចយសស័ក្តិ ហៅជាតិយស មិនឱ្យរាប់ជាប្រជារាស្ត្រអ្នកស្រុកមានមុខនោះ បើកាត់សេចក្តីគ្រាណាៗក្តី នឹងធ្វើទោសដាក់គុកផងក៏បាន តែនឹងឱ្យលើសពីកំណត់ ៥(ប្រាំ) ឆ្នាំមិនបាន [15]។

ចំពោះទោសដាក់គុកបង្ខំឱ្យធ្វើការជាទម្ងន់មានកំណត់ ១ ទោសដាក់គុកបង្ខាំងឱ្យនៅដោយពួកផ្សេង ១ ទោសដាក់គុកឱ្យនៅស្ងាត់តែឯង ១ ទោសនិរទេស ១ ទោសទាំងបួនសណ្ឋាននេះត្រូវឱ្យបន្ថយអំណាចយសស័ក្តិ តាំងពីថ្ងៃកាត់ទោសសម្រេចសេចក្តីជាស្រេច [16]។

ឧទាហរណ៍៖ យោងតាមមាត្រា ១៨៦ បានបញ្ញត្តិថា ទោះឈ្មោះណាវាយព្រះភិក្ខុសង្ឃសាមណេរអង្គណាមួយ ត្រូវធ្វើទោសព្រោះប្រមាថព្រះភិក្ខុសង្ឃសាមណេរ គឺ បន្ថយអំណាចយសស័ក្តិ ថែមលើទោសដែលបញ្ញត្តិពីវាយអ្នកទាំងពួងឱ្យមានស្លាកស្នាមនោះទៀត ។

- **ចំពោះទ្រព្យរបស់ជនដែលបានត្រូវធ្វើទោសដាក់គុក៖**

អ្នកដែលត្រូវធ្វើទោសដាក់គុកបង្ខំឱ្យធ្វើការជាទម្ងន់មានកំណត់ ឬ ជាទោសដាក់គុកបង្ខាំងឱ្យនៅដោយពួកផ្សេង ឬ ទោសបង្ខាំងឱ្យនៅកន្លែងស្ងាត់តែឯងក្តី ត្រូវបង្ខាំងខ្លួនតាមច្បាប់ ហើយត្រូវចាត់តាំងមនុស្សម្នាក់ ដែលជាអាណាព្យាបាលឱ្យថែរក្សាទ្រព្យសម្បត្តិឈ្មោះនោះ ។ បើមនុស្សដែលត្រូវបានធ្វើទោសនោះពុំរកអ្នករក្សាទ្រព្យទេ ត្រូវក្រុមការឃុំថែរក្សាទ្រព្យឱ្យ [17]។

ចំណែកឯទ្រព្យរបស់ឈ្មោះដែលត្រូវធ្វើទោសនោះ បើគ្រប់កំណត់រួចពីទោសមកត្រូវប្រគល់ឱ្យវាវិញ ។ ឯអ្នកអាណាព្យាបាល ឬ ក្រុមការឃុំ ដែលបានរក្សាទ្រព្យវាទាំងនោះត្រូវប្រាប់វាឱ្យពីចំណាយចំណូល ក្នុងកិច្ចការរក្សាទ្រព្យនោះឱ្យវាដឹងផង [18]។ ម្យ៉ាងទៀតក្នុងរវាងដែលវានៅក្នុងទោសនឹងយកប្រាក់ទ្រព្យរបស់ ឬ ស្បៀងអាហារ ឬ អាករអ្វី ដែលជារបស់វាទៅឱ្យវាមិនបានឡើយ [19]។

សរុបសេចក្តីមកការធ្វើទោសចំពោះឧក្រិដ្ឋទោស គឺ ត្រូវពិនិត្យទៅតាមសណ្ឋានទាំង ៨ ដែលបានកំណត់ និង ការកំណត់ដែលបានបញ្ញត្តិក្នុងបទល្មើសនីមួយៗ ។ ចំពោះប្រភេទទោសទីមួយ គឺឧក្រិដ្ឋទោស ដែលបានកំណត់ធ្វើទោសដាក់គុកសណ្ឋានណាមួយ បើមានសាលក្រមកាត់

---

[14]មាត្រា ២៨ នៃក្រមព្រហ្មទណ្ឌខេមរៈ ចុះថ្ងៃទី ៨ ខែ មេសា ឆ្នាំ ១៩០៩
[15]មាត្រា ២៩ នៃក្រមព្រហ្មទណ្ឌខេមរៈ ចុះថ្ងៃទី ៨ ខែ មេសា ឆ្នាំ ១៩០៩
[16]មាត្រា ២២ នៃក្រមព្រហ្មទណ្ឌខេមរៈ ចុះថ្ងៃទី ៨ ខែ មេសា ឆ្នាំ ១៩០៩
[17]មាត្រា ២៣ នៃក្រមព្រហ្មទណ្ឌខេមរៈ ចុះថ្ងៃទី ៨ ខែ មេសា ឆ្នាំ ១៩០៩
[18]មាត្រា ២៤នៃក្រមព្រហ្មទណ្ឌខេមរៈ ចុះថ្ងៃទី ៨ ខែ មេសា ឆ្នាំ ១៩០៩
[19]មាត្រា ២៥ នៃក្រមព្រហ្មទណ្ឌខេមរៈ ចុះថ្ងៃទី ៨ ខែ មេសា ឆ្នាំ ១៩០៩

ជាស្រេចហើយ ត្រូវគិតរាប់តាំងពីថ្ងៃដែលមនុស្សទោសនោះមកចូលគុក[20] ។ ម្យ៉ាងទៀតបើបានយកមនុស្សដែលត្រូវចោទនោះមកដាក់ក្តីមុន ទើបជំនុំជម្រះចេញសាលក្រមកាត់សេចក្តីធ្វើទោសដាក់គុកនោះត្រូវគិតថ្ងៃខែ ដែលវាមកជាប់ក្តី យកមកកាត់ទោសដែលសម្រេចក្នុងសាលក្រម ។ តែបើប្រការអ្វីផ្សេងៗ ជាហេតុពិតតុលាការមិនកាច់ឱ្យ ឬកាច់ឱ្យខ្លះក៏បាន[21] ។ ចំណែកឯអស់ទាំងសាលក្រម ដែលកាត់ទោសដល់ស្លាប់ ដាក់គុកឱ្យធ្វើការជាទម្ងន់អស់មួយជីវិត ដាក់គុកឱ្យធ្វើការជាទម្ងន់មានកំណត់ ដាក់ទោសដល់បព្វាជយ្យំ ដាក់គុកឱ្យនៅដោយពួក ធ្វើទោសឱ្យនៅស្ងាត់តែម្នាក់ឯងធ្វើទោសនិរទេស ទោសបន្ថយអំណាច ក្នុងសណ្ឋានឯណានីមួយក្តី ត្រូវស្រង់សេចក្តីបោះពុម្ព [22]។ មិនតែប៉ុណ្ណោះសេចក្តីស្រង់ពីសាលក្រមនោះ ត្រូវបិទនៅ៖

- ភូមិដែលធ្វើសាលក្រមនេះ ១
- ទីកន្លែងដែលកើតហេតុនេះ ១
- ទីកន្លែងដែលពិឃាដនេះ ១
- ទីកន្លែងមនុស្សទោសនៅ ១ [23]។

បន្ទាប់ពីធ្វើការបកស្រាយទៅលើឧក្រិដ្ឋទោសដែលមានប្រាំបីសណ្ឋាន ដោយបានធ្វើការបកស្រាយអំពីនិមយមន័យ និងសណ្ឋាននីមួយៗ នៃឧក្រិដ្ឋទោសរួចហើយ ជាបន្តទៅទៀតនេះយើងនឹងធ្វើការបកស្រាយទៅលើប្រភេទទោសទីពីរដែលហៅថា មជ្ឈិមទោស ។

## ១.២. មជ្ឈិមទោស

ការបកស្រាយជាបន្តអំពីប្រភេទទោសទីពីរ គឺមជ្ឈិមទោសដែលរួមមាន (១.២.១)និយមន័យ និង (១.២.២) សណ្ឋាននៃមជ្ឈិមទោស ៖

### ១.២.១. និយមន័យនៃមជ្ឈិមទោស

តាមរយៈក្រមចាស់បានកំណត់ពីអត្ថន័យចំពោះមជ្ឈិមទោស ថាជាទោសខុសដែលច្បាប់ធ្វើទោសដាក់គុកប្រដៅនោះ [24]។

### ១.២.២. សណ្ឋាននៃមជ្ឈិមទោស

មជ្ឈិមទោសមាន ៣ (បី) សណ្ឋានដូចជា៖

[20]មាត្រា ១៧នៃក្រមព្រហ្មទណ្ឌខេមរៈ ចុះថ្ងៃទី ៨ ខែ មេសា ឆ្នាំ ១៩០៩

[21]មាត្រា ១៨ នៃក្រមព្រហ្មទណ្ឌខេមរៈ ចុះថ្ងៃទី ៨ ខែ មេសា ឆ្នាំ ១៩០៩

[22]មាត្រា ៣០ នៃក្រមព្រហ្មទណ្ឌខេមរៈ ចុះថ្ងៃទី ៨ ខែ មេសា ឆ្នាំ ១៩០៩

[23]មាត្រា ៣១ នៃក្រមព្រហ្មទណ្ឌខេមរៈ ចុះថ្ងៃទី ៨ ខែ មេសា ឆ្នាំ ១៩០៩

[24]មាត្រា ១ វាក្យខណ្ឌ នៃក្រមព្រហ្មទណ្ឌខេមរៈ ចុះថ្ងៃទី ៨ ខែ មេសា ឆ្នាំ ១៩០៩

- សណ្ឋាន ១ គឺដាក់គុក ។
- សណ្ឋាន ២ គឺបញ្ញត្តិហាមមិនឱ្យមានអំណាចខ្លះពីយសស័ក្តិ សម្រាប់ខ្លួន សម្រាប់រាជការ ឬសម្រាប់ជាអាណាព្យាបាលក្នុងត្រកូល ។
- សណ្ឋាន ៣ គឺត្រូវឱ្យពិន័យ [25]។

ចំណែកឯខាងក្រោមនេះ គឺជាការបកស្រាយទៅលើខ្លឹមសារលម្អិតនៃសណ្ឋានទាំងបីរបស់មជ្ឈិមទោស៖

### ១.២.២.១. ការដាក់គុក

ទោះឈ្មោះណាមានទោសដាក់គុក នោះត្រូវយកខ្លួនទៅដាក់គុកហើយត្រូវប្រើឱ្យធ្វើការនីមួយៗ ក្នុងគុកកំណត់ទោសនេះយ៉ាងតិច ៦(ប្រាំមួយ) ថ្ងៃ យ៉ាងច្រើន ៥(ប្រាំ)ឆ្នាំ ។ តែបើត្រូវធ្វើទោសម្តងហើយមកត្រូវម្តងទៀតនោះ ឬ ក៏មានទោសផ្សេងទៀតដែលច្បាប់នឹងសម្រេចកំណត់ទោសនោះ ត្រូវធ្វើទោសតាមបញ្ញត្តិ [26]។

**ចំណាំ៖** ទោសដាក់គុកត្រូវគិត៖

- ១ (មួយ)ថ្ងៃ ត្រូវគិត ២៤(ម្ភៃបួន)ម៉ោង
- ១ (មួយ)ខែ ត្រូវគិត ៣០(សាមសិប)ថ្ងៃ
- ១ (មួយ)ឆ្នាំ ត្រូវគិត ១២(ដប់ពីរ)ខែ [27]។

### ១.២.២.២. បញ្ញត្តិហាមមិនឱ្យមានអំណាចខ្លះពីយសស័ក្តិ

បើទោសឯណាដែលច្បាប់បើកអំណាច ឬ បញ្ញត្តិឱ្យធ្វើទោសបញ្ឈប់អំណាចខ្លួនមិនឱ្យប្រជារាស្ត្រអ្នកស្រុកមានមុខ ដូចមាននិយាយក្នុងមាត្រា ២៨ (ទោសបន្ថយអំណាចយសស័ក្តិ) នោះតុលាការនឹងកាត់ធ្វើទោសពេញទាំងអស់ក៏បាន ឬនឹងត្រាប្រណីខ្លះក៏បាន [28]។

### ១.២.២.៣. ការពិន័យ

ការពិន័យ សំដៅលើការពិន័យជាប្រាក់ ដែលការពិន័យនេះ គឺ បានបញ្ញត្តិនៅក្នុងសណ្ឋាន ៣ នៃមជ្ឈិមទោស ។

[25]មាត្រា ៧ នៃក្រមព្រហ្មទណ្ឌខេមរៈ ចុះថ្ងៃទី ៨ ខែ មេសា ឆ្នាំ ១៩០៩
[26]មាត្រា ៣២ នៃក្រមព្រហ្មទណ្ឌខេមរៈ ចុះថ្ងៃទី ៨ ខែ មេសា ឆ្នាំ ១៩០៩
[27]មាត្រា ៣៣ នៃក្រមព្រហ្មទណ្ឌខេមរៈ ចុះថ្ងៃទី ៨ ខែ មេសា ឆ្នាំ១៩០៩
[28]មាត្រា៣៤ នៃក្រមព្រហ្មទណ្ឌខេមរៈ ចុះថ្ងៃទី ៨ ខែ មេសា ឆ្នាំ ១៩០៩

ឧទាហរណ៍៖

មាត្រា ១៥៨. ទោះអ្នកឥតបណ្ដាស័ក្តិ ទៅប្រមាថអ្នកឥតបណ្ដាស័ក្តិដូចគ្នា នោះបើ ជេរផ្ទាល់ ត្រូវពិន័យជាប្រាក់ពី ១២ (ដប់ពីរ) រៀល ។ បើជេរប្រមាថដៀលពូជត្រកូលនោះ ត្រូវពិន័យទ្វេ ១ ជា ២ ។

មាត្រា ១៦៣. ទោះឈ្មោះណាជេរប្រមាថគ្នានៅមុខនាម៉ឺន ឬចៅក្រមណាក្នុងវេលា កំពុងជំនុំជម្រះ ធ្វើរាជការជាក្រសួងមន្ត្រីនោះ នោះត្រូវពិន័យតាមបណ្ដាស័ក្តិនាម៉ឺន ឬមន្ត្រី (ដែលគេជេរនៅមុខ) នោះគឺមួយស័ក្តិ ៥ (ប្រាំ) រៀល ។

## ១.៣. លហុទោស

ប្រភេទទោសចុងក្រោយដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌខេមរៈឆ្នាំ ១៩០៩ គឺ លហុទោស ដែលត្រូវបានលើកយកមកបកស្រាយដោយធ្វើការបែកចែកជាពីរចំណុចសំខាន់ៗរួមមាន (១.៣.១)និយមន័យនៃលហុទោស និង (១.៣.២) សណ្ឋាននៃលហុទោស៖

### ១.៣.១. និយមន័យនៃលហុទោស

ទោសជាលហុ គឺដាក់គុកពិន័យដកហូតយករបស់ទ្រព្យអ្វីតិចច្រើនដែលចាប់រឹបយកមកបាន ទោះជាប្រយោជន៍ឃ្លាំង បើមនុស្សនោះត្រូវទោសជាលហុនោះម្តងហើយ ក្រោយត្រូវទោសនោះម្តងទៀត ត្រូវដាក់គុកពី ១(មួយ)ថ្ងៃ ទៅដល់ ៣ (បី)ថ្ងៃ ជាលហុទោស [29]។

លក្ខណៈសម្គាល់នៃលហុទោស៖

- សេចក្តីជាលហុទោស ជាប្រដៅបន្តិចបន្តួច នោះនឹងឱ្យតិចជាងពី ១(មួយ)ថ្ងៃ ចុះមក ឬឱ្យហួសពី ៥(ប្រាំ)ថ្ងៃឡើងទៅពុំបានឡើយ ។ ឯកំណត់ថ្ងៃនឹងដាក់គុកនោះតោងគិតឱ្យគ្រប់ពេញ ២៤(ម្ភៃបួន) ម៉ោងជាមួយថ្ងៃ [30]។
- ឯប្រាក់ក្រោយពិន័យទោសល្មើសបញ្ញត្តិជាលហុនោះ នឹងកាត់យកពី ២០(ម្ភៃ)សេន ទៅដល់ ៥(ប្រាំ) រៀល ក៏បានតាមដោយសណ្ឋានសេចក្តីដូចមានខាងក្រោយនេះ [31]។

ក្នុងករណីដែលមនុស្សនោះ គ្មានប្រាក់បង់ពិន័យ នោះនឹងធ្វើទោសដាក់គុកបង្ខំសងក្រោយពិន័យក៏បាន តែមនុស្សមានទោសយ៉ាងនេះ មិនត្រូវដាក់គុកបង្ខំនោះហួសពី ១០ (ដប់) ថ្ងៃឡើងទៅឡើយ [32]។

[29] មាត្រា ២៩១ នៃក្រមព្រហ្មទណ្ឌខេមរៈ ចុះថ្ងៃទី ៨ ខែ មេសា ឆ្នាំ ១៩០៩

[30] មាត្រា ២៩២ នៃក្រមព្រហ្មទណ្ឌខេមរៈ ចុះថ្ងៃទី ៨ ខែ មេសា ឆ្នាំ ១៩០៩

[31] មាត្រា ២៩៣ នៃក្រមព្រទណ្ឌខេមរៈ ចុះថ្ងៃទី ៨ ខែ មេសា ឆ្នាំ ១៩០៩

### ១.៣.២. សណ្ឋាននៃលហុទោស

លហុទោស ក៏មាន ៣(បី) សណ្ឋានដូចមជ្ឈិមទោស ប៉ុន្តែមិនបានកំណត់ពីការធ្វើទោសដូចមជ្ឈិមទោសដែលបានកំណត់នៅក្នុងសណ្ឋាននីមួយៗទេ ។

#### ១.៣.២.១. ទោសសណ្ឋានទី ១

- ទោះឈ្មោះណាល្មើសបញ្ញត្តិជាលហុទោស ដែលហាមមិនឱ្យអុចបាញ់ផាវ អុចកាំជ្រួច មានគោមហោះភ្ញីទៀនគោះហ៊ាជាដើម ។
- ទោះឈ្មោះណាធ្វេសប្រហែស ខ្ជិលច្រអូស មិនបោសច្រាស សំអាតផ្លូវច្រកល្ហកក្នុងភូមិស្រុក ដែលត្រូវឱ្យអ្នកស្រុកនៅទីនោះធ្វើថែទាំ ។
- ទោះឈ្មោះណាទុក ឬ ចោលគ្រឿងប្រដាប់ប្រដាធ្វើផ្ទះឬរបស់អ្វីៗ មានឈើ ឥដ្ឋក្បឿងជាដើម ដែលមិនត្រូវការដាក់ ហើយដាក់ឱ្យរាំងរាទទឹងទើសទែង ឱ្យចង្អៀតផ្លូវ មិនស្រួលបង្កើតឱ្យថ្លោះធ្លោយមានគ្រោះ ។
- ទោះឈ្មោះណាខ្ជិលច្រអូស ឬមិនព្រមធ្វើតាមបញ្ញត្តិប្រាមពីកិច្ចការ ថែទាំរក្សាសំអាតផ្លូវសាធារណ:ជនទាំងពួង ។
- ទោះឈ្មោះណាបេះបោច ឬបរិភោគអស់ទាំងផលាអាហារដំណាំរបស់គេនៅទីកន្លែងណាក្តី ហើយពុំបានសុំម្ចាស់របស់ ។
- ទោះឈ្មោះណាពុំបានសុំម្ចាស់របស់ ហើយទៅច្រូតកាត់រើសស្រូវដែលជំរុះជ្រុះកើបកៀរប្រមូលសន្សំយកទៅផលារុក្ខជាតិអ្វីក្នុងស្រែចំការគេ ។
- ទោះឈ្មោះណាឥតគំនិតបាចសាចបោះចោលជារបស់អាសោចទៅលើគេ ។
- ទោះឈ្មោះណាលែងសត្វសម្រាប់ដឹក សម្រាប់ជិះរិតយកទឹកដោះ ឱ្យចូលទៅក្នុងដីគេដែលមិនទាន់ច្រូតកាត់ កាយគាស់បែនបូតជញ្ជូនផលានោះ ។
- ទោះឈ្មោះណាល្មើសនឹងច្បាប់ ដែលរាជការរៀបចំជាត្រឹមត្រូវហើយ មិនព្រមធ្វើតាមរបៀបច្បាប់រាជការ ដែលតែងបញ្ញត្តិសេចក្តីទោសល្មើសបញ្ញត្តិជាលហុទោស ដូចមាននិយាយខាងលើទាំងនេះត្រូវធ្វើទោសពិន័យជាប្រាក់ពី ២០ (ម្ភៃ)សេន ទៅដល់ ១(មួយ)រៀល[33]។

#### ១.៣.២.២ ទោសសណ្ឋានទី ២

ត្រូវធ្វើទោសពិន័យជាប្រាក់ពី១ (មួយ) រៀល ទៅដល់ ៣(បី)រៀល ឬ ដាក់គុកពី១(មួយ) ថ្ងៃ ទៅដល់ ៣(បី)ថ្ងៃ បើឈ្មោះដែលធ្វើខុសដូចមានប្រការខាងក្រោមនេះ៖

[32]មាត្រា ២៩៤ នៃក្រមព្រហ្មទណ្ឌខេមរ: ចុះថ្ងៃទី ៨ ខែ មេសា ឆ្នាំ ១៩០៩

[33]មាត្រា ២៩៦ នៃក្រមព្រហ្មទណ្ឌខេមរ: ចុះថ្ងៃទី ៨ ខែ មេសា ឆ្នាំ ១៩០៩

- ឈ្មោះណាដែលលែងសត្វកាចសាហាវ សត្វអ្វីនីមួយៗនោះធ្វើទុកគេ ឈ្មោះណាដែលបង្កាប់ឆ្កែ តែឆ្កែនោះវាកាច ឬ មិនការពារឱ្យឆ្កែផងខ្លួនក្នុងវេលាវាខាំ ឬវាដេញខាំអ្នកដំណើរ ទោះបានខាំមានស្លាកស្នាម ឬ មិនបានជាពិការខូចខាតអ្វីៗក្តី ។
- ឈ្មោះណាដែលចោលដុំថ្ម ឬ ដុំអ្វីជារឹង ឬ វត្ថុអ្វីមួយជាអសោចទៅលើផ្ទះ ក្នុងរបងច្បារចំការ ឬ កំផែងវាំង ។
- ឈ្មោះណាដែលមិនព្រមទទួលយកប្រាក់អ្វីជារបស់សុទ្ធ ប្រាកដមិនមែនជាក្លែងក្លាយក្រឡៃទេ ពិតជារាជការបើកអំណាចឱ្យចាយក្នុងព្រះនគរខ្មែរ ។
- ឈ្មោះណាក្នុងសម័យវេលា នោះមិនមានកិច្ចការធុរៈអ្វីសោះឡើយ បើនឹងទៅជួយកិច្ចការធុរៈនោះក៏បាន ហើយមិនព្រមទៅ ឬខ្ជិលធ្វេសប្រហែសធ្វើការទាំងពួង ឬធ្វើការជារាជការអ្វីដែលកែនហៅឱ្យជួយក្នុងខណៈមានទុក្ខធុរៈបាបគ្រោះ គឺលិចលង់ទូក ឬទឹកលិច ភ្លើងឆេះផ្ទះ ចោរលួចប្លន់ ឬមិនធ្វើតាមសេចក្តីបង្គាប់របស់តុលាការម្យ៉ាង[34]។

**១.៣.២.៣. ទោសសណ្ឋានទី ៣**

ត្រូវធ្វើទោសពិន័យបី ៣(បី)រៀល ទៅដល់ ៥(ប្រាំ) រៀល ឬនឹងដាក់គុកពី ៣(បី)ថ្ងៃ ទៅដល់ ៥(ប្រាំ) ថ្ងៃ សេចក្តីដែលធ្វើខុសដូចមានក្នុងប្រការខាងក្រោមនេះ៖

- ឈ្មោះណាដែលអាចហ៊ាន ធ្វើលើសក្រៅពីបញ្ញត្តិច្បាប់ ដែលមាននិយាយក្នុងមាត្រា ២៨១ ដល់មាត្រា ២៨៩ ហើយធ្វើពីចិត្តឯងឱ្យខូចអន្តរាយវិនាសបង់របស់ទ្រព្យ មានតាំងតុ គ្រឿងស្លៀកពាក់ គ្រឿងបរិភោគជាដើម ។

អំពើដែលធ្វើឱ្យខូចអន្តរាយវិនាសបង់ទ្រព្យដែលបានបញ្ញត្តិក្នុងមាត្រា ២៨១ ដល់ មាត្រា ២៨៩ រួមមាន៖

- ការដុតផ្ទះ ទូក កប៉ាល់ធំតូច ឃ្លាំង គេហដ្ឋាន ដែលមានមនុស្សមានម្ចាស់នៅ។
- ការលួចដុតដើមស្រូវស្រែ ឬ របរអ្វីជាប្រយោជន៍ដែលគេបេះច្រូតកាត់ ហើយគរជាគំនរ ឬរទេះទូកដែលគេដឹកផ្ទុកទំនិញ។
- ការប្រទូស្តវាយគុំគួននឹងដុតគេហដ្ឋានជាទីលំនៅ ឬរបស់ទ្រព្យអ្វីមួយ។
- ការដុតបំផ្លាញបញ្ជី សំបុត្រសំណៅ ពាក្យអ្វីនីមួយៗជារបស់រាជការគ្រប់ក្រសួងភ្នាក់ងារ ។

[34]មាត្រា ២៩៧ នៃក្រមព្រហ្មទណ្ឌខេមរៈ ចុះថ្ងៃទី ៨ ខែ មេសា ឆ្នាំ១៩០៩

- ការធ្វើឱ្យអន្តរាយវិនាសបង់អស់ទាំងគ្រឿងប្រដាប់អ្វី ដែលសម្រាប់ធ្វើការរបររកស៊ី និងជាទីអាស្រ័យ។
- ការសម្លាប់សត្វចតុប្បាត រួមមាន គោ ក្របី សេះ ។
- ការលុបទប់បឹងរណ្ដៅផ្លូវទឹក កាប់រុះទម្លាយ បំផ្លាញវាំងកំផែង ឬ កាប់ដករបងរកិលបង្ខិត ឬរំលាយរំលីងគាស់ដកបំបាត់គោលចារឹក ឬ អ្វីនីមួយៗដែលគេទុកសម្គាល់ជាដែនខណ្ឌ ចំណាំជាគោលចារឹកព្រំដី ។ ដូច្នេះរាល់អំពើទាំងឡាយដែលបានរៀបរាប់នេះគឺជាប្រភេទនៃឧក្រិដ្ឋទោស ហើយត្រូវធ្វើទោសតាមសណ្ឋាននីមួយៗ ការធ្វើទោសនេះត្រូវបានកំណត់ជាក់លាក់នៅបទល្មើសដែលបានបញ្ញត្តិ ចំណែកឯរាល់អំពើដែលបានធ្វើក្រៅពីអំពើ ដែលបានរៀបរាប់ខាងលើនោះត្រូវចាត់ចូលជាប្រភេទនៃលហុទោសទាំងអស់ ។

- ទោះឈ្មោះណាដែលមិនប្រសព្វ កាន់គ្រឿងសត្រាវុធ ហើយធ្វេសប្រហែសមិនប្រយ័ត្នធ្វើឱ្យស្លាប់ ឬឱ្យមានរបួសសត្វទាំងពួងដែលមានម្ចាស់។
- ឈ្មោះណាដែលបង្កើតជាសេចក្ដីមិនគប្បី ឬ ស្រែកហ៊ោកញ្ជ្រៀវឃោរឃៅដេរពោលឱ្យជាចលាចលអំពល់ដល់អ្នកស្រុក ។
- ឈ្មោះណាដែលបើកហែកពីចិត្ត ជាសំបុត្រប្រកាសបំរាមដែលរាជការបិទ ។
- ឈ្មោះណាដែលគាស់យកស្មៅ ជីកដី ឬ ថ្ម យកចេញពីផ្លូវឥតគំនាប់មិនសុំច្បាប់ ។
- ឈ្មោះណាដែលចូលទៅក្នុងផ្ទះអ្នកផងទាំងពួង គ្មានការហេតុអ្វីជាគប្បី ។
- ឈ្មោះណាដែលមានកាំភ្លើងទុកឥតច្បាប់ ។
- ឈ្មោះណាដែលប្រមឹកស្រវឹង ដើរដួលដេកដោយផ្លូវ ។
- ឈ្មោះណាដែលកោងកាចប្រហើន មើលងាយ ដោយវាចាជាទ្រគោះនឹងអ្នករាជការទាំងពួង។
- ឈ្មោះណាដែលនិយាយជាពាក្យមិនគប្បីទៅនឹងចៅហ្វាយស្រុក និង ក្រុមការងារក្នុងខេត្តក្នុងភូមិ ។
- ឈ្មោះណាដែលមិនព្រមទទួលវេនយាមល្បាត វេលាយប់តាមរាជការត្រូវការ ដែលកែនហៅយកមកប្រើ។
- ឈ្មោះណាដែលឃឹតយូរ ធ្វេសប្រហែសមិនបង់ពន្ធមិនបង់ក្រោយពិន័យ ហើយ និងប្រាក់អ្វីនីមួយដែលជំពាក់រាជការ ។
- ឈ្មោះណាដែលប្រកែករឹងទទឹង ឬ ធ្វេសប្រហែសមិនព្រមចូលមកតាមរាជការកោះហៅ ។

- ឈ្មោះណាដែលទទួលមនុស្សអនាថាឥតទីលំនៅ ឱ្យផ្ទះអាស្រ័យសំណាក់ ហើយនិងមនុស្សចំឡែកចូលមកពីភូមិក្រៅឯទៀត ដែលសំបុត្រជំរៀបថ្លៃរាជការខ្លួន សំបុត្រសម្គាល់ ឬ សំបុត្រច្បាប់ដើរផ្លូវនោះគ្មាន ។
- ឈ្មោះណាដែលដើរចោលភូមិស្រុកផងខ្លួនទៅនៅស្រុកឯទៀត មិនបានជម្រាបប្ដឹងមន្ត្រីជាក្រសួងក្នុងភូមិខ្លួន ឬវេលាដែលខ្លួនបានទៅដល់ភូមិស្រុកឯទៀត ហើយធ្វេសប្រហែសមិនបានប្ដឹងក្រុមការស្រុកគេ ។
- ឈ្មោះណាដែលបានឃើញសាកអសុក អណ្ដែតនៅក្នុងទឹកឬនៅទីកន្លែងណា ហើយធ្វេសប្រហែសមិនបានប្ដឹងមន្ត្រីជាក្រសួងក្នុងស្រុកឱ្យបានដឹង ។
- ឈ្មោះណាដែលបានទិញគោ ក្របី សេះ ហើយពុំបានទារសំបុត្រពីអ្នកលក់ ដែលជាម្ចាស់សត្វនោះមើលឱ្យដឹងប្រាកដជាសត្វនោះរបស់ផងអ្នកលក់មែន ឬ មិនបានឱ្យមន្ត្រីជាក្រសួងក្នុងភូមិស្រុកគេត្រួតពិនិត្យមើលជាប្រាកដត្រឹមត្រូវឱ្យ ។
- ឈ្មោះណាដែលទិញសត្វនោះ ហើយមិនបានយកសត្វដែលខ្លួនទិញនោះមកឱ្យមន្ត្រីជាក្រសួងក្នុងភូមិស្រុក ចុះបញ្ចូលបញ្ជីក្នុងរវាង ៨ (ប្រាំបី) ថ្ងៃ [35]។

សរុបមកលហុទោស គឺ ជាប្រភេទនៃទោសដែលមានលក្ខណៈស្រាលជាងគេក្នុងចំណោមប្រភេទនៃទោសទាំងបី ម្យ៉ាងទៀតលហុទោស គឺបានបញ្ញត្តិពីអំពើដែលជាបទល្មើសបានយ៉ាងច្បាស់លាស់នៅក្នុងសណ្ឋាននីមួយៗ ខុសពីឧក្រិដ្ឋទោស និងមជ្ឈិមទោស ដែលបានបញ្ញត្តិនៅក្នុងមាត្រាផ្សេងគ្នា ហើយនិងការធ្វើទោសទៅតាមសណ្ឋាននីមួយៗ ។

មកដល់ត្រង់នេះ យើងសូមបញ្ចប់នូវការបកស្រាយជំពូកទី១ ដោយសង្ខេបខ្លីតែប៉ុណ្ណឹង ។ បន្ទាប់មកទៀត យើងនឹងធ្វើការបកស្រាយនូវជំពូកទី២ ស្ដីពីប្រភេទទោសព្រហ្មទណ្ឌឆ្នាំ ២០០៩ វិញម្ដង ហើយខ្លឹមសារទាំងស្រុងមានដូចតទៅនេះ៖

[35]មាត្រា ២៩៨ នៃក្រមព្រហ្មទណ្ឌខេមរៈ ចុះថ្ងៃទី ៨ ខែ មេសា ឆ្នាំ ១៩០៩

# ជំពូកទី ២
# ប្រភេទទោសព្រហ្មទណ្ឌឆ្នាំ ២០០៩

ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ២០០៩ ហើយក្រមនេះបានធ្វើការបែងចែកប្រភេទនៃទោសជាបីប្រភេទ គឺ មូលទោស ទោសបន្ថែម និងទោសជំនួស ។

## ២.១. មូលទោស

ដើម្បីយល់បានច្បាស់អំពីមូលទោស ដែលប្រើប្រាស់ចំពោះរូបវន្តបុគ្គលនោះយើងនឹងធ្វើការបកស្រាយទៅលើនិយមន័យនៃមូលទោស(**ចំណុច ២.១.១**) និង ប្រភេទនៃមូលទោស (**ចំណុច ២.១.២**) ដូចមានពន្យល់លម្អិតខាងក្រោម ៖

### ២.១.១. និយមន័យនៃមូលទោស

មូលទោស គឺទោសដាក់ពន្ធនាគារ និងទោសពិន័យ[36]។

មូលទោស គឺជាទោសមូលដ្ឋានដែលយកទៅប្រើប្រាស់សម្រាប់ការប្រកាសទោសចំពោះជនជាប់ចោទដែលបានប្រព្រឹត្តបទល្មើស ។ មូលទោស ត្រូវបានកំណត់ដោយក្រមព្រហ្មទណ្ឌមានទោសដាក់ពន្ធនាគារ និងទោស ពិន័យជាប្រាក់ (មាត្រា ៨៣)[37]។

### ២.១.២. ប្រភេទនៃមូលទោស

យើងឃើញមានចែងកំណត់នៅក្នុងមាត្រា ៨៣ នៃក្រមព្រហ្មទណ្ឌ ។ បើយោងតាមមាត្រា ៨៣ មូលទោសនេះ ត្រូវបានបែងចែកជា ០២ (ពីរ) គឺ

- **ទោសដាក់ពន្ធនាគារ** ដែលយើងហៅសាមញ្ញថា ទោសជាប់គុកនោះឯង។
- **ទោសពិន័យ** ដែលយើងហៅជារួមថា ទោសពិន័យជាប្រាក់ ។

ក្នុងការកំណត់ចំពោះទោសនីមួយៗនេះ ជាគោលការណ៍ច្បាប់ និងយោងតាមក្រមព្រហ្មទណ្ឌចាប់ពីមាត្រា ៨៤ មាត្រា ៨៥ នោះ ជាទូទៅច្បាប់នីមួយៗបានកំណត់ពីអប្បបរមា និងអតិបរមានៃទោសនីមួយៗ មានន័យថាអប្បបរមា សម្រាប់ទោសដាក់ពន្ធនាគារ អតិបរមាសម្រាប់ទោសដាក់ពន្ធនាគារ ក៏ដូចជា អប្បបរមា និង អតិបរមា សម្រាប់ទោសពិន័យជាប្រាក់ ។ ក៏ប៉ុន្តែអប្បបរមាហើយនិងអតិបរមានេះអាចត្រូវបានបន្ថយ ឬ បន្ថែមនេះអាស្រ័យទៅតាមលក្ខខណ្ឌដែលមានកំណត់នៅក្នុងក្រមព្រហ្មទណ្ឌ ។

[36]សទ្ទានុក្រមពាក្យច្បាប់ ផ្នែកក្រមព្រហ្មទណ្ឌ ទីស្ដីការគណៈរដ្ឋមន្ត្រី ឆ្នាំ ២០១១ លេខរៀងទី ១៩៥

[37]យោងតាមឯកសាររបស់ **ឯកឧត្តម ហ៊ី សោភា** រដ្ឋលេខាធិការលំដាប់ថ្នាក់ទីមួយនៃក្រសួងយុត្តិធម៌ ស្ដីពីប្រភេទនៃទោស ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១០

បន្តទៅនេះយើងនឹងពន្យល់ឱ្យបានក្បោះក្បាយអំពីទោសគុក និងពិន័យ ៖

**២.១.២.១. ទោសដាក់ពន្ធនាគារ**

ទោសដាក់ពន្ធនាគារ គឺជាទោសគុកទោសដែលបំបាត់សេរីភាពមានកំណត់កាល ឬគ្មានកំណត់កាល ដែលត្រូវបានផ្តន្ទាទោសដោយដាក់ពន្ធនាគារ[38]។

ដូចបានជម្រាបជូនពីលើចំពោះខ្លឹមសារទាក់ទងជាមួយទោសដាក់ពន្ធនាគារ ឬ ទោសដាក់គុកមានន័យថា ជនម្នាក់ក្រោយពេលដែលសម្រេចទោសដាក់ពន្ធនាគារគាត់រួចហើយគេក៏យកជននេះទៅដាក់គុកពីព្រោះថាការអនុវត្ត គឺធ្វើនៅពន្ធនាគារ ។ ក្រមព្រហ្មទណ្ឌថ្មីបានកំណត់អំពីរបៀបក្នុងការគណនា ចំពោះការដាក់ពន្ធនាគារ ឬគុកនេះទៀតផង[39]។ ហើយក្រមព្រហ្មទណ្ឌបាន កំណត់ទាំងលក្ខខណ្ឌក្នុងការបញ្ចប់ទោសដាក់ពន្ធនាគារទៀតផង[40]ពីព្រោះក្រមព្រហ្មទណ្ឌបានកំណត់ថា៖

- បើសិនជាទោសដាក់ពន្ធនាគារកំណត់ដាក់រយៈពេល ០១ ថ្ងៃ ហេតុដូច្នេះច្បាប់កំណត់ថា ០១ ថ្ងៃ គឺមានរយៈពេល ២៤ ម៉ោង ។
- បើជនម្នាក់ត្រូវបានតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារ ០១ ខែ របៀបក្នុងគណនា ០១ ខែ ត្រូវគិត ៣០ ថ្ងៃ។
- បើសិនជាជនម្នាក់ត្រូវ បានផ្តន្ទាទោសដាក់ពន្ធនាគារក្នុងរយៈពេល ០១ ឆ្នាំ របៀបក្នុងការគណនា ត្រូវគិត ១២ ខែ។

ទន្ទឹមនឹងនេះដែរ ក្រមព្រហ្មទណ្ឌក៏បានចែងពីលក្ខខណ្ឌដោយឡែកនៃការបញ្ចប់ទោសទៀតផង ព្រោះថាជាទូទៅនៅពេលតុលាការផ្តន្ទាទោសដាក់ពន្ធនាគារជនណាម្នាក់ ហើយនៅក្នុងករណីមួយនេះ ជននោះត្រូវទទួលរងទោសនៅក្នុងពន្ធនាគារឱ្យបានគ្រប់ចំនួន ។ បើដាក់គុក ០៣ ឆ្នាំ ត្រូវទទួលរងទោសឱ្យបានគ្រប់ចំនួន០៣ ឆ្នាំ ទៅតាមរបៀបគណនាដូចបាន ជម្រាបជូនពីខាងដើម ។ ប៉ុន្តែវាមានបញ្ហាដោយ ហៅថាករណីពិសេសខ្លះដែលក្នុងនោះការបញ្ចប់ទោសនៅក្នុងពន្ធនាគារគឺអាចបញ្ចប់មុនបាន ។

<u>ឧទាហរណ៍</u> ៖ ដូចជាទោសមួយនោះ ត្រូវបញ្ចប់ចំថ្ងៃឈប់សម្រាក ចំថ្ងៃសៅរ៍ ឬថ្ងៃអាទិត្យ ឬ ថ្ងៃឈប់សម្រាក តាមកាលកំណត់ ដែលបច្ចុប្បន្នគឺកំណត់ ដោយអនុក្រឹត្យរបស់រាជរដ្ឋាភិបាល ។ ដូច្នេះលក្ខខណ្ឌនៃការបញ្ចប់ទោស ក្រមព្រហ្មទណ្ឌបានបញ្ជាក់ជូនថាបើសិនជាពេលដែលត្រូវបញ្ចប់

[38] សទ្ទានុក្រមពាក្យច្បាប់ ផ្នែកក្រមព្រហ្មទណ្ឌ ទីស្តីការគណៈរដ្ឋមន្ត្រី ឆ្នាំ ២០១១ លេខរៀងទី ៤៩

[39] មាត្រា ៤៩ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ចែងអំពី "ការគណនាអំពីថិរវេលានៃទោសដាក់ពន្ធនាគារ"

[40] មាត្រា ៥០ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ចែងអំពី "លក្ខខណ្ឌដោយឡែកនៃការបញ្ចប់ទោស"

ទោសដាក់ពន្ធនាគារប៉ះចំថ្ងៃសៅរ៍ ឬថ្ងៃអាទិត្យ ឬថ្ងៃឈប់សម្រាក ផ្លូវការនោះ គឺនៅក្នុងករណីនេះ ជនដែលជាទណ្ឌិតនោះត្រូវបានដោះលែង ជាទូទៅស្មើនឹង ១ ថ្ងៃមុនថ្ងៃឈប់សម្រាកនោះ ដូចជាករណីថាចំថ្ងៃសៅរ៍ គឺត្រូវដោះលែងគាត់នៅថ្ងៃសុក្រនេះ គឺក្រមព្រហ្មទណ្ឌបានចែងកំណត់បែបហ្នឹង ។ ហើយទន្ទឹមនឹងនេះដែរ ក្រមថ្មីយើងក៏បានចែងអំពីរបបគតិយុត្តផ្សេងទៀត ទាក់ទងនឹងបញ្ហានេះដែរ ពិសេសករណីដូចជាការរាប់បញ្ចូលនូវថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នចូលទៅក្នុងទោសដាក់ពន្ធនាគារជាដើមក្រមថ្មីក៏មានចែងកំណត់ពីបញ្ហានេះដែរ[41] ។ ទាំងនេះទាក់ទងជាមួយនឹងទោសដាក់ពន្ធនាគារ ។ ម្យ៉ាងទៀតបើយោងតាមប្រសាសន៍របស់ **ឯកឧត្តម ហ៊ី សោភា** ធ្លាប់ជារដ្ឋមន្ត្រីស្តីទីនៃក្រសួងយុត្តិធម៌បានបែងចែកទោសគុកនេះជា២(ពីរ)គឺ៖

- ទី ១ ទោសដាក់ពន្ធនាគារមានកាលកំណត់ ដូចជាដាក់ពន្ធនាគារកំណត់ពី ១៥ ឆ្នាំ ទៅ ៣០ ឆ្នាំ
- ទី ២ ទោសដាក់ពន្ធាគារគ្មានកាលកំណត់ គឺទោសដាក់ពន្ធនាគារអស់មួយជីវិត ពីព្រោះថាមិនដឹងពេលណាទណ្ឌិតនោះគាត់ស្លាប់ឡើយ។

#### ២.១.២.១. ទោសពិន័យជាប្រាក់

ភ្ជាប់ជាមួយទោសដាក់ពន្ធនាគារនៅមានទោសមួយទៀត ដែលគេឱ្យឈ្មោះថាទោសពិន័យ ។ ការពិន័យជាប្រាក់ គឺត្រូវគិតជាប្រាក់រៀលដែលជារូបិយវត្ថុជាតិខ្មែរហើយផលដែលបានមកពីការពិន័យជាប្រាក់នេះត្រូវបង់ចូលទៅក្នុងថវិការបស់រដ្ឋ ។

កន្លែងនេះយើងសូមទាញចំណាប់អារម្មណ៍ពីអ្នកអានអំពី "ចំណុចខុសគ្នា" រវាងទោសពិន័យជាប្រាក់នេះជាមួយ និង ការសម្រេចផ្តន្ទាទោសពិសេសករណីឱ្យជនម្នាក់បង់សំណងជម្ងឺចិត្តជាដើម ។ ទោសពិន័យ គឺជាទោសព្រហ្មទណ្ឌមួយប្រភេទក្នុងឋានៈជាមូលទោសខុសពីទណ្ឌកម្មផ្សេងទៀតដែលចៅក្រមគាត់ប្រកាសផ្តន្ទាទោស ។ ករណីជនម្នាក់បានប្រព្រឹត្តបទល្មើសចៅក្រមក៏ប្រកាសផ្តន្ទាទោសដាក់ពន្ធនាគារផង ហើយគាត់សម្រេចឱ្យជនជាប់ចោទបង់ជម្ងឺចិត្តទៅឱ្យជនរងគ្រោះថែមទៀតផង ។

ទាំងអស់ខាងលើនេះទាក់ទងជាមួយនឹងមូលទោស គឺមានចំណុចសំខាន់ៗ ចំនួន ០២ (ពីរ) នេះហើយ ។ ប៉ុន្តែមូលទោសដែលយើងបានជម្រាបជូននេះ គឺអនុវត្តតែចំពោះ**"រូបវន្តបុគ្គលជានីតិជន"** តែប៉ុណ្ណោះ ។ សម្រាប់ការអនុវត្តចំពោះ **"រូបវន្តបុគ្គលជាអនីតិជន"** ច្បាប់បានកំណត់អំពីមូលទោសដាច់ដោយឡែកផ្សេងទៀត។ ខាងក្រោម យើងនឹងពន្យល់អំពីមូលទោសសម្រាប់អនីតិជន៖

[41]មាត្រា ៥១ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ចែងអំពី "ការគិតបញ្ចូលថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន"

អនីតិជន គឺជាជនដែលមិនទាន់គ្រប់អាយុតាមច្បាប់កំណត់ ឬជនដែលមានអាយុក្រោម១៨ ឆ្នាំ[42]។

អនីតិជន គឺជាជនដែលច្បាប់មិនទាន់ឱ្យទទួលខុសត្រូវលើអំពើដែល ខ្លួនបានប្រព្រឹត្ត ។ ឬជាជនដែលច្បាប់កំណត់ឱ្យទទួលខុសត្រូវលើអំពើរបស់ ខ្លួនដោយមានកម្រិត[43]។

សម្រាប់មូលទោសដែលអនុវត្តចំពោះអនីតិជន គឺច្បាប់បានកំណត់នៅក្នុងមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌបានចែងអំពី "មូលទោសដែលអនុវត្តចំពោះអនីតិជនអាយុចាប់ពី១៤ឆ្នាំ ឡើងទៅ"។ បញ្ហានៃទោសដែលប្រើប្រាស់ចំពោះអនីតិជនជាពិសេសការពិន័យជាប្រាក់ ។ ក្នុងនេះពាក់ព័ន្ធជាមួយមាត្រា ៣៨ ដែលបាននិយាយអំពី **នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ**[44] ដែលជា គោលការណ៍របស់វា គឺ ១៨ ឆ្នាំ បើយើងពិនិត្យមើលទៅលើមាត្រា ៣៨ ដែលអង្គសភាបានអនុម័តរួចហើយ ។ នៅក្នុងនោះនិយាយពីនីតិភាពក្នុងការទទួលខុសត្រូវផ្នែកខាងព្រហ្មទណ្ឌគឺអាយុ ១៨ (ដប់ប្រាំបី) ឆ្នាំ តែប្រសិនបើនៅក្នុងស្ថានភាពដោយសារកាលៈទេសៈ ឬ ក៏ដោយសារបុគ្គលិកលក្ខណៈ ឬ មួយក៏ស្ថានភាពនៃចរិកគ្រោះថ្នាក់នៃអំពើនោះធ្ងន់ធ្ងរតុលាការអាចប្រកាសទោសចំពោះ អនីតិជនចាប់ពី ១៤ (ដប់បួន)ឆ្នាំឡើងទៅ ។ ហើយពាក់ព័ន្ធជាមួយនឹងទោសដែលត្រូវអនុវត្តចំពោះ **អនីតិជន**នេះដោយសារផ្អែកទៅលើជំហរនៃទស្សនៈមួយដែលចែងក្នុង***ក្រមរដ្ឋប្បវេណី*** ហើយជាគោលការណ៍សកលផងដែរ ។ ច្បាប់ថាបុគ្គលទាំងឡាយណាដែលទទួលខុសត្រូវវាលុះត្រាតែបុគ្គលនោះអាចពិចារណាលើចំណុចមួយចំនួនដូចជាៈ

- លទ្ធផលដែលកើតចេញមកពីអំពើរបស់ខ្លួន រួចប្រសិនបើជននោះដឹងហើយថាបច្ច័យនោះជាបច្ច័យដែលមានបង្កគ្រោះថ្នាក់ដល់សង្គម ហើយគាត់នៅតែប្រព្រឹត្តអំពើ មានន័យថាគាត់ចង់ឱ្យបច្ច័យដែលគាត់បានឃើញនៅក្នុងសតិអារម្មណ៍របស់គាត់នោះ ស្តែងចេញ ជារូបភាពជាក់ស្តែង។
- ការវាយតម្លៃទៅលើភាពយល់ដឹងរបស់បុគ្គល គឺ មានបញ្ហាពីរដែលមានរបបវេជ្ជសាស្ត្រផង និងរបបចិត្តសាស្ត្រផងដែលគេកំណត់ទៅលើបញ្ហានេះ ។ របបវេជ្ជសាស្ត្រ គឺគិតពិចារណាទៅលើស្ថានភាពនៃជម្ងឺដែលនាំឱ្យជននោះមិនអាចយល់ដឹងបានដូចជាមនុស្ស ដែលស្ថិតនៅក្នុងស្ថានភាពវិបល្លាសស្មារតីជាប្រចាំនេះ គឺ បានន័យថាជាមនុស្សឆ្កួតដែលគាត់មិនអាចពិចារណាអ្វីបាន ។ ចំណែកឯបញ្ហាទី ២ របបចិត្តសាស្ត្រ គឺ តាមបែបធម្មជាតិដែល

[42]សទ្ទានុក្រមពាក្យច្បាប់ ផ្នែករដ្ឋប្បវេណី ទីស្តីការគណៈរដ្ឋមន្ត្រី ឆ្នាំ ២០០៧ លេខរៀងទី ១៨៧

[43]សទ្ទានុក្រមពាក្យច្បាប់ ផ្នែកក្រមព្រហ្មទណ្ឌ ទីស្តីការគណៈរដ្ឋមន្ត្រី ឆ្នាំ ២០១១ លេខរៀងទី ២៣០

[44]**នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ** គឺជាអាយុដែលត្រូវកំណត់ឱ្យទទួលខុសត្រូវលើការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ។ សទ្ទានុក្រមពាក្យច្បាប់ ផ្នែកក្រមព្រហ្មទណ្ឌ ទីស្តីការគណៈរដ្ឋមន្ត្រី ឆ្នាំ ២០១១ លេខរៀងទី ៥៧

គេពិចារណាទៅលើផ្នែកសរីរាង្គនោះ គឺ គេពិនិត្យទៅអាយុវិញ មជ្ឈដ្ឋានជុំវិញ និងការលូតលាស់នៃសេរីរាង្គ ។ សរីរាង្គរួមមានទាំងបញ្ហាសរសៃប្រសាទ ទាំងបញ្ហាសរីរាង្គកាយមិនទាន់រីកចម្រើនទៅដល់កម្រិតមួយដែល អាចទទួលយកបាននូវឥទ្ធិពលពីខាងក្រៅទេ បែបហ្នឹងក៏គាត់មិនទទួលយកបានដែរ។

សរុបមកប្រសិនបើអនីតិជនបានប្រព្រឹត្តបទល្មើស ចំពោះការផ្តន្ទាទោស គឺ ត្រូវធ្វើតាមច្បាប់ដែលបានកំណត់ ហើយចៅក្រមក៏ត្រូវធ្វើការពិចារណាទៅលើចំនុចមួយចំនួនមុននឹងសម្រេចកាត់ទោសជនល្មើសដែលជាអនីតិជន ។ នៅក្នុងច្បាប់គេបាន កំណត់ថា ១៤ឆ្នាំ ដោយសារតែស្ថានភាពនៃការរីកចម្រើនផ្នែកខាងមនុស្សការទទួលនូវឥទ្ធិពលផ្នែកខាងធម្មជាតិដូចជាបញ្ហា ដែលពាក់ព័ន្ធជាមួយនឹងអាកាសធាតុ បញ្ហាសេដ្ឋកិច្ច បញ្ហាសង្គម គឺកំណត់អាយុមនុស្សប្រហែលជា១៤ឆ្នាំទើបអាចយល់ដឹងបានខ្លះៗ ។ ដូច្នេះហើយនៅក្នុងច្បាប់បានកំណត់ថាបើសិនជាអាយុ ១៤ ឆ្នាំ នៅក្នុងកាលៈទេសៈតម្រូវ ចៅក្រមអាចប្រកាសទោស ទៅលើគាត់បាន។ ក៏ប៉ុន្តែទោសនោះ គឺស្ថិតនៅក្នុងលក្ខខណ្ឌមួយដែលទាប ពីព្រោះអនីតិជននោះត្រូវទទួលបាននូវស្ថានសម្រាល ។ ចំណែកទោសពិន័យជាប្រាក់វិញ បើពិនិត្យទៅមើលលើក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ដែលនិយាយអំពីការទទួលខុសត្រូវរបស់អនីតិជនដែលមានអាយុចាប់ពី ១៤ ឆ្នាំឡើងទៅ ។ ជាទូទៅមនុស្សទាំងអស់ នៅក្នុងក្រមរដ្ឋប្បវេណីចែងថាក្លាយទៅជាប្រធាននៃសិទ្ធិ និង កាតព្វកិច្ចនៅពេលដែលមនុស្សបានកើតឡើងហើយរលត់ឋានៈជាប្រធាននៃសិទ្ធិនិងកាតព្វកិច្ចនៅពេលដែលគាត់ស្លាប់ គឺបានន័យថាពេលដែលកើតមកគេអាចក្លាយទៅជាកម្មសិទ្ធិករ ឬ មួយក៏អាចក្លាយទៅជាអ្នកមានកាតព្វកិច្ចតាមផ្លូវច្បាប់។

## ២.២. ទោសបន្ថែម

ការប្រកាសទោសបន្ថែម គឺជាសិទ្ធដែលផ្តល់ឱ្យចៅក្រម ព្រោះពាក្យថាទោសបន្ថែមនៅទីនេះ គឺត្រូវស្របជាមួយនឹងគោលការណ៍ ដែលមានចែងនៅក្នុងមាត្រា៥៤ ជាមុនសិន ដូច្នេះចៅក្រមត្រូវពិនិត្យមើលលើមាត្រាមួយនេះ។

លក្ខខណ្ឌចំពោះការប្រកាសទោសបន្ថែមៈ

មាត្រា ៥៤ ចែងថាទោសបន្ថែមអាចប្រកាសទៅបាន

- លុះត្រាតែទោសនេះត្រូវបានចែងដោយជាក់លាក់ចំពោះបទឧក្រិដ្ឋ ឬបទមជ្ឈិម ឬបទលហុដែលត្រូវចោទប្រកាន់។
- ទោសបន្ថែមនេះទោះបីជាបានចែងច្បាស់លាស់អញ្ចឹងហើយក៏ដោយគាត់អាចប្រកាសក៏បាន មិនប្រកាសក៏បាននេះជាលក្ខខណ្ឌទី ២ ។

- បើច្បាប់បានចែងជាក់លាក់ថា ត្រូវតែប្រកាសទោសបន្ថែមនោះទើបចៅក្រមត្រូវតែប្រកាសទោសបន្ថែមជាកាតព្វកិច្ច ។ ប៉ុន្តែនៅក្នុងច្បាប់ព្រហ្មទណ្ឌទូទៅគេច្រើនតែយកគោលការណ៍មួយថាជ្រើសរើសប្រកាសឬមិនប្រកាស ដោយអាស្រ័យទៅលើបទល្មើសមួយចំនួននោះប្រសិនបើទោសបន្ថែមដែលយើងប្រើទាំង១៩ចំណុច ឬ មួយក៏ប្រើទោសបន្ថែមណាមួយដែលមិនសមស្របបែរទៅជាអត់ប្រយោជន៍ទៅវិញ។

ជាបឋមនៅពេលនេះ យើងគ្រាន់តែចង់ឱ្យដឹងថាក្រៅពីមូលទោសខាងលើ គឺមានទោសមួយទៀតដែលច្បាប់ឱ្យឈ្មោះថា "ទោសបន្ថែម" ។ ដូច្នេះដើម្បីអាចយល់បានច្បាស់លាស់អំពីទោសបន្ថែមដែលប្រើប្រាស់ចំពោះរូបវន្តបុគ្គល យើងនឹងធ្វើការបកស្រាយទៅលើ *និយមន័យ* នៃទោសបន្ថែម(**២.២.១**) និង ប្រភេទទាំង ១៩ ចំណុចសំខាន់ៗ នៃទោសបន្ថែម (**២.២.២**)៖

### ២.២.១. និយមន័យនៃទោសបន្ថែម

ទោសបន្ថែម គឺជាអនុទោស ឬទោសបន្ទាប់បន្សំ[45]។

ទោសបន្ថែម មានន័យថាក្រៅអំពីការផ្តន្ទាទោសជាមូលដ្ឋាន ឬ ក៏ជាមូលទោសដែលមានដូចជាទោសដាក់ពន្ធនាគារ ឬ ទោសពិន័យហើយតុលាការអាចធ្វើការសម្រេចពិចារណាអំពីទោសបន្ថែមដែលអាចប្រកាសចំពោះទណ្ឌិតនោះថែមទៀតបាន ។ ទោសបន្ថែមអាចប្រកាសទៅបានលុះត្រាតែទោសនោះមានចែងយ៉ាងជាក់លាក់ចំពោះបទល្មើសដែលត្រូវបានចោទប្រកាន់(មាត្រា៥៤)[46]។

### ២.២.២. ប្រភេទទាំង ១៩ នៃទោសបន្ថែម

ទោសបន្ថែមនេះ បើយើងមើលទៅក្នុងក្រមព្រហ្មទណ្ឌមានចែងចាប់ ពីមាត្រា ៥៣ ទៅមុខ ។ បើយោងតាមក្រមព្រហ្មទណ្ឌក្នុងមាត្រា ៥៣ ស្តីអំពីប្រភេទនៃទោសបន្ថែម មានចំនួន ១៩ ចំណុច ៖

#### ២.២.២.១ ការដកសិទ្ធខ្លះជាពលរដ្ឋ

មាត្រា ៥៥ ចែងថា "សិទ្ធិពលរដ្ឋដែលអាចដកបានដូចមានចែងក្នុង ចំណុច ១ នៃមាត្រា ៥៣ (ប្រភេទនៃទោសបន្ថែម)នៃក្រមនេះរួមមាន៖

- សិទ្ធិបោះឆ្នោត
- សិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោត
- សិទ្ធិបំពេញការងារជាមន្ត្រីក្របខណ្ឌមុខងារសាធារណៈ

[45] សទ្ទានុក្រមពាក្យច្បាប់ ផ្នែកក្រមព្រហ្មទណ្ឌ ទីស្តីការគណៈរដ្ឋមន្ត្រី ឆ្នាំ ២០១១ លេខរៀងទី ៥០

[46] យោងតាមឯកសាររបស់ **ឯកឧត្តម ហ៊ី សោភា** រដ្ឋលេខាធិការលំដាប់ថ្នាក់ទីមួយនៃក្រសួងយុត្តិធម៌ ស្តីពីប្រភេទនៃទោស ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១០

- សិទ្ធិទទួលការចាត់តាំងជាអ្នកជំនាញ ជាអាជ្ញាកណ្ដាល ឬ ជាអណត្តិគាហករបស់តុលាការ
- សិទ្ធិទទួល និងពាក់គ្រឿងឥស្សរយយសទាំងអស់
- សិទ្ធិធ្វើសាក្សី ដែលទទួលសម្បថនៅមុខតុលាការ

**២.២.២.២ ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈណា ដែលបទល្មើសនោះបានប្រព្រឹត្តនៅក្នុងពេលដែលប្រកបវិជ្ជាជីវៈនេះ**

ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈមិនអនុវត្តទៅលើការបំពេញអាណត្តិដែលជ្រើសតាំងដោយការបោះឆ្នោតជាសាធារណៈ ឬការទទួលខុស ត្រូវខាងសហជីពទេ ។ ការហាមឃាត់នេះមិនអាចអនុវត្តចំពោះបទល្មើសរំលោភលើច្បាប់ស្តីពីរបបសារព័ត៌មានទេ [47]។

**២.២.២.៣ ការហាមឃាត់ចំពោះការបើកបរយានយន្តគ្រប់ប្រភេទ**

ការហាមឃាត់ចំពោះការបើកបរយានយន្តមិនត្រូវលើសពី៥ (ប្រាំ) ឆ្នាំទេ[48]។

<u>ឧទាហរណ៍</u>៖ករណីជនម្នាក់បានប្រព្រឹត្តបទមនុស្សឃាតដោយអចេតនា តាមមាត្រា ២០៧ ។ ក្រោយពេលដែលតុលាការផ្តន្ទាទោសស្ថាពររួចហើយ បន្ទាប់ពីគាត់ចប់ការអនុវត្តនូវទោសគុកថៅក្រមអាចប្រកាសទោសបន្ថែមបានផ្អែកតាមមាត្រា ២០៨ ចែងពីទោសបន្ថែម ៖ ប្រភេទ និងរយៈពេល។

**<u>ចំណាំ</u>** ៖ បើយើងពិនិត្យទៅលើ មាត្រា ៨២ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០០៧ ក៏ឃើញមាននិយាយពីមនុស្សឃាតដោយ អចេតនាផងដែរ ។

**២.២.២.៤ ការព្យួរលិខិតបើកបរ**

ទោសព្យួរលិខិតបើកបរមិនត្រូវលើសពី ៥ (ប្រាំ) ឆ្នាំទេ ។ ទណ្ឌិតត្រូវប្រគល់លិខិតបើកបររបស់ខ្លួនទៅក្រឡាបញ្ជីតុលាការ ។ លិខិតបើកបរត្រូវរក្សាទុកតាមលក្ខខណ្ឌដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ដូច្នេះដើម្បីលម្អិតយើងត្រូវទៅរកមើលនូវប្រកាសនោះវិញ[49]។

<u>ឧទាហរណ៍</u> ៖ ដូចខាងលើតុលាការអាចប្រកាសទោសបន្ថែមទាំងហាមឃាត់ចំពោះការបើកបរយានយន្តគ្រប់ប្រភេទផង និងការព្យួរលិខិតបើកបរផងដែរ ប្រសិនបើគាត់ប្រព្រឹត្តបទល្មើសដូចខាងលើ គឺមនុស្សឃាតដោយអចេតនា ។

[47]មាត្រា ៥៦ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ២០០៩

[48]មាត្រា ៥៧នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ២០០៩

[49]មាត្រា ៥៨នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ២០០៩

### ២.២.២.៥. ការហាមឃាត់ចំពោះការស្នាក់នៅទីកន្លែងមួយចំនួននៃព្រះរាជាណាចក្រកម្ពុជា

ទោសហាមឃាត់ការស្នាក់នៅ គឺជាការហាមឃាត់ដល់ទណ្ឌិតចំពោះការមានមុខនៅទីកន្លែងខ្លះលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។ ទោសនេះមិនអាចលើសពី ១០ (ដប់)ឆ្នាំចំពោះបទឧក្រិដ្ឋ និង៥(ប្រាំ) ឆ្នាំចំពោះបទមជ្ឈិម។

តុលាការកំណត់បញ្ជីនៃទីកន្លែងដែលហាមឃាត់និងកំណត់ថិរវេលានៃការហាមឃាត់។

ការហាមឃាត់ការស្នាក់នៅរួមមានវិធានការតាមដាន។ទណ្ឌិតត្រូវតែ ៖

១-ចូលបង្ហាញខ្លួនតាមដីកាកោះរបស់អាជ្ញាធរតុលាការ ឬ រដ្ឋបាលដែលតុលាការបានចាត់តាំង។

២-ចូលបង្ហាញខ្លួនឱ្យបានទៀងទាត់តាមការកំណត់នៅស្នាក់ការនគរបាល ឬ កងរាជអាវុធហត្ថតាមការចាត់តាំងរបស់តុលាការ។

តុលាការត្រូវកំណត់បែបបទនៃវិធានការតាមដាន។

សេចក្តីសម្រេចរបស់តុលាការត្រូវជូនដំណឹងដោយព្រះរាជអាជ្ញាដល់ក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិក្នុងគោលបំណងសុំឱ្យមានកិច្ចសហប្រតិបត្តិការជាមួយតុលាការ[50]។

<u>ឧទាហរណ៍</u> ៖ ជនម្នាក់ គាត់ជាយោធិនខ្មែរ គាត់បានប្រព្រឹត្តអំពើក្បត់ជាតិ យោងតាមមាត្រា ៤៣៩ និងមាត្រា ៤៤៨ បទផ្តល់ព័ត៌មានមិនពិត ពីព្រោះគាត់កំពុងរស់នៅក្នុងមូលដ្ឋាននៃកងយោធពលខេមរភូមិន្ទតែគាត់បែរជាទៅផ្តល់ដល់អាជ្ញាធរស៊ីវិល ឬ យោធាខ្មែរនូវព័ត៌មានមិនពិតដែលអាចធ្វើឱ្យអន្តរាយដល់ការការពារជាតិដើម្បីបម្រើផលប្រយោជន៍ឱ្យរដ្ឋបរទេស ។ ដូច្នេះចៅក្រមអាចផ្តន្ទាទោសបន្ថែមដល់គាត់ ដោយហាមឃាត់មិនឱ្យចូលទៅស្នាក់នៅក្នុងមូលដ្ឋាននៃកងទ័ពខ្មែរ សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំជាដើម នេះបើផ្អែកតាមមាត្រា ៤៥០ ស្តីពីទោសបន្ថែម ។ បន្ទាប់ពីតុលាការជាអ្នកកំណត់កន្លែងហាមឃាត់រួចហើយគាត់នឹងត្រូវទទួលរងនូវវិធានការតាមដាន ដូចខាងលើទៀតផង។

### ២.២.២.៦.ការហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា

ការហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា មិនត្រូវលើសពី៥ (ប្រាំ) ឆ្នាំ[51]។

[50]មាត្រា ៥៩នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ២០០៩

[51]មាត្រា ៦០នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ២០០៩

ទណ្ឌិតត្រូវតែប្រគល់លិខិតឆ្លងដែនរបស់ខ្លួនទៅក្រឡាបញ្ជីនៃតុលាការ ។ លិខិតឆ្លងដែននេះត្រូវរក្សាទុកតាមលក្ខខណ្ឌដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

ទណ្ឌិតមិនអាចសុំលិខិតឆ្លងដែនបានទេក្នុងរយៈពេលដែលកំពុងទទួលទោសនោះ។

<u>ឧទាហរណ៍</u> ៖ ជនម្នាក់គឺជាយោធិនខ្មែរ គាត់បានប្រព្រឹត្តអំពើក្បត់ជាតិដែរ តាមមាត្រា ៤៣៩ និង មាត្រា ៤៤៣ បទសន្ទិដ្ឋិភាពជាមួយបរទេស ពីព្រោះគាត់រស់នៅក្នុងមូលដ្ឋាននៃកងយោធពលខេមរភូមិន្ទតែគាត់បានត្រូវរ៉ូវគ្នាដោយសម្ងាត់ជាមួយរដ្ឋបរទេស ឬភ្នាក់ងារបរទេសដើម្បីបង្កើតឱ្យមានអំពើ ប្រទូស្តរ៉ាយ ឬ ឱ្យមានអំពើឈ្លានពានប្រឆាំងនឹងព្រះរាជាណាចក្រកម្ពុជា ។ ដូច្នេះ បើមានការផ្តន្ទាទោសស្ថាពរពីបទល្មើសនេះរួចហើយ ក្រោយចេញពីជាប់គុករួចរាល់ចៅក្រមក៏អាចប្រកាសទោសបន្ថែម ដើម្បីហាមឃាត់ចំពោះ ការចាកចេញពីដែនដី នៃព្រះរាជាណាចក្រកម្ពុជា សម្រាប់រយៈពេល ៥ ឆ្នាំនេះបើយោងតាមមាត្រា ៤៥០ ។ ការហាមឃាត់មិនឱ្យគាត់ចាកចេញពីដែនដី នៃប្រទេសកម្ពុជា ពីព្រោះបារម្ភណ៍ថា គាត់អាចនឹងទៅក្រៅប្រទេស ដើម្បី ប្រព្រឹត្តបទល្មើស ដោយត្រូវរ៉ូវជាមួយបរទេស រួចនាំគ្នាមកបំផ្លាញប្រទេស កម្ពុជា ហេតុនេះត្រូវតែដកប៉ាស្ព័រគាត់ទុក ដូច្នេះគាត់មិនអាចទៅណារួចទេ។

**<u>ចំណាំ</u>** ៖ សន្ទិដ្ឋិភាព គឺជាដំណើរព្រមព្រៀងគ្នាដោយរបៀបណាមួយ[52]។

**២.២.២.៧.ការហាមឃាត់ចំពោះការចូល និង ការស្នាក់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា**

ការហាមឃាត់ដល់ទណ្ឌិតបរទេសចំពោះការចូល និងការស្នាក់នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជាអាចជាស្ថាពរឬជាបណ្តោះអាសន្នសម្រាប់រយៈពេល៥(ប្រាំ) ឆ្នាំយ៉ាងច្រើន ។ ការហាមឃាត់នេះនាំឱ្យមានការបណ្តេញទណ្ឌិតឱ្យចេញដោយពេញច្បាប់ នៅពេលបញ្ចប់ទោសដាក់ពន្ធនាគារ[53]។

**២.២.២.៨.ការរឹបអូសឧបករណ៍ សម្ភារៈ ឬ វត្ថុដែលប្រើប្រាស់ក្នុងពេលប្រព្រឹត្តបទល្មើស ឬដែលទុកសម្រាប់ប្រព្រឹត្តបទល្មើស**

ការរឹបអូសឧបករណ៍សម្ភារៈ ឬ វត្ថុណាមួយដែលបានប្រើប្រាស់ក្នុង ការប្រព្រឹត្តបទល្មើស ឬដែលសម្រាប់ប្រព្រឹត្តបទល្មើសមានចែងកំណត់នៅ ក្នុងមាត្រា ៦២ កថាខណ្ឌទី ១ ។

<u>ឧទាហរណ៍</u> ៖ លោក ក ប្រព្រឹត្តបទល្មើសពាក់ព័ន្ធនឹងការផលិតគ្រឿងញៀន ផ្ទុយទៅនឹង ច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ចុះថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ២០០៥ ។ ដូច្នេះ

[52]សទ្ទានុក្រមពាក្យច្បាប់ ផ្នែកក្រមព្រហ្មទណ្ឌ ទីស្តីការគណៈរដ្ឋមន្ត្រី ឆ្នាំ ២០១១ លេខរៀងទី ២១២

[53]មាត្រា ៦១នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ២០០៩

ហើយតុលាការអាចប្រកាសទោសបន្ថែមដោយរឹបអូសនូវឧបករណ៍ សម្ភារៈ ឬ វត្ថុដែលទុកសម្រាប់ផលិតគ្រឿងញៀននោះបាន។

**២.២.២.៩. ការរឹបអូសវត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស**

ការរឹបអូសវត្ថុឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស មានចែងនៅ ក្នុងមាត្រា ៦២ ដដែល កថាខណ្ឌទី ២។

ឧទាហរណ៍ ៖ បន្តពីខាងលើបន្ទាប់ពីតុលាការរឹបអូសនូវហិបដាក់លុយនោះគាត់ថែមទាំងអាចប្រកាសទោសបន្ថែមដោយរឹបអូសយកនូវមូលនិធិ (ប្រាក់) ទាំងនោះបានទៀតផងនេះបើយោងតាមមាត្រា ៩៥ កថាខណ្ឌទី ៦ នៃ ច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ។

**២.២.២.១០. ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស**

ការរឹបអូសផលទុន ឬ ទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើសមានចែងនៅក្នុងមាត្រា ៦២ ដដែល កថាខណ្ឌទី ៣។

ឧទាហរណ៍ ៖ បន្តពីខាងលើទៀត បើគាត់យកប្រាក់ដែលកើតចេញពីការប្រព្រឹត្តអំពើពុករលួយនោះទៅចងការគេដើម្បីយកការប្រាក់ ឬក៏យកលុយទាំងនោះទៅរកស៊ីបានចំណេញដូច្នេះការប្រាក់ឬមូលនិធិដែលចំណេញនេះ គឺជាផលទុនឬទ្រព្យសម្បត្តិដែលកើតចេញពីបទល្មើស ។ បើយោងទៅតាម មាត្រា ៩៥ កថាខណ្ឌទី ៧ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ តុលាការ ប្រកាសទោសបន្ថែមដោយរឹបអូសនូវការប្រាក់ ឬ លុយដែលចំណេញនោះបាន។

**២.២.២.១១. ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬចលនវត្ថុដែលលំអទីកន្លែងដែលបទល្មើសត្រូវបានប្រព្រឹត្ត**

ឧបភោគភណ្ឌ គឺជាឧបករណ៍ប្រើប្រាស់ប្រចាំជីវភាពធម្មតា ។ របស់ឬអីវ៉ាន់សម្រាប់ប្រើប្រាស់ជិតៗខ្លួន[54]។

ការរឹបអូសឧបភោគភណ្ឌសម្ភារៈ និងចលនវត្ថុនៅក្នុងទីកន្លែងដែលបទល្មើសបានប្រព្រឹត្តមានចែងនៅក្នុងមាត្រា ៦២ ដដែល កថាខណ្ឌទី ៤ ។

ឧទាហរណ៍ ៖ អ្នកជំនាញព័ត៌មានវិទ្យា ឬ ជំនាញអាយធីម្នាក់បានប្រព្រឹត្តបទល្មើស ដែលមានចែងពាក់ព័ន្ធនឹងបទល្មើសនៅក្នុងវិស័យព័ត៌មានវិទ្យាដូចក្នុងមាត្រា ៤២៧ ឬ មាត្រា ៤២៨ ឬ មាត្រា ៤២៩ ឬ មាត្រា ៤៣០ នៃក្រមថ្មី។ បើយោងតាមមាត្រា ៤៣២ នៃក្រមព្រហ្មទណ្ឌ គឺតុលាការអាចរឹបអូសដូចជា កុំព្យូទ័រ ម៉ាស៊ីនព្រីន ម៉ាស៊ីនហ្វាក់ ម៉ាស៊ីនហ្វូតូកូពី ប៉ាស់កុំព្យូទ័រ ឬផ្លាសសម្រាប់កូពីឬថតចម្លងឯកសារជាដើម ។ល។ ដែលមាននៅក្នុងទីកន្លែងដែលបានប្រព្រឹត្តបទល្មើសនោះ។

[54]សទ្ទានុក្រមពាក្យច្បាប់ ផ្នែកក្រមព្រហ្មទណ្ឌ ទីស្តីការគណៈរដ្ឋមន្ត្រី ឆ្នាំ ២០១១ លេខរៀងទី ២៥០

### ២.២.២.១២.ការរឹបអូសយានជំនិះដែលជារបស់ទណ្ឌិត

មានចែងនៅក្នុងមាត្រា ៥៣ កថាខណ្ឌទី ១២ និងមានមាត្រា ៦១៥ យកមកធ្វើជាឧទាហរណ៍ ដើម្បីបង្ហាញឱ្យងាយស្រួលយល់ដូចតទៅនេះ ៖

ឧទាហរណ៍ ៖ ជនម្នាក់បានទៅប្រព្រឹត្តអំពើ គឺ បើកបរដោយគ្មានសិទ្ធិនូវយានយន្តដែលមានសញ្ញាសម្គាល់ខាងក្រៅប្រើប្រាស់ដោយភ្នាក់ងារនគរបាល ឬយោធិន ។ ហេតុដូច្នេះចូលទៅនឹងបទល្មើសដែលមានចែងក្នុងមាត្រា ៦១៥ ចែងអំពី "បទប្រើប្រាស់ដោយគ្មានសិទ្ធិនូវយានយន្តដែលមានសញ្ញាសម្គាល់ ប្រើប្រាស់ដោយនគរបាលឬយោធា" ។ នៅក្នុងករណីនេះ តុលាការអាចប្រើ ទោសបន្ថែមតាមរយៈមាត្រា ៦២៤ នៃក្រមព្រហ្មទណ្ឌបាន ដើម្បីរឹបអូសនូវយានជំនិះរបស់ទណ្ឌិត។

ការរឹបអូស មានន័យថាការដកហូតជាអចិន្ត្រៃយ៍នូវទ្រព្យសម្បត្តិណាមួយតាមរយៈសេចក្តីសម្រេចរបស់តុលាការ[55]។

**គួរកត់សម្គាល់** ៖ នៅពេលដែលតុលាការផ្តន្ទាទោសបន្ថែមទៀតរួចហើយប្រសិនបើបំពានលើសេចក្តីសម្រេចរបស់តុលាការ មានបទល្មើសមួយឈ្មោះថា "បទមិនគោរពការរឹបអូស" ដែលមាត្រា ៥៨១ បានចែងយ៉ាងច្បាស់ថាអំពើបំផ្លិចបំផ្លាញលាក់បំបាំងឬគៃបំបាត់វត្ថុរឹបអូសត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ១ (មួយ) ឆ្នាំទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀលទៅ ៤.០០០.០០០ (បួនលាន) រៀល។

ប៉ុន្តែការរឹបអូសមិនអាចប្រកាសបានទេប្រសិនបើមានការប៉ះពាល់ដល់សិទ្ធិរបស់តតិយជន[56]។

ឧទាហរណ៍ ៖ មិត្តភក្តិយើងបានខ្ចីម៉ូតូទៅប្រព្រឹត្តបទល្មើស ដែលយើងមិនបានដឹងខ្លួននោះទេ និងថែមទាំងមិនបានចូលរួមនៅក្នុងបទល្មើសនោះទៀតផងដែរ ។ ដូច្នេះតុលាការមិនអាចរឹបអូសម៉ូតូដែលជាទ្រព្យសម្បត្តិរបស់យើង ដែលជាតតិយជននោះឡើយព្រោះយើងអត់មានកំហុសទេ ។ ម្យ៉ាងវិញទៀត កាលបើការរឹបអូសបានក្លាយទៅជាស្ថាពរ ទ្រព្យសម្បត្តិរឹបអូស ក្លាយទៅជាកម្មសិទ្ធិរបស់រដ្ឋលើកលែងតែមានបទប្បញ្ញត្តិដោយឡែក ដែលចែងអំពីការប្រគល់ផ្សេងពីនេះ ។ ហើយរដ្ឋអាចលក់ឬបំផ្លាញទ្រព្យរឹបអូសតាមនីតិវិធីស្តីពីការលក់ទ្រព្យសម្បត្តិរដ្ឋ (សូមរកនីតិវិធីនេះមកអានបន្ថែមដោយក្តីអនុគ្រោះ)។

### ២.២.២.១៣. ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និង គ្រាប់រំសេវគ្រប់ប្រភេទ

ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និង គ្រាប់រំសេវអាចជាស្ថាពរ ឬ ជាបណ្តោះអាសន្នសម្រាប់រយៈពេល ៥ (ប្រាំ)ឆ្នាំយ៉ាងច្រើន ។ ការហាមឃាត់នេះត្រូវអនុវត្តទៅលើអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទនៅក្នុងព្រះរាជាណាចក្រកម្ពុជា[57]។

---

[55]មាត្រា ៤ កថាខណ្ឌទី ១៤ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ចុះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០១០

[56]មាត្រា ៦២ ឃ្លាចុងក្រោយបង្អស់ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ស្តីពី "ការរឹបអូស"

- អាវុធ សំដៅដល់កាំភ្លើងគ្រប់ប្រភេទដែលផលិត ឬ កែច្នៃតម្លើង និងដែលអាចប្រើប្រាស់ដើម្បីសម្លាប់ ឬ ធ្វើឱ្យរបួស ឬ ធ្វើឱ្យប៉ះពាល់ខូចខាតដល់ ទ្រព្យសម្បត្តិ (មាត្រា ៤៨៨ កថាខណ្ឌទី ២) ។
- គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ សំដៅដល់ឧបករណ៍ ឬសម្ភារៈដែលគេផលិត ឬ កែច្នៃ ដែលអាចប្រើប្រាស់សម្លាប់ ឬ ធ្វើឱ្យរបួស ឬ ធ្វើឱ្យប៉ះពាល់ដល់ទ្រព្យសម្បត្តិ (មាត្រា ៤៨៨ កថាខណ្ឌទី ៣) ។
- អាវុធគីមី អាវុធជីវសាស្ត្រគ្រប់ប្រភេទ ឬគ្រាប់ដទៃទៀត ដែលផ្ទុកជាតិគីមីផ្ទុកជីវសាស្ត្រ សំដៅដល់សារធាតុ ដែលគេផលិត ឬកែច្នៃតម្លើង និងដែល អាចបង្កគ្រោះថ្នាក់ដល់សុខភាព អាយុជីវិត ឬ ទ្រព្យសម្បត្តិ និងបរិស្ថាន (មាត្រា ៤៨៨ កថាខណ្ឌទី ៤)។

**២.២.២.១៤.ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ**

លទ្ធកម្មសាធារណៈ គឺជាការផ្គត់ផ្គង់ទំនិញផ្សេងៗតាមការដេញថ្លៃជាសាធារណៈដោយប្រើថវិការដ្ឋ[58] ។

ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ នាំឱ្យមានការហាមឃាត់ចំពោះការចូលរួមដោយផ្ទាល់ ឬ ដោយប្រយោលក្នុងលទ្ធកម្មសាធារណៈទាំងឡាយដែលរៀបចំដោយៈ

១-រដ្ឋ។

២-រដ្ឋបាលថ្នាក់ក្រោមជាតិ។

៣-គ្រឹះស្ថានសាធារណៈ។

៤-សហគ្រាសដែលទទួលសម្បទានពីរដ្ឋ ឬ ពីរដ្ឋបាលថ្នាក់ក្រោមជាតិឬដែលត្រួតពិនិត្យដោយរដ្ឋឬដោយរដ្ឋបាលថ្នាក់ក្រោមជាតិ។

ទោសបណ្តេញចេញនេះអាចជាស្ថាពរឬជាបណ្តោះអាសន្នសម្រាប់រយៈពេល ៥(ប្រាំ) ឆ្នាំយ៉ាងច្រើន[59]។

- រដ្ឋបាលថ្នាក់ក្រោមជាតិ សំដៅលើរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ [60]។
- គ្រឹះស្ថានសាធារណៈ គឺជាវិមជ្ឈការបច្ចេកទេសដែលគេអាចហៅម្យ៉ាងទៀតថាវិមជ្ឈការតាមសេវាកម្ម គឺជារបៀបគ្រប់គ្រងសេវាកម្មសាធារណៈមួយបែបដែលគេប្រគល់សកម្មភាព

[57]មាត្រា ៦៤នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ២០០៩

[58]សទ្ទានុក្រមពាក្យច្បាប់ ផ្នែកក្រមព្រហ្មទណ្ឌ ទីស្តីការគណៈរដ្ឋមន្ត្រី ឆ្នាំ ២០១១ លេខរៀងទី ២០១

[59]មាត្រា ៦៥នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ២០០៩

[60] សន្ទានុក្រមនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០០៨

បច្ចេកទេសណាមួយរបស់រដ្ឋ ឬរបស់សមូហភាពវិមជ្ឈការទៅឱ្យនីតិបុគ្គលសាធារណៈប្រភេទថ្មីមួយធ្វើដោយស្វ័យភាព ក្នុងគោល ដៅបម្រើផលប្រយោជន៍ទូទៅឱ្យមានប្រសិទ្ធិភាព[61]។

ឧទាហរណ៍ ៖ មានអ្នកដេញថ្លៃមិនត្រឹមត្រូវ ដូចករណីដេញថ្លៃឡូត៍នេសាទជាធម្មតាគេត្រូវដាក់ប្រាក់តម្កល់សម្រាប់ការដេញថ្លៃ យ៉ាងតិចណាស់ ក៏១០ភាគរយសិនដែររួចតម្លៃត្រូវតែដេញឡើងៗ ។ កាលពីមុនមានមនុស្សម្នាក់ជួលឡានម៉ែកសីដែសមួយថ្ងៃមួយរយដុល្លា និងអាវធំគ្រ័រ ស៊េទៅទិញពីផ្សារមួយតម្លៃពីរដុល្លាប្រាំកាក់ព្រមទាំងទិញក្រវ៉ាត់ករមួយតម្លៃ ១០០០ រៀល គឺសុទ្ធតែរបស់ជជុស ។ រួចក៏ហៅគ្នាពីរនាក់ទៀត ដើម្បីទៅចូលរួមដេញថ្លៃស្រាប់តែទៅដល់ក៏មានអ្នកដេញថ្លៃផ្សេងៗទៀតឆ្ងល់ថាមានមនុស្សមកដេញថ្លៃជិះឡានសុទ្ធតែម៉ែកសីដែស ព្រោះកាលនោះគេជិះត្រឹមតែកាម៉ារី ៨២ ទេ ។ គេក៏សួរថាតើគាត់មកធ្វើអ្វី? អ្នកពីរនាក់មកជាមួយនោះកុហកថាគាត់គឺជា ម្ចាស់ឡូត៍នេសាទខេត្តនេះ ខេត្តនោះ ចំនួនបីបួនទៅហើយ ប៉ុន្តែគាត់ចង់មក យកខេត្តនេះមួយទៀត ។ ម្យ៉ាងលោកថៅកែបានដាក់ប្រាក់ធានារួចហើយបើនិយាយឱ្យចំមែនទែនគាត់បានប្រាប់ថាក្នុងមួយជីវិតរបស់គាត់បើដេញថ្លៃមិនបានទេ គឺកាត់ក្បាលបោះចោល ។ អ្នកពួក៏ភ័យ និងសូមឱ្យអ្នកទាំងពីរនោះជួយកុំឱ្យគាត់ចូលរួមអី ។ ក៏ប៉ុន្តែពួកនេះបាននិយាយថាគាត់បានដាក់ប្រាក់តម្កល់រួចហើយបើមិនចូលរួមគេនឹងយកប្រាក់នោះទៅបាត់ហើយ ។ ចំណែកឯអ្នកកំពុងតែភ័យ ក៏អង្វរថាឥឡូវយកប្រាក់តម្កល់នោះវិញទៅ ហើយខ្លួននឹងថែមឱ្យប្រាក់ ១០០០ ដុល្លាទៀត ។ ស្រាប់តែពួកនោះក៏យល់ព្រមដោយយកលុយទាំងនោះមកចែកគ្នាអស់ ។ សរុបមកអ្នកដែលធ្វើនូវអំពើបែបហ្នឹង ប្រសិនបើជាតុលាការរកឃើញថៅក្រមនឹងប្រកាសទោសបន្ថែមមួយទៀតដោយលែងឱ្យចូលទៅក្នុងការដេញថ្លៃបែបនេះតទៅទៀតហើយ ពីព្រោះគាត់បានធ្វើនូវអំពើដែលមិនត្រឹមត្រូវនៅក្នុងការដេញថ្លៃដើម្បីកម្ចាត់អ្នកដេញថ្លៃដទៃទៀតកុំឱ្យគេចូលរួមដេញថ្លៃបាន ។

### ២.២.២.១៥.ការបិទគ្រឹះស្ថានដែលប្រើប្រាស់ដើម្បីត្រៀម ឬប្រព្រឹត្តបទល្មើស

គ្រឹះស្ថាន គឺជាកន្លែងធ្វើពាណិជ្ជកម្មអាជីវកម្មឬសហគ្រាស[62] ។ ទោសបិទគ្រឹះស្ថាននាំឱ្យមានការហាមឃាត់ចំពោះការធ្វើសកម្មភាពនៅក្នុងគ្រឹះស្ថាន ដែលនៅក្នុងឱកាសធ្វើសកម្មភាពនោះបទល្មើសត្រូវបានប្រព្រឹត្តឡើង។

ទោសបិទគ្រឹះស្ថាននេះអាចជាស្ថាពរឬជាបណ្តោះអាសន្នសម្រាប់រយៈពេល ៥(ប្រាំ) ឆ្នាំយ៉ាងច្រើន។ (មាត្រា ៦៦)

---

[61] សៀវភៅនីតិរដ្ឋបាលទូទៅ របស់បណ្ឌិត សាយ បូរី ឆ្នាំ២០០៦ ទំព័រទី៤០៣

[62]សទ្ទានុក្រមពាក្យច្បាប់ ផ្នែកក្រមព្រហ្មទណ្ឌ ទីស្តីការគណៈរដ្ឋមន្ត្រី ឆ្នាំ ២០១១ លេខរៀងទី ៣៦

ឧទាហរណ៍ ៖ ជនម្នាក់បានប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រា ២៩១ នៃក្រមព្រហ្មទណ្ឌថ្មី គឺ "បទដឹកនាំគ្រប់គ្រងគ្រឹះស្ថានសម្រាប់ធ្វើពេស្យាចារ" ដែលមាត្រានេះចែងបានថាអំពើគ្រប់គ្រងធ្វើអាជីវកម្មដឹកនាំធ្វើឱ្យដំណើរការ ឬ ចេញប្រាក់ឱ្យគ្រឹះស្ថានពេស្យាចារ ដោយផ្ទាល់ ឬ តាមរយៈអន្តរការី ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ ពី ៤.០០០.០០០ (បួនលាន) រៀលទៅ ១០.០០០.០០០ (ដប់លាន) រៀល ។ ដូច្នេះ តុលាការគឺអាចបិទចោលនូវគ្រឹះស្ថានសម្រាប់ធ្វើពេស្យាចារ្យនេះបាន រយៈពេល ៥ ឆ្នាំ ឬក៏បិទរហូតជាស្ថាពរតែម្តង នេះបើយោងតាមមាត្រា ២៩៥ កថាខណ្ឌទី ១១ ស្តីពីទោសបន្ថែម។

**២.២.២.១៦.ការហាមឃាត់ចំពោះការធ្វើអាជីវកម្មនៅក្នុងគ្រឹះស្ថាន ដែលបើកចំហសម្រាប់សាធារណជន ឬដែលប្រើប្រាស់ដោយសាធារណជន**

ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថាន ដែលបើកចំហសម្រាប់សាធារណជន ឬ ដែលត្រូវប្រើប្រាស់ដោយសាធារណជនអាចជាស្ថាពរឬជាបណ្តោះអាសន្នសម្រាប់រយៈពេល៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន[63]។

ឧទាហរណ៍ ៖ ជនម្នាក់បានប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រា ២៩៣ នៃក្រមព្រហ្មទណ្ឌថ្មី គឺ "បទដាក់ឱ្យប្រើប្រាស់ទីកន្លែងសម្រាប់ធ្វើពេស្យាចារ" ដោយមាត្រានេះបានចែងថាត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ចំពោះបុគ្គលដែលលក់ ឬដាក់ឱ្យបុគ្គល ណាម្នាក់ ប្រើប្រាស់ទីកន្លែង ដែលមិនមែនប្រើប្រាស់ដោយសាធារណជនដោយដឹងជាក់ច្បាស់ថាបុគ្គលនោះនឹងប្រើប្រាស់ទីកន្លែងនោះ សម្រាប់ធ្វើ សកម្មភាពពេស្យាចារ ។ បើយោងតាមមាត្រា ២៩៥ កថាខណ្ឌទី ១២ ស្តីពី ទោសបន្ថែម គឺចៅក្រមអាចប្រកាសទោសបន្ថែមនេះដើម្បីហាមបានសម្រាប់ រយៈពេល ៥ ឆ្នាំ ឬជាស្ថាពរ គឺ ស្មើនឹងអស់មួយជីវិតតែម្តង។

**២.២.២.១៧.ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស**

ទោសបិទផ្សាយសេចក្តីសម្រេចត្រូវអនុវត្តនៅទីកន្លែង ដែលចង្អុលបង្ហាញដោយតុលាការ និងក្នុងរយៈពេលមួយដែលកំណត់ដោយតុលាការ ។ ការបិទផ្សាយមិនអាចលើសពី២(ពីរ)ខែទេ ។ ការបិទផ្សាយអាចធ្វើទាំងស្រុង ឬតាមសម្រង់ឬតាមនិទ្ទេសធម្មតា ។ សោហ៊ុយបិទផ្សាយ គឺជាបន្ទុករបស់ទណ្ឌិត។

[63] មាត្រា ៦៧នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ២០០៩

ក្នុងករណីមានការបំបាត់ចោលការលាក់បំបាំង ឬការហែកចោលសេចក្តីប្រកាសនេះត្រូវតែធ្វើការបិទផ្សាយជាថ្មី។ ការបិទផ្សាយនេះត្រូវចេញសោហ៊ុយដោយអ្នកបំបាត់ចោលលាក់បំបាំងឬអ្នកហែកចោលសេចក្តីប្រកាសនេះ [64]។

*និទ្ទេស* គឺជាសេចក្តីចារឹកសេចក្តីដែលចុះដោយសង្ខេបនៅលើរឹមទំព័រ ឬនៅចុងទំព័រនៃលិខិតណាមួយ[65]។

<u>ឧទាហរណ៍</u> ៖ ករណីដែលបុគ្គលមួយរូបបានទៅប្រព្រឹត្តអំពើដក ឬ ផ្លាស់ទីកន្លែងនៃគោលព្រំដែលដាក់ដោយអាជ្ញាធរសាធារណៈ ។ ពេលនោះគាត់នឹងជាប់ទោសពី "បទបំលាស់ទីនៃគោលព្រំ" ដែលមាននៅក្នុងបទប្បញ្ញត្តិនៃមាត្រា ៦២២ នៃក្រមព្រហ្មទណ្ឌថ្មី ។ យោងតាមអត្ថន័យនេះតុលាការក៏អាចប្រកាសទោសបន្ថែមដោយផ្អែកលើមាត្រា៦២៤ស្តីពីទោសបន្ថែមៈប្រភេទ និងរយៈពេលត្រង់ចំណុចទី ៨ ពាក់ព័ន្ធនឹងការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោសសម្រាប់រយៈពេល២ (ពីរ) ខែយ៉ាងច្រើនផងដែរ។

### ២.២.២.១៨.ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារពត៌មានសរសេរ

ទោសផ្សាយសេចក្តីសម្រេចរបស់តុលាការ ត្រូវចុះផ្សាយក្នុងសារព័ត៌មានសរសេរតាមបែបបទនិងក្នុងចិរវេលាដែលកំណត់ដោយតុលាការ ។ សោហ៊ុយក្នុងការចុះផ្សាយជាបន្ទុករបស់ទណ្ឌិត ។ បើតុលាការបានបង្គាប់ការផ្សព្វផ្សាយសេចក្តីសម្រេចសារព័ត៌មានមិនអាចបដិសេធការផ្សព្វផ្សាយនេះបានទេ[66]។

<u>ឧទាហរណ៍</u> ៖ មើលមិនឃើញអាចមានជនអគតិណាម្នាក់ខ្វះវិចារណញ្ញាណនឹងទៅប្រព្រឹត្តបទរាជឃាតកម្មនេះបានន័យថា គឺ នឹងអាចលួចធ្វើឃាតកម្មចំពោះអង្គព្រះមហាក្សត្រ ។ ប្រសិនបើមានដូច្នេះមែននោះ តុលាការនឹងត្រូវធ្វើការផ្តន្ទាទោសដាក់គុកដល់ជននេះអស់មួយជីវិតស្របតាមបទប្បញ្ញត្តិមាត្រា៤៣៣ ក្រៅពីនេះដើម្បីឱ្យប្រជាពលរដ្ឋខ្មែរគ្រប់រូបបានស្គាល់ និងយល់ដឹងគ្រប់ៗគ្នាទាំងអស់ពេញផ្ទៃប្រទេសនោះ គឺតុលាការអាចប្រើប្រាស់មាត្រា៤៣៨ត្រង់ចំណុចទី៩ស្តីពីការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស នៅក្នុងសារព័ត៌មានសរសេរដូចជាកាសែតភ្នំពេញប៉ុស្តិ៍ កាសែតរស្មីកម្ពុជាកាសែតកោះសន្តិភាព ការសែតដើមអម្ពិល ។ល។ ដើម្បីបោះផ្សាយចែកគ្នាអានឱ្យបានដឹងគ្រប់ៗគ្នា។

---

[64] មាត្រា ៦៨នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ២០០៩

[65]សទ្ទានុក្រមពាក្យច្បាប់ ផ្នែកក្រមព្រហ្មទណ្ឌ ទីស្តីការគណៈរដ្ឋមន្ត្រី ឆ្នាំ ២០១១ លេខរៀងទី ៥៥

[66] មាត្រា ៦៩នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ២០០៩

### ២.២.២.១៩.ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសតាមគ្រប់មធ្យោបាយ

ទូរគមនាគមន៍សោតទស្សន៍ ទោសផ្សាយជាសាធារណៈនូវសេចក្ដីសម្រេចតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ត្រូវអនុវត្តតាមបែបបទដែលកំណត់ដោយតុលាការ ។ ការផ្សាយនេះមិនអាចលើសពី៨ (ប្រាំបី)ថ្ងៃទេ ។ ការផ្សាយអាចផ្សាយទាំងស្រុងតាមសម្រង់ឬតាមនិទ្ទេស។សោហ៊ុយនៃការផ្សាយគឺជាបន្ទុករបស់ទណ្ឌិត[67]។

ទូរគមនាគមន៍សោតទស្សន៍គឺជាប្រព័ន្ធផ្សព្វផ្សាយ ទូរទស្សន៍[68]។

<u>ឧទាហរណ៍</u> ៖ បន្ថែមពីករណីរាជឃាតកម្មខាងលើចៅក្រមក៏អាចប្រើប្រាស់នូវទោសបន្ថែមស្របតាមមាត្រា៤៣៨ ត្រង់ចំណុចទី១០ពាក់ព័ន្ធទៅនឹងការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសនៅតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃយ៉ាងច្រើនដូចជាការផ្សាយតាមរយៈវិទ្យុនិងការផ្សាយតាមរយៈទូរទស្សន៍ ដើម្បីឱ្យរាស្ត្រប្រជាគ្រប់រូបបានឮបានឃើញបានស្គាល់នូវឧក្រិដ្ឋជនដ៏សាហាវ យង់ឃ្នងឃោរឃៅពីព្រោះថាអំពើបែបនេះគឺជាបទល្មើសប្រឆាំងនឹងជាតិដែលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ស្ថាប័នចម្បងរបស់រដ្ឋពិសេស គឺប៉ះពាល់ដល់និមិត្តរូបនៃឯកភាពជាតិនិរន្តរភាពជាតិអ្នកធានាឯករាជ្យជាតិអធិបតេយ្យ និងបូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជាក៏ដូចជាបំពានដល់អ្នកធានាការគោរពសិទ្ធិ និងសេរីភាពរបស់ប្រជាពលរដ្ឋនិងការគោរពសន្ធិសញ្ញាអន្តរជាតិជាដើម។ (មានចែងក្នុងមាត្រា៨នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣) ។

## ២.៣. ទោសជំនួស

ក្រៅពីទោសទាំងពីរខាងលើ គឺមានទោសមួយទៀតដែលច្បាប់ឱ្យឈ្មោះថាទោសជំនួស។ ទោសជំនួសនេះ គឺមានចែងក្នុងក្រមព្រហ្មទណ្ឌ ជាប្រភេទទី ៣ នៃទោស ចាប់ពីមាត្រា ៧២ ដល់មាត្រា ៧៦ គឺមានចែងអំពីទោសជំនួសនេះ ។ តើទោសជំនួសគឺជាអ្វី?ហើយទោសជំនួសមានប៉ុន្មានប្រភេទ ? អ្វីខ្លះ ? ដូច្នេះដើម្បីអាចយល់បានច្បាស់អំពីទោសជំនួសដែលប្រើប្រាស់ចំពោះរូបវន្តបុគ្គល យើងនឹងធ្វើការបកស្រាយ ទៅលើនិយមន័យនៃទោសជំនួស (**ចំណុច ២.៣.១**) និង ប្រភេទនៃទោសជំនួស (**ចំណុច ២.៣.២**) ៖

### ២.៣.១. និយមន័យនៃទោសជំនួស

ទោសជំនួស គឺទោសការងារសហគមន៍ ឬ ការស្ដីបន្ទោសដែលត្រូវបានកំណត់ជាជំនួសទោសដាក់ពន្ធនាគារ[69]។

[67] មាត្រា ៧០នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ២០០៩

[68]សទ្ទានុក្រមពាក្យច្បាប់ ផ្នែកក្រមព្រហ្មទណ្ឌ ទីស្ដីការគណៈរដ្ឋមន្ត្រី ឆ្នាំ ២០១១ លេខរៀងទី ៤៦

ទោសជំនួសដោយផ្អែកទៅលើគោលការណ៍មនុស្សធម៌ ចៅក្រមអាចពិនិត្យទៅលើស្ថានភាពកាលៈទេសៈនៃការប្រព្រឹត្តបទល្មើស ដើម្បីមិនអនុវត្តទោសដែលជាមូលដ្ឋានដោយយកទោសជំនួសមកអនុវត្តវិញ[70]។

## ២.៣.២. ប្រភេទនៃទោសជំនួស

តើទោសជំនួសនេះមានអ្វីខ្លះ ?

តាមក្រមព្រហ្មទណ្ឌ គឺទោសជំនួសមានពីរប្រភេទ ៖យើងឃើញមានចែងកំណត់នៅក្នុងមាត្រា ៧២ ដល់មាត្រា ៧៦ នៃក្រមព្រហ្មទណ្ឌ ។ យោងទៅតាមមាត្រាទាំងអស់នេះទោសជំនួសត្រូវបានក្រមព្រហ្មទណ្ឌចែកចេញជា ០២(ពីរ) ប្រភេទសំខាន់ៗគឺ

- ទោសការងារសហគមន៍ និង
- ទោសស្តីបន្ទោស

### ២.៣.២.១. ទោសការងារសហគមន៍

ទោសនេះ គឺជាសញ្ញាណថ្មីស្រឡាងសម្រាប់ប្រទេសកម្ពុជាយើងហើយ ។ យើងនឹងពន្យល់ចំណុចនីមួយៗឱ្យបានក្បោះក្បាយដូចតទៅ ៖

#### ក. និយមន័យនៃការងារសហគមន៍

តុលាការអាចប្រកាសទោសការងារសហគមន៍បានបើកាលណាជនជាប់ចោទទទួលទោសដាក់ពន្ធនាគារ ដែលអតិបរមាតិចជាង ឬស្មើនឹង ៣ (បី) ឆ្នាំ ។

ទោសការងារសហគមន៍ គឺជាទោសជំនួសមួយប្រភេទដែលតម្រូវឱ្យទណ្ឌិតបំពេញការងារក្នុងចិរវេលាចន្លោះពី ៣០ (សាមសិប) ម៉ោង ទៅ ២០០ (ពីររយ) ម៉ោង ដោយគ្មានកម្រៃជាប្រយោជន៍ដល់រដ្ឋ រដ្ឋបាលថ្នាក់ក្រោមជាតិ ឬ នីតិបុគ្គលនៃនីតិសាធារណៈផ្សេងៗទៀត ដល់សមាគម ឬ ដល់អង្គការមិនមែនរដ្ឋាភិបាល[71]។

ដូច្នេះទោសការងារសហគមន៍ គឺសំដៅដល់កាតព្វកិច្ចមួយដែលត្រូវបំពេញនៅការងារមួយដែលគ្មានកម្រៃ និងជាប្រយោជន៍សាធារណៈ បានន័យថាជាប្រយោជន៍របស់រដ្ឋរបស់រដ្ឋបាលថ្នាក់ក្រោមជាតិរបស់នីតិបុគ្គលនៃនីតិសាធារណៈដ៏ទៃទៀត ឬ របស់សមាគម ឬ របស់អង្គការមិន

---

[69]សទ្ទានុក្រមពាក្យច្បាប់ ផ្នែកក្រមព្រហ្មទណ្ឌ ទីស្តីការគណៈរដ្ឋមន្ត្រី ឆ្នាំ ២០១១ លេខរៀងទី ៤៨

[70]យោងតាមឯកសាររបស់ **ឯកឧត្តម ហ៊ី សោភា**រដ្ឋលេខាធិការលំដាប់ថ្នាក់ទីមួយនៃក្រសួងយុត្តិធម៌ ស្តីពីប្រភេទនៃទោស ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១០

[71]សទ្ទានុក្រមពាក្យច្បាប់ ផ្នែកក្រមព្រហ្មទណ្ឌ ទីស្តីការគណៈរដ្ឋមន្ត្រី ឆ្នាំ ២០១១ លេខរៀងទី ៤៧

មែនរដ្ឋាភិបាល [72]។ ការងារសហគមន៍នេះអាចប្រែប្រួលរយៈពេលម៉ោងធ្វើការចាប់ពី ៣០ ម៉ោង ដល់ ២០០ ម៉ោង។

ឧទាហរណ៍ ៖ ជាក់ស្តែងតុលាការមិនប្រកាសពីមូលទោសទេ ប៉ុន្តែគាត់អាចប្រកាសអំពីការងារសហគមន៍ ប្រសិនបើជននោះគាត់មានវត្តមាននៅពេលសវនាការហើយគាត់យល់ព្រមទទួលយកការងារសហគមន៍ គឺតុលាការអាចប្រកាសការងារសហគមន៍ ដូចជាធ្វើការងាររយៈពេល ៥០ ម៉ោង ដើម្បីជាប្រយោជន៍សាធារណៈមួយ ។ ដូច្នេះ នៅពេលដែលតុលាការប្រកាសនោះ គឺគាត់នឹងកំណត់ពីបែបបទ និងរយៈពេលចំពោះការធ្វើទោសការងារសហគមន៍នោះ ។ ប៉ុន្តែការងារសហគមន៍នេះព្រះរាជអាជ្ញាមិនមែនចេះតែឱ្យគាត់ធ្វើពីមួយថ្ងៃទៅមួយថ្ងៃដោយឥតឈប់នោះទេ គឺត្រូវធ្វើនៅពេលម៉ោងណាមួយ ដែលទុកពេលវេលាផ្សេងទៀតឱ្យគាត់ទៅធ្វើការរកស៊ីដើម្បីឱ្យគាត់ចិញ្ចឹមជីវិតខ្លួនគាត់ និងចិញ្ចឹមជីវិតគ្រួសារគាត់ផង។

ការប្រកាសទោសការងារសហគមន៍បានផ្តល់ផលប្រយោជន៍ច្រើនដូចជា៖

- ទីមួយ ៖រដ្ឋមិនបាត់បង់សមាជិករបស់ខ្លួនទេ។
- ទីពីរ ៖ គឺកាត់បន្ថយការចំណាយរបស់រដ្ឋ ដូចជា ចំណាយទៅលើការចិញ្ចឹម ការបីបាច់ ការថែរក្សា ដូចជា គាត់ឈឺត្រូវយក គាត់ទៅពេទ្យរឺឯកន្លែងដែលដាក់គុកមនុស្ស ។
- ងាយនឹងអប់រំកែប្រែគាត់ខ្លាំងណាស់[73] ។ លើសពីនេះទៅទៀតនៅពេលដែលតុលាការប្រកាសទោសការងារសហគមន៍នោះរួច ព្រះរាជអាជ្ញានឹងចង្អុលបង្ហាញហើយថា តើនីតិបុគ្គលមួយណាដែលទទួលប្រយោជន៍ការងារសហគមន៍នេះ? ហេតុនេះព្រះរាជអាជ្ញា គាត់អាចសម្រេចថាឥឡូវឱ្យជនហ្នឹងទៅបោសសំរាមនៅសាលារាជធានីភ្នំពេញ ឬ ជួយដល់ការងារកាកបាទក្រហមជាដើម បើដូច្នេះមែនទណ្ឌិតត្រូវអនុវត្តការងារនេះ ក្រោមការត្រួតពិនិត្យរបស់ព្រះរាជអាជ្ញា ។

**ខ.របបគតិយុត្តនៃការងារសហគមន៍**[74]

គតិយុត្ត គឺតាមគន្លងច្បាប់ ឬ ដែលទាក់ទងនឹងច្បាប់ ដែលត្រឹមត្រូវ តាមច្បាប់។

---

[72] មាត្រា ៧២នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ២០០៩

[73]យោងតាមប្រសាសន៍របស់**ឯកឧត្តម ហ៊ី សោភា** ប្រធានក្រុមការងារចូលរួមតាក់តែង និងការពារសេចក្តីព្រាងក្រមព្រហ្មទណ្ឌ នាពេលបង្រៀនដល់អ្នករៀបរៀង កាលពីថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១១ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ស្តីពី "ក្រមព្រហ្មទណ្ឌ"

[74] មាត្រា ៧៤នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ២០០៩

ការងារសហាគមន៍ អាចត្រួតគ្នាបានជាមួយនឹងការអនុវត្តសកម្មភាព វិជ្ជាជីវៈ។

ការងារសហាគមន៍ គឺត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ការងារជាអាទិ៍ការងារនៅពេលយប់ អនាម័យ សន្តិសុខ និង ការងាររបស់ស្ត្រី ។ តែភាគច្រើនគឺមិនសូវប្រើចំពោះការងារកុមារនោះទេ ព្រោះកុមារ ឬអនីតិជន ដែលមានអាយុពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំច្រើនតែ ប្រើប្រាស់នូវយន្តការថ្មីស្ដីពី "ការស្ដីបន្ទោស" ទៅវិញទេ។

**គ.អ្នកមិនទទួលផលប្រយោជន៍នៃការងារសហាគមន៍** [75]

នៅក្នុងគ្រប់ករណីទាំងអស់ការងារសហាគមន៍ មិនអាចបំពេញជាប្រយោជន៍នៃរូបវន្តបុគ្គលទេ ពីព្រោះនេះជាផលប្រយោជន៍របស់ឯកជនសុទ្ធសាធ គឺមិនមែនជាផលប្រយោជន៍របស់សាធារណៈទេ ។ ម្យ៉ាងទៀតករណីនេះធ្លាប់មានរឿងពិតមែនដែលបុគ្គលឯកជនបានយកជនដែលធ្វើការងារនេះទៅបម្រើផលប្រយោជន៍ឱ្យខ្លួនឯងផ្ទាល់ ។ ដោយសារតែមានមូលហេតុបែបនេះទើបច្បាប់ត្រូវតែចែងដើម្បីហាមកុំឱ្យមានករណីនេះកើតឡើងតទៅទៀត ។

**ឃ.គោលការណ៍ជួសជុលការខូចខាតដល់អ្នកដទៃ**[76]

រដ្ឋត្រូវតែចេញសោហ៊ុយជួសជុលការខូចខាត ដែលបង្កដល់អ្នកដទៃដោយទណ្ឌិតនៅក្នុងពេលដែលកំពុងអនុវត្តការងារសហាគមន៍ ។ រដ្ឋត្រូវធ្វើឧបាទេសកម្មដោយពេញច្បាប់ទៅក្នុងសិទ្ធិជនរងគ្រោះ ពីព្រោះពេលខ្លះជនដែលទទួលរងនូវការងារសហាគមន៍នេះគ្មានថវិកាបង់ខ្លួនឯងទេ។ ផ្ទុយទៅវិញ បើរដ្ឋមិនចេញសំណងឱ្យនោះទេជនរងគ្រោះនឹងមិនទទួលបានការជួសជុលនូវព្យសនកម្ម ឬ ការខូចខាតឡើយ ។ ដូច្នេះនឹងបណ្ដាលឱ្យមានភាពអយុត្តិធម៌ចំពោះជនរងគ្រោះដែលជាពលរដ្ឋរបស់ខ្លួនជាក់ជាមិនខានឡើយ ។ សរុបមក ដើម្បីឱ្យមានភាពយុត្តិធម៌វិញ ក្រមព្រហ្មទណ្ឌថ្មីក៏បានកំណត់ឱ្យរដ្ឋត្រូវធ្វើ ឧបាទេសកម្មដោយពេញច្បាប់ទៅក្នុងសិទ្ធិរបស់ជនរងគ្រោះវិញ ។ *ឧបាទេសកម្ម* គឺជាឋានៈមួយដែលបុគ្គលម្នាក់ទទួលជំនួសបុគ្គលណាមួយទៅតាមផ្លូវច្បាប់ ។ ដូច្នេះរដ្ឋក្លាយទៅជាម្ចាស់បំណុល ដើម្បីប្ដឹងទារសំណងពីទណ្ឌិតនោះវិញក៏ប៉ុន្តែបើជននោះគ្មានថវិកាបង់សងជូនរដ្ឋទាល់តែសោះ ហេតុដូចនេះថវិកាដែលរដ្ឋចេញសងជំនួសនោះអត់ទទួលបានត្រឡប់មករដ្ឋវិញទេ ពីព្រោះតែទណ្ឌិតគ្មានថវិកាសងរដ្ឋឡើយ។

ទោសការងារសហាគមន៍មានលក្ខណៈដូចខាងលើនេះហើយ គឺជាប្រភេទទោសជំនួសទី ១។ បន្តទៅទៀត យើងនឹងសិក្សាពីប្រភេទទី ២ ម្ដងៈ

[75] មាត្រា ៧៣នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ២០០៩

[76] មាត្រា ៧៥នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ២០០៩

**២.៣.២.២. ទោសស្តីបន្ទោស**

ការស្តីបន្ទោសនេះក៏ជាយន្តការថ្មីស្រឡាងមួយដែរនៅក្នុងទោសព្រហ្មទណ្ឌ ។ យើងនឹងធ្វើការពន្យល់ត្រួសៗអំពីបញ្ហានេះតែយើងសូមបញ្ជាក់ជូនថានៅក្នុងការពន្យល់លើកនេះ គឺគ្រាន់តែជម្រាបជូនអំពីខ្លឹមសារប៉ុណ្ណោះ ។ ប៉ុន្តែរបៀប និងលក្ខខណ្ឌ នៃការប្រកាសទោសការងារសហគមន៍ក៏ដូចជាការស្តីបន្ទោសហ្នឹង គឺ ក្រមបានចែងជាក់លាក់ថា តើលក្ខខណ្ឌណា ដែលអាចឱ្យគាត់ប្រកាសទោសនេះបានមិនមែនគាត់ចេះតែប្រកាសការស្តីបន្ទោសគ្រប់បទល្មើសបានទេ គឺគាត់ត្រូវមើលទៅតាមកាលៈទេសៈ ទៅតាមស្ថានភាពជាក់លាក់នីមួយៗ។

**ក. អត្ថន័យនៃទោសស្តីបន្ទោស**

ទោសស្តីបន្ទោស គឺជាប្រភេទទោសមួយដែលក្នុងនោះ គឺជាទោសដែលប្រើប្រាស់សម្រាប់បទល្មើសស្រាល ហើយចៅក្រមគាត់មិនសម្រេចដាក់ពន្ធនាគារ ឬពិន័យជាប្រាក់អ្វីនោះទេ ប៉ុន្តែចៅក្រមគាត់អាចប្រកាសទោសនេះបាន ព្រោះទោសស្តីបន្ទោស គឺ ជាការព្រមានការប្រដៅអំពីទោសកំហុសឆ្គងដែលគាត់បានប្រព្រឹត្ត ហើយជាការព្រមានថាកុំឱ្យគាត់ប្រព្រឹត្តបទល្មើសតទៅទៀត[77]។ ម្យ៉ាងវិញទៀតទោសស្តីបន្ទោស គឺ ភាគច្រើនប្រើចំពោះកុមារឬអនីតិជនដែលមានអាយុចាប់ពី ១៤ ឆ្នាំ ឡើងទៅដល់ក្រោម ១៨ ឆ្នាំ។ ក៏ប៉ុន្តែចៅក្រមនឹងប្រាប់ថាថ្ងៃក្រោយគ្មានការអនុគ្រោះណាមួយទៀតទេប្រសិនបើអ្នកនៅតែប្រព្រឹត្តអំពើបែបនេះតទៅទៀត[78]។

**ខ. របបគតិយុត្តនៃការស្តីបន្ទោស**[79]

កាលបើជនជាប់ចោទរងទោសដាក់ពន្ធនាគារដែលអតិបរមាតិចជាង ឬស្មើនឹង ៣ (បី) ឆ្នាំ តុលាការអាចប្រកាសស្តីបន្ទោស ប្រសិនបើមានគ្រប់ លក្ខខណ្ឌទាំងបីដូចតទៅនេះ ៖

- ភាពចលាចលដល់សណ្តាប់ធ្នាប់សាធារណៈ ដែលបណ្តាលមកពីបទល្មើសបានបញ្ចប់
- ការខូចខាតត្រូវបានជួសជុលរួចហើយ និង
- ជនជាប់ចោទបានបង្ហាញការធានាក្នុងការចូល ទៅរួមរស់នៅក្នុងសង្គមវិញ។

[77]យោងតាមប្រសាសន៍របស់**ឯកឧត្តម កើត រិទ្ធ** អនុប្រធានក្រុមការងារចូលរួមតាក់តែង និងការពារសេចក្តីព្រាងក្រមព្រហ្មទណ្ឌ នៅក្នុងកម្មវិធីផ្សព្វផ្សាយច្បាប់ស្តីពី "ក្រមព្រហ្មទណ្ឌ" ដែលរៀបចំឡើងដោយ ក្រសួងយុត្តិធម៌សហការជាមួយក្រសួងព័ត៌មានតាមរយៈទូរទស្សន៍ជាតិកម្ពុជា

[78]យោងតាមប្រសាសន៍របស់**ឯកឧត្តម ហ៊ី សោភា** ប្រធានក្រុមការងារចូលរួមតាក់តែង និងការពារសេចក្តីព្រាងក្រមព្រហ្មទណ្ឌ នាពេលបង្រៀនដល់អ្នករៀបរៀង កាលពី ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១១នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ស្តីពី "ក្រមព្រហ្មទណ្ឌ"

[79] មាត្រា ៧៦នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ២០០៩

ឥឡូវនេះយើងសូមធ្វើការបញ្ចប់នូវការបកស្រាយជំពូកទី២ ស្តីអំពី ប្រភេទទោសព្រហ្មទណ្ឌ ឆ្នាំ ២០០៩ តែប៉ុណ្ណេះ ។

ដូច្នេះក្រោយពីរបានធ្វើសិក្សាយល់ស៊ីជម្រៅទៅលើជំពូកទី១ ស្តីពី ប្រភេទទោសព្រហ្មទណ្ឌ ឆ្នាំ ១៩០៩ និងជំពូកទី២ ស្តីពី ប្រភេទទោសព្រហ្មទណ្ឌឆ្នាំ ២០០៩ រួចមក យើងនឹងធ្វើការប្រៀបធៀបដោយទាញចេញនូវចំណុចដូចគ្នា និងចំណុចខុសគ្នាដូចមានក្នុងសេចក្តីពន្យល់នៃជំពូកទី៣ ខាងក្រោមនេះ៖

# ជំពូកទី ៣
# ការប្រៀបធៀបប្រភេទទោស

បន្ទាប់ពីយើងបានធ្វើការបកស្រាយរួចហើយ អំពីប្រភេទនៃទោសព្រហ្មទណ្ឌនៃឆ្នាំទាំងពីរ គឺ ១៩០៩ និង២០០៩ បើគិតទៅជាងមួយទស្សវត្ស (១០០ឆ្នាំ) កន្លងមកហើយ ដូច្នេះយើងអាចសិក្សាទៅលើប្រភេទនៃទោសព្រហ្មទណ្ឌដោយធ្វើការទាញយកនូវចំណុចជាច្រើន ដើម្បីយកមកធ្វើការប្រៀបធៀបគ្នា ។ បើធ្វើការពិនិត្យចំពោះការប្រៀបធៀបទៅលើប្រភេទនៃទោសព្រហ្មទណ្ឌរវាងឆ្នាំ ១៩០៩ និងឆ្នាំ ២០០៩ ត្រូវបានយកមកធ្វើការបកស្រាយនៅក្នុងជំពូកទី៣ នេះដោយធ្វើការបែងចែកជាពីរចំនុចធំៗ គឺទីមួយះយើងធ្វើការបកស្រាយទៅលើចំនុចដូចគ្នានៃប្រភេទទោស (៣.១) និងទីពីរះបកស្រាយទៅលើចំនុចខុសគ្នានៃប្រភេទទោស (៣.២) ។

## ៣.១.ចំនុចដូចគ្នានៃប្រភេទទោស

ការបកស្រាយទៅលើចំនុចដូចគ្នានៃប្រភេទទោសព្រហ្មទណ្ឌនៃឆ្នាំទាំងពីរ អាចធ្វើឡើងទៅបានដោយឆ្លងកាត់ការសិក្សា ការវិភាគ និងការពិនិត្យពិចារណាយ៉ាងស៊ីជម្រៅទៅលើការបកស្រាយទាំងឡាយ ដែលលើកឡើងអំពីប្រភេទទោសព្រហ្មទណ្ឌនៅក្នុងឆ្នាំនីមួយៗ ។ ឆ្លងកាត់ដំណាក់កាលទាំងអស់នេះយ៉ាងស៊ីជម្រៅទៅលើការបកស្រាយក្នុងជំពូកទាំងពីរ យើងអាចលើកយកនូវចំនុចមួយចំនួនដែលមានលក្ខណៈដូចគ្នា ដើម្បីយកមកធ្វើការបកស្រាយដោយបែងចែកជាចំនុចធំៗមួយចំនួនដូចជាះ រូបភាពនៃប្រភេទទោស(៣.១.១) ទម្ងន់នៃប្រភេទទោស (៣.១.២) របៀបសម្គាល់នូវប្រភេទនៃទោសចំពោះបទល្មើស (៣.១.៣) និងបុគ្គលដែលត្រូវទទួលរងនូវប្រភេទទោសជារូបវន្តបុគ្គល (៣.១.៤) ។

### ៣.១.១. រូបភាពនៃប្រភេទទោស

ការបកស្រាយទៅលើរូបភាពនៃប្រភេទទោស មានន័យថា គឺ ជាការបកស្រាយដោយលើកឡើងនូវប្រភេទទោសដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ មកធ្វើការបកស្រាយដោយប្រៀបធៀបទៅនឹងក្រមព្រហ្មទណ្ឌខេមរៈឆ្នាំ ១៩០៩ ហើយធ្វើការសន្និដ្ឋានថា ការចែងនៅក្នុងក្រមព្រហ្មទណ្ឌខេមរៈឆ្នាំ១៩០៩ គឺជារូបភាពនៃប្រភេទទោសដែលមាននៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩។ បន្ទាប់ពីបានធ្វើការសិក្សាទៅលើការបកស្រាយ នូវប្រភេទទោសនៅក្នុងឆ្នាំទាំងពីរខាងលើរួចមក យើងបានពិនិត្យឃើញនូវប្រភេទទោសចំនួនពីរ ដែលមានរូបភាពនៅក្នុងក្រមព្រហ្មទណ្ឌខេមរៈឆ្នាំ ១៩០៩ គឺមូលទោស និងទោសបន្ថែម ។

### ៣.១.១.១. រូបភាពជាមូលទោសក្នុងក្រមចាស់

ដូចជាអ្វីដែលយើងបានធ្វើការសិក្សាខាងលើរួចហើយដែរ ថាមូលទោសគឺជាប្រភេទទោសមួយដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ ហើយមូលទោសនេះត្រូវបានបែងចែកជាពីរ គឺ ទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់ ។ បើយើងធ្វើការពិនិត្យទៅលើរូបភាពនៃមូលទោសនេះនៅក្នុងក្រមព្រហ្មទណ្ឌខេមរៈឆ្នាំ ១៩០៩ គឺ យើងឃើញមាននៅក្នុងក្រមចាស់នេះ ប៉ុន្តែនៅក្នុងក្រមចាស់នេះ វាមិនត្រូវបានគេចែងឡើងដោយបញ្ជាក់ឈ្មោះថាជាមូលទោសនោះទេ គឺគ្រាន់តែមានការកំណត់ទៅលើបទល្មើសណាមួយថាត្រូវមានទោសដាក់គុក ឬពិន័យជាប្រាក់តែប៉ុណ្ណោះ ។ យើងក៏អាចពិនិត្យទៅលើរូបភាពនៃមូលទោសនេះ ដែលមានកំណត់នៅក្នុងសណ្ឋាននៃមជ្ឈិមទោស គឺ ការដាក់គុក (សណ្ឋាន ១) និង ការពិន័យ (សណ្ឋាន ៣)[80] ។

ដោយសារតែនៅក្នុងក្រមចាស់មិនបានធ្វើការកំណត់ឱ្យបានច្បាស់លាស់ ហេតុនេះហើយទើបយើងទាញការកំណត់នេះជារូបភាព ដែលបានបន្តជាមូលដ្ឋានសម្រាប់ការចែងជាបទបញ្ញត្តិនៅក្នុងក្រមថ្មីតែម្តង ។

បន្ទាប់ពីបានធ្វើការបកស្រាយទៅលើ រូបភាពនៃមូលទោសរួចហើយ ជាបន្តទៅទៀតនេះ យើងសូមលើកយកនូវរូបភាពនៃទោសបន្ថែមមកបកស្រាយបង្ហាញវិញម្តង ព្រោះវាក៏មានរូបភាពខ្លះៗនៅក្នុងក្រមព្រហ្មទណ្ឌចាស់ដែរ ។

### ៣.១.១.២. រូបភាពជាទោសបន្ថែមក្នុងក្រមចាស់

បើយោងទៅតាមក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ ទោសបន្ថែមសំដៅទៅលើទោសដែលត្រូវបានគេប្រើសម្រាប់ដាក់បន្ថែមទៅលើមូលទោសដែលមានស្រាប់ ។ ចំពោះរូបភាពនៃទោសបន្ថែមនេះ បើយើងពិនិត្យមើលនៅក្នុងក្រមព្រហ្មទណ្ឌខេមរៈឆ្នាំ ១៩០៩ គឺមានការកំណត់មួយចំនួនដែលមានលក្ខណៈដូចទៅនឹងប្រភេទនៃទោសបន្ថែមមួយចំនួន ក្នុងចំណោមប្រភេទនៃទោសបន្ថែមដែលមានចែងក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ ក្នុងនោះមានដូចជាៈ **ការដកសិទ្ធិខ្លះជាពលរដ្ឋ ការហាមឃាត់ចំពោះការស្នាក់នៅ ការហាមឃាត់ចំពោះការចូល និងការស្នាក់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជាចំពោះទណ្ឌិតដែលជាជនបរទេស ការរឹបអូស** និង**ការបិទផ្សាយសេចក្តីសម្រេច** ។

#### ក. ការដកសិទ្ធិខ្លះជាពលរដ្ឋ

ការដកសិទ្ធិខ្លះជាពលរដ្ឋ គឺជាប្រភេទនៃទោសបន្ថែមដែលមានចែងនៅក្នុងមាត្រា ៥៣ ចំណុច១ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ ។ នៅក្នុងការដកសិទ្ធិខ្លះជាពលរដ្ឋនេះ មានការកំណត់

[80] មាត្រា ៧ នៃក្រមព្រហ្មទណ្ឌខេមរៈ ចុះថ្ងៃទី ៨ ខែ មេសា ឆ្នាំ ១៩០៩

យ៉ាងច្បាស់លាស់នូវសិទ្ធិជាច្រើនដែលត្រូវបានដកដោយអំណាចសាធារណៈចំពោះទណ្ឌិត ប៉ុន្តែនៅក្នុងការបកស្រាយអំពីរូបភាពនៃទោសបន្ថែម ដែលតម្រូវឱ្យមានការលើកឡើងដោយធ្វើការប្រៀបធៀបទៅនឹងក្រមព្រហ្មទណ្ឌខេមរៈឆ្នាំ ១៩០៩ ហេតុនេះហើយយើងសូមលើកយកនូវសិទ្ធិខ្លះដែលមានលក្ខណៈប្រហាក់ប្រហែលគ្នាទៅនឹងសិទ្ធិមួយចំនួន ដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌខេមរៈឆ្នាំ ១៩០៩ ។

ការដកសិទ្ធិខ្លះជាពលរដ្ឋ ឬសិទ្ធិពលរដ្ឋដែលអាចដកបាន ដែលត្រូវលើកយកមកបកស្រាយក្នុងចំនុចនោះមានដូចជា៖

- សិទ្ធិបំពេញការងារជាមន្ត្រីក្របខ័ណ្ឌមុខងារសាធារណៈ
- សិទ្ធិទទួល និងពាក់គ្រឿងឥស្សរិយយសទាំងអស់
- សិទ្ធិដែលធ្វើជាសាក្សីដែលទទួលសម្បថនៅមុខតុលាការ[81]

បើយើងធ្វើការពិនិត្យទៅលើរូបភាពនៃប្រភេទទោសបន្ថែមមួយនេះ គឺ ក៏ធ្លាប់បានចែងនៅក្នុងក្រមព្រហ្មទណ្ឌខេមរៈឆ្នាំ ១៩០៩ ផងដែរ ។ ប៉ុន្តែនៅក្នុងក្រមព្រហ្មទណ្ឌខេមរៈឆ្នាំ ១៩០៩ វិញសិទ្ធិដែលមានកំណត់ខាងលើ គឺត្រូវបានកំណត់នៅក្នុងទោសដែលចែងអំពីការបន្ថយអំណាចយសស័ក្តិ។

ចំពោះទោសបន្ថយអំណាចយសស័ក្តិនេះ ក៏មានកំណត់នូវប្រភេទនៃអំណាចយសស័ក្តិច្រើនដែរ ប៉ុន្តែយើងសូមលើកយកនូវចំនុចមួយចំនួនមកធ្វើការប្រៀបធៀបទៅនឹងការលើកឡើងខាងលើតែប៉ុណ្ណោះ ។ ចំពោះទោសបន្ថយអំណាចយសស័ក្តិ ដែលត្រូវលើកយកមកប្រៀបធៀបនេះមានលក្ខណៈដូចខាងក្រោម៖

- មិនឱ្យមនុស្សដែលបានត្រូវទោសនោះធ្វើជារាជការធំតូច ជាតំណាងប្រយោជន៍ជនានុជន ឬធ្វើយសស័ក្តិអ្វី ។
- មិនឱ្យមានអំណាចពាក់គ្រឿងឥស្សរិយយស ។
- មិនឱ្យមានអំណាចធ្វើជាស្មរក្សីនសាក្សី ក្នុងសេចក្តីដល់តុលាការ តែបើតុលាការត្រូវការ នឹងយកមកសួរជាដំណឹងបំភ្លឺតុលាការបាន[82] ។

លក្ខណៈទាំងអស់ដែលលើកឡើងខាងលើនេះ គឺជាលក្ខណៈមួយចំនួនក្នុងចំណោមលក្ខណៈនៃទោសបន្ថយអំណាចយសស័ក្តិ ដែលមានដូចទៅនឹងប្រភេទនៃសិទ្ធិមួយចំនួនក្នុងចំណោមប្រភេទនៃសិទ្ធិជាច្រើនដែលមានចែងក្នុងសិទ្ធិពលរដ្ឋដែលអាចដកបាន ដែលជាប្រភេទទោសបន្ថែមមួយក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ ។

[81] មាត្រា ៥៥ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩

[82] មាត្រា ២៨ នៃក្រមព្រហ្មទណ្ឌខេមរៈ ចុះថ្ងៃទី ៨ ខែ មេសា ឆ្នាំ ១៩០៩

**ខ. ការហាមឃាត់ចំពោះការស្នាក់នៅ**

ការហាមឃាត់ចំពោះការស្នាក់នៅ គឺសំដៅទៅលើការហាមឃាត់ចំពោះទណ្ឌិត មិនឱ្យមានមុខនៅទីកន្លែងខ្លះលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។ ទោសនេះ មិនអាចលើសពី ១០ (ដប់) ឆ្នាំ ចំពោះបទឧក្រិដ្ឋ និង ៥ (ប្រាំ) ឆ្នាំ ចំពោះ បទមជ្ឈិម ។ តុលាការកំណត់បញ្ជីនៃទីកន្លែងដែលហាមឃាត់និងកំណត់ថិរវេលានៃការហាមឃាត់។ ការហាមឃាត់ការស្នាក់នៅរួមមានវិធានការតាមដាន។ ទណ្ឌិតត្រូវតែ ៖

១-ចូលបង្ហាញខ្លួនតាមដីកាកោះរបស់អាជ្ញាធរតុលាការឬរដ្ឋបាល ដែលតុលាការបានចាត់តាំង។

២-ចូលបង្ហាញខ្លួនឱ្យបានទៀងទាត់តាមការកំណត់នៅស្នាក់ការនគរបាល ឬ កងរាជអាវុធហត្ថតាមការចាត់តាំងរបស់តុលាការ។

តុលាការត្រូវកំណត់បែបបទនៃវិធានការតាមដាន។

សេចក្ដីសម្រេចរបស់តុលាការ ត្រូវជូនដំណឹងដោយព្រះរាជអាជ្ញា ដល់ក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ ក្នុងគោលបំណងសុំឱ្យមាន កិច្ចសហប្រតិបត្តិការជាមួយតុលាការ[83]។

<u>ឧទាហរណ៍</u> ៖ ជនម្នាក់ គាត់ជាយោធិនខ្មែរ គាត់បានប្រព្រឹត្តអំពើក្បត់ជាតិ យោងតាមមាត្រា ៤៣៩ និងមាត្រា ៤៤៨ បទផ្ដល់ព័ត៌មានមិនពិត ពីព្រោះ គាត់កំពុងរស់នៅក្នុងមូលដ្ឋាន នៃកងយោធពលខេមរភូមិន្ទ តែគាត់បែរជា ទៅផ្ដល់ដល់អាជ្ញាធរស៊ីវិល ឬយោធាខ្មែរ នូវព័ត៌មានមិនពិតដែលអាចធ្វើឱ្យ អន្តរាយដល់ការការពារជាតិដើម្បីបម្រើផលប្រយោជន៍ឱ្យរដ្ឋបរទេស ។ ដូច្នេះ ចៅក្រម អាចផ្ដន្ទាទោសបន្ថែមដល់គាត់ដោយហាមឃាត់មិនឱ្យចូលទៅស្នាក់នៅក្នុងមូលដ្ឋាននៃកងទ័ពខ្មែរសម្រាប់រយៈពេល ១០ (ដប់) ឆ្នាំជាដើមនេះបើផ្អែកតាមមាត្រា ៤៥០ ស្ដីពីទោសបន្ថែម ។

ចំពោះការចែងនៅក្នុងក្រមព្រហ្មទណ្ឌខេមរៈឆ្នាំ ១៩០៩ ក៏មានការកំណត់នូវការហាមឃាត់ទៅលើទណ្ឌិតមិនឱ្យមានមុខនៅកន្លែងខ្លះនៅលើដែនដីនៃព្រះរាជណាចក្រកម្ពុជា ប៉ុន្តែមិនមានលក្ខណៈដូចគ្នាទាំងស្រុងទេ ។ នៅក្នុងការបកស្រាយប្រៀបធៀបទៅលើការហាមឃាត់ចំពោះការស្នាក់នៅនេះ ក្នុងក្រមព្រហ្មទណ្ឌខេមរៈឆ្នាំ ១៩០៩ ក៏មានការកំណត់ផងដែរថា៖

«បើកាត់ទោសដាក់គុកឱ្យធ្វើការជាទម្ងន់មានកំណត់នេះ ១ ទោសដាក់គុកឱ្យនៅដោយពួកនេះ ១ ទោសដាក់គុកបង្ខាំងឱ្យនៅតែម្នាក់ឯងនេះ ១ និង*បញ្ញត្តិកុំឱ្យមនុស្សទោសទៅណាមកឯទី*

[83] មាត្រា ៥៩ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩

*កន្លែងណា ដែលរាជការហាមឃាត់មិនឱ្យទៅណាក៏បាន* ។ ឯការហាមឃាត់ រាជការនឹងប្រាប់ឱ្យដឹងមុន វេលាដែលនឹងរួចពីទោស ។»[84]

«រីទោសហាមឃាត់មិនឱ្យទៅទីកន្លែងណាមួយនោះ ទោះសណ្ឋានធ្ងន់ ស្រាលដូចម្ដេចក្ដី នឹងកាត់ឱ្យលើសពី ២០ (ម្ភៃ) ឆ្នាំពុំបាន ។

ឯសាលក្រមកាត់ទោសនោះ នឹងបន្ថយកំណត់ទោសនេះពី ២០ (ម្ភៃ) ឆ្នាំ ឬនឹងកាត់ថា មិនត្រូវហាមក៏បាន ។»[85]

**គ. ការហាមឃាត់ចំពោះការចូលនិងការស្នាក់នៅលើដែនដី នៃព្រះរាជាណាចក្រកម្ពុជាចំពោះទណ្ឌិតដែលជាជនបរទេស**

ការហាមឃាត់ដល់ទណ្ឌិតបរទេសចំពោះការចូល និងការស្នាក់នៅ ក្នុងដែនដី នៃព្រះរាជាណាចក្រកម្ពុជា អាចជាស្ថាពរ ឬជាបណ្ដោះអាសន្ន សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងច្រើន ។ ការហាមឃាត់នេះនាំឱ្យមាន ការបណ្ដេញទណ្ឌិត ឱ្យចេញដោយពេញច្បាប់ នៅពេលបញ្ចប់ទោសដាក់ពន្ធនាគារ ។[86]

<u>ឧទាហរណ៍</u> ៖ ដើម្បីងាយយល់ ព្រោះនេះវាអាចមានលក្ខណៈជាក់ស្ដែងច្រើន ដោយសារតែការអនុវត្តបច្ចុប្បន្ន គឺដូចជា មានជនបរទេសម្នាក់ចូលមកដល់ ប្រទេសកម្ពុជាគាត់ ក៏ប្រព្រឹត្តបទល្មើសមួយចំនួន គឺគាត់អាចចាប់គេរំលោភ ឬគាត់ប្រព្រឹត្តអំពើឆបោក ។ អញ្ចឹងតុលាការ ឬ ចៅក្រម បន្ថែមទៅលើ ទោសដាក់ពន្ធនាគារ បើករណីគាត់សម្រេចផ្ដន្ទាទោសដាក់ពន្ធនាគាររួចហើយ គាត់អាចជ្រើសយកទោសមួយទៀត គេឱ្យឈ្មោះថាទោសបន្ថែមដែលមាន ចែងនៅក្នុងចំណុចទី ៧ នៃមាត្រា ៥៣ ដូចបានសរសេរបង្ហាញរួចហើយ ។ ដូច្នេះ នៅពេលដែលចៅក្រម គាត់សម្រេចបន្ថែមទោសបន្ថែមនេះទៅលើ មូលទោសទៀត នៅក្នុងករណីហ្នឹង ក្រោយពេលជននោះគាត់អនុវត្តទោស របស់ខ្លួនចប់សព្វគ្រប់នៅក្នុងពន្ធនាគាររួចហើយ ជនបរទេសនោះនឹងត្រូវបានគេបណ្ដេញចេញដោយស្វ័យប្រវត្តិពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។ ហេតុដូច្នេះ ទោសបន្ថែមគឺបន្ថែមទៅលើមូលទោសដែលមូលទោស ដូចជា ទោសដាក់ពន្ធនាគារ គាត់កំពុងតែអនុវត្តទោសនៅក្នុងពន្ធនាគារ ប៉ុន្តែពេលចប់គឺពេលដែលគាត់ចាកចេញពីពន្ធនាគារ គេនឹងបណ្ដេញគាត់ដោយបញ្ជូនទៅតាមយន្តហោះ ឬមធ្យោបាយណាមួយទៀត ដើម្បីឱ្យគាត់ចេញឱ្យឆ្ងាយ ពីដែនដីនៃព្រះរាជាណាចក្រកម្ពុជាដោយពេញច្បាប់ ហើយបែបបទទាំងអស់នេះមានចែងកំណត់អំពីការបណ្ដេញចេញអីទាំងអស់នៅ

[84] មាត្រា ៣៥ នៃក្រមព្រហ្មទណ្ឌខេមរៈ ចុះថ្ងៃទី ៨ ខែ មេសា ឆ្នាំ ១៩០៩

[85] មាត្រា ៣៦ នៃក្រមព្រហ្មទណ្ឌខេមរៈ ចុះថ្ងៃទី ៨ ខែ មេសា ឆ្នាំ ១៩០៩

[86] មាត្រា ៦១ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩

ក្នុងចំណុចទី ៧ នៃ មាត្រា ៥៣ គឺវាទាក់ទងទៅនឹងបទបញ្ញត្តិមាត្រា ៦១ នៃក្រមព្រហ្មទណ្ឌ ។ មាត្រា ៦១ កំណត់តែម្តងថា បើតុលាការគាត់ជ្រើសរើសយកទោសបន្ថែម បែបហ្នឹងហើយ គឺបន្ទាប់ពីអនុវត្តទោសដាក់ពន្ធនាគារគាត់រួចរាល់ហើយនោះ ជនបរទេសនេះត្រូវបណ្តេញចេញពីព្រះរាជាណាចក្រកម្ពុជាដោយពេញច្បាប់។

ចំណែកនៅក្នុងក្រមព្រហ្មទណ្ឌខេមរៈឆ្នាំ ១៩០៩ វិញក៏មានការចែងចំពោះការហាមឃាត់មិនឱ្យស្នាក់នៅក្នុងដែនដីកម្ពុជាចំពោះទណ្ឌិតដែលជាជនបរទេសដែរ ។ ការចែងនេះមាននៅក្នុងមាត្រា ២០០ ដែលបានចែងថា «ទោះមនុស្សប្រទេសក្រៅ មកនៅក្នុងក្រុងកម្ពុជា តុលាការស្គាល់ជាក់ពិតប្រាកដជាអនាថា នោះបើដល់វេលា ដែលវាគ្រប់កំណត់រួចពីទោសហើយរាជការត្រូវបណ្តេញចេញឱ្យទៅនៅក្រៅពីអាណាខេត្តដែនខ្មែរ ។»

**ឃ. ការរឹបអូស**

ការរឹបអូស មានន័យថា ការដកហូតជាអចិន្ត្រៃយ៍នូវទ្រព្យសម្បត្តិណាមួយ តាមរយៈសេចក្តីសម្រេចរបស់តុលាការ[87]។

**<u>គួរកត់សម្គាល់</u>** ៖ នៅពេលដែលតុលាការផ្តន្ទាទោសបន្ថែមទៀតរួចហើយ ប្រសិនបើបំពានទៅលើសេចក្តីសម្រេចរបស់តុលាការ មានបទល្មើសមួយឈ្មោះថា "បទមិនគោរពការរឹបអូស" ដែលមាត្រា ៥៨១ បានចែងយ៉ាងច្បាស់ថាអំពើ បំផ្លិចបំផ្លាញ លាក់បំបាំង ឬតែបំបាត់វត្ថុរឹបអូសត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ១ (មួយ) ឆ្នាំទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀលទៅ ៤.០០០.០០០ (បួនលាន) រៀល។

ប៉ុន្តែការរឹបអូស មិនអាចប្រកាសបានទេ ប្រសិនបើមានការប៉ះពាល់ដល់ សិទ្ធិរបស់តតិយជន[88]។

<u>ឧទាហរណ៍</u> ៖ មិត្តភក្តិយើងបានខ្ចីម៉ូតូទៅប្រព្រឹត្តបទល្មើស ដែលយើងមិន បានដឹងខ្លួននោះទេ និងថែមទាំងមិនបានចូលរួមនៅក្នុងបទល្មើសនោះទៀត ផងដែរ។ ដូច្នេះតុលាការមិនអាចរឹបអូសម៉ូតូដែលជាទ្រព្យសម្បត្តិរបស់យើង ដែលជាតតិយជននោះឡើយ ព្រោះយើងអត់មានកំហុសទេ។ ម្យ៉ាងវិញទៀត កាលបើការរឹបអូសបានក្លាយទៅជាស្ថាពរ ទ្រព្យសម្បត្តិរឹបអូស ក្លាយទៅជាកម្មសិទ្ធិរបស់រដ្ឋ លើកលែងតែមានបទប្បញ្ញត្តិដោយឡែកដែលចែងអំពីការ ប្រគល់ផ្សេងពីនេះ។ ហើយរដ្ឋអាចលក់ឬបំផ្លាញទ្រព្យរឹបអូសតាមនីតិវិធីស្តីពី ការលក់ទ្រព្យសម្បត្តិរដ្ឋ(សូមរកនីតិវិធីនេះមកអានបន្ថែមដោយក្តីអនុគ្រោះ)។

---

[87] មាត្រា ៤ កថាខណ្ឌទី ១៤ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ចុះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០១០

[88] មាត្រា ៦២ ឃ្លាចុងក្រោយបង្អស់ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ស្តីពី "ការរឹបអូស"

- ការរឹបអូសឧបករណ៍ សម្ភារៈ ឬ វត្ថុដែលប្រើប្រាស់ក្នុងពេល ប្រព្រឹត្តបទល្មើស ឬ ដែលទុកសម្រាប់ប្រព្រឹត្តបទល្មើស
- ការរឹបអូសវត្ថុឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស
- ការរឹបអូសផលទុនឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស
- ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬ ចលនវត្ថុ ដែលលំអទីកន្លែង ដែលបទល្មើស ត្រូវបានប្រព្រឹត្ត
- ការរឹបអូសយានជំនិះដែលជារបស់ទណ្ឌិត

បើយើងធ្វើការពិនិត្យនៅក្នុងក្រមព្រហ្មទណ្ឌខេមរៈឆ្នាំ ១៩០៩ ក៏មានចែងអំពីការរឹបអូសនេះដែរ ប៉ុន្តែមិនបានធ្វើការបែងចែកឱ្យបានច្បាស់លាស់ដូចការបកស្រាយខាងលើនោះទេ ។ ការកំណត់ចំពោះការរឹបអូសក្នុងក្រមព្រហ្មទណ្ឌខេមរៈឆ្នាំ ១៩០៩ នេះ មានដូចជាៈ គឺ***ឱ្យរឹបយកគ្រឿងសាត្រាវុធ ដែលយកទៅប្រើការធ្វើឱ្យកើតឡើងជាអំពើទុច្ចរិត ១ តែគ្រឿងនោះជារបស់ផងវា ឬក៏របស់សព្វសារពើ ដែលកើតពីអំពើទុច្ចរិតនោះ ១ ឬគ្រឿងរបស់អ្វីនីមួយ ដែលសម្រាប់យកទៅធ្វើអាការទុច្ចរិតនេះ ១***[89] ។ ថ្វីត្បិតតែនៅក្នុងក្រមនេះមិនបានធ្វើការបែងចែកឱ្យបានច្បាស់ និងដាច់ៗពីគ្នាដែលធ្វើឱ្យយើងពិបាកយល់ក៏ដោយ ក៏អត្ថន័យទាំងអស់ដែលពាក់ព័ន្ធទៅនឹងការរឹបអូសដូចការបកស្រាយខាងលើ គឺស្ថិតនៅក្នុងមាត្រា ៩ ប្រការ ៣ នៃក្រមនេះទាំងអស់ ។

**ខ. ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស**

ការបិទផ្សាយអំពីសេចក្តីសម្រេចផ្តន្ទាទោសរបស់តុលាការចំពោះបុគ្គលណាម្នាក់ ដែលបានប្រព្រឹត្តបទល្មើស មានគោលបំណងដើម្បីប្រកាសឱ្យសាធារណៈជនបានដឹងអំពីទោសកំហុសរបស់បុគ្គលនោះ ហើយវានេះក៏ជាទណ្ឌកម្មមួយដែលបន្ថែមទៅលើមូលទោសដែលត្រូវបានប្រកាសរួចហើយ ។

នៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ មានការចែងអំពីទណ្ឌកម្មមួយនេះ ដែលយើងហៅថាជាទោសបន្ថែមដែលចៅក្រមអាចប្រកាសដើម្បីបន្ថែមទៅលើបុគ្គលដែលប្រព្រឹត្តបទល្មើសផងដែរ ។ នៅក្នុងក្រមនេះបានរៀបរាប់អំពីការអនុវត្តទោសនេះ ដោយលើកឡើងថា «ទោសបិទផ្សាយសេចក្តីសម្រេច ត្រូវអនុវត្តនៅទីកន្លែងដែលចង្អុលបង្ហាញដោយតុលាការ និងក្នុងរយៈពេលមួយ ដែល

[89] មាត្រា ៩ ប្រការ ៣ នៃក្រមព្រហ្មទណ្ឌខេមរៈ ចុះថ្ងៃទី ៨ ខែ មេសា ឆ្នាំ ១៩០៩

កំណត់ដោយតុលាការ ។ ការបិទផ្សាយមិនអាចលើសពី ២ (ពីរ) ខែទេ ។ ការបិទផ្សាយអាចធ្វើទាំងស្រុង ឬតាមសម្រង់ឬតាមនិទ្ទេសធម្មតា ។ សោហ៊ុយបិទផ្សាយគឺជាបន្ទុករបស់ទណ្ឌិត។[90]»

ចំពោះក្រមព្រហ្មទណ្ឌខេមរៈឆ្នាំ ១៩០៩ វិញក៏មានកំណត់អំពីការបិទផ្សាយនូវសេចក្តីសម្រេចរបស់តុលាការនេះផងដែរ ដោយលើកឡើងថា « សេចក្តីស្រង់ពីសាលក្រមនោះ ត្រូវបិទនៅភូមិដែលធ្វើសាលក្រមនេះ ១ នៅទីកន្លែងដែលកើតហេតុនេះ ១ នៅទីកន្លែងដែលពិឃាដនេះ ១ នៅទីកន្លែងមនុស្សទោសនៅនោះ ១ ។[91]»

យោងតាមការលើកឡើងខាងលើ យើងសង្កេតឃើញថានៅក្នុងក្រមទាំងពីរ គឺសុទ្ធតែមានចែងអំពីការបិទផ្សាយនូវសេចក្តីសម្រេចផ្តន្ទាទោសដូចគ្នា ប៉ុន្តែនៅក្នុងក្រមចាស់ ការកំណត់អំពីការអនុវត្តនូវទោសមួយនេះដោយមានការបញ្ជាក់នូវទីតាំងនៃការបិទផ្សាយច្បាស់លាស់ ចំណែកឯនៅក្នុងក្រមថ្មីវិញពុំមានចែងបញ្ជាក់ដូចគ្នានេះទេ ។ បើទោះបីជាការចែងអំពីការអនុវត្តនូវទោសមួយនេះមានលក្ខណៈខុសគ្នាបន្តិចរវាងក្រមទាំងពីរនេះ ប៉ុន្តែការលើកឡើងនេះក្នុងគោលបំណងដើម្បីបង្ហាញថាការកំណត់នៅក្នុងក្រមចាស់ គឺ ជារូបភាពដែលបន្សល់ឱ្យមានការចែងនៅក្នុងក្រមថ្មីផងដែរ ។

### ៣.១.២. ទម្ងន់នៃប្រភេទទោស

នៅក្នុងការបកស្រាយទៅលើទម្ងន់នៃប្រភេទទោស គឺ យើងនឹងធ្វើការបកស្រាយដោយស្ថិតនៅក្នុងរង្វង់មួយដែលលើកឡើងតាមរយៈទ្រឹស្តី ដោយពឹងផ្អែកទាំងស្រុងទៅលើការពន្យល់ចំពោះកម្រិតនៃទោសនីមួយៗ។ ចំពោះកម្រិតនៃទោសនីមួយៗធ្ងន់ មធ្យម ឬ ស្រាលវាអាស្រ័យទៅលើផលប៉ះពាល់ដែលកើតចេញពីបទល្មើសបំពានសណ្តាប់ធ្នាប់សាធារណៈ ។

#### ៣.១.២.១. ទម្ងន់នៃទោសឧក្រិដ្ឋ

ទោសឧក្រិដ្ឋ គឺជាទោសមួយប្រភេទដែលមានកម្រិតធ្ងន់ធ្ងរបំផុត ដែលមានចែងក្នុងបញ្ញត្តិស្តីពីបទល្មើសឧក្រិដ្ឋ សម្រាប់ដាក់ទៅលើទណ្ឌិត ។ ការលើកឡើងថាទោសឧក្រិដ្ឋមានកម្រិតធ្ងន់ធ្ងរបំផុតនេះ ដោយផ្អែកទៅលើផលប៉ះពាល់ដែលកើតចេញពីបទល្មើសចំពោះសណ្តាប់ធ្នាប់សាធារណៈ ហើយបទល្មើសនេះបានជះឥទ្ធិពលអាក្រក់ដល់សង្គម ជាពិសេសទៅទៀតនោះ ឥទ្ធិពលអាក្រក់នេះមិនងាយនឹងសាបរលាបក្នុងរយៈពេលដ៏ខ្លីនោះទេ។

[90] មាត្រា ៦៨ កថាខ័ណ្ឌទី១ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកាឆ្នាំ ២០០៩
[91] មាត្រា ៣១ នៃក្រមព្រហ្មទណ្ឌខេមរៈ ចុះថ្ងៃទី ៨ ខែ មេសា ឆ្នាំ ១៩០៩

ចំពោះទម្ងន់នៃទោសឧក្រិដ្ឋនេះ យើងអាចពិនិត្យមើលឃើញភាពដូចគ្នារវាងក្រមទាំងពីរបាន ដោយសង្កេតទៅលើការកំណត់អំពីការដាក់ទណ្ឌកម្ម ។ ការដាក់ទណ្ឌកម្មដែលមានទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់ ប៉ុន្តែចំពោះទោសឧក្រិដ្ឋនៅក្នុងក្រមទាំងពីរមានតែការកំណត់អំពីទោសដាក់ពន្ធនាគារ ពុំមានទោសពិន័យជាប្រាក់ទេ ដោយសារតែស្ថានទម្ងន់នៃទោសឧក្រិដ្ឋមានលក្ខណៈធ្ងន់ធ្ងរ ហេតុនេះហើយការដាក់ទោសពន្ធនាគារគឺ គ្រប់គ្រាន់ហើយ បើយើងបន្ថែមទោសពិន័យជាប្រាក់ទៀត គឺ វាធ្វើឱ្យទណ្ឌិតកាន់តែទទួលទោសកាន់តែធ្ងន់ទៅៗ ។

**៣.១.២.២. ទម្ងន់នៃទោសមជ្ឈិម**

ទោសមជ្ឈិម គឺជាប្រភេទនៃទោសមួយដែលមានទណ្ឌកម្មមធ្យម ឬនៅកណ្តាលហើយមានលក្ខណៈស្រាលជាងទោសឧក្រិដ្ឋ ឬធ្ងន់ជាងទោសលហុ ។ មិនខុសពីការបកស្រាយទៅលើទម្ងន់នៃទោសឧក្រិដ្ឋដែរ ទម្ងន់នៃទោសមជ្ឈិមក៏ត្រូវការពិនិត្យទៅលើ ផលប៉ះពាល់នៃបទល្មើសដែលកើតឡើងចំពោះសង្គម ប៉ុន្តែវាមានលក្ខណៈស្រាលជាងទោសឧក្រិដ្ឋ ហើយឥទ្ធិពលរបស់វាអាចសាបរលាបក្នុងរយៈពេលខ្លីជាងទោសឧក្រិដ្ឋផងដែរ ។

ទម្ងន់នៃទោសមជ្ឈិមនេះ នៅក្នុងក្រមទាំងពីរ មិនត្រឹមតែដូចគ្នាចំពោះកម្រិតទម្ងន់នៃទោសនេះទេ លើសពីនេះទៅទៀតការដាក់ទណ្ឌកម្មក៏មានលក្ខណៈដូចគ្នាផងដែរ ។ ការដាក់ទណ្ឌនៅក្នុងក្រមទាំងពីរចំពោះទោសមជ្ឈិម គឺមានការដាក់ពន្ធនគារ និងការពិន័យជាប្រាក់ ។

**៣.១.២.៣. ទម្ងន់នៃទោសលហុ**

ទោសលហុ គឺ ជាទោសមួយប្រភេទ ដែលមានលក្ខណៈស្រាលជាងគេក្នុងចំណោមប្រភេទនៃទោសទាំងអស់គឺស្រាលជាងទោសឧក្រិដ្ឋ និងទោសមជ្ឈិមទៅទៀត ។ទម្ងន់នៃទោសលហុ ដែលមានលក្ខណៈស្រាលជាងប្រភេទទោសផ្សេងទៀត ក៏ព្រោះតែទម្ងន់នៃផលប៉ះពាល់របស់បទល្មើសលហុវាមានកម្រិតស្រាលជាងប្រភេទទោសទាំងពីរខាងលើ ហើយការបាត់បង់នូវឥទ្ធិពលរបស់វាក៏មានរយៈពេលលឿនជាងគេដែរ ។ ម្យ៉ាងមនុស្សងាយនឹងធ្លាក់ជ្រុលខ្លួនប្រព្រឹត្តបទលហុនេះណាស់អាចកើតញឹកញាប់ក៏ថាបាន ។ដូច្នេះបើទោសលហុ កំណត់ដាក់ទោសធ្ងន់ពេកក៏មិនកើតដែរ ។

ចំពោះទោសលហុទម្ងន់របស់ស្រាលជាងគេ ហើយនៅក្នុងក្រមទាំងពីរក៏បានកំណត់អំពីការដាក់ទណ្ឌកម្មចំនួនពីរដែរ គឺ ការដាក់ពន្ធនាគារ និងការពិន័យជាប្រាក់ ។ បើទោះជាមានការកំណត់ដូច្នេះក៏ដោយ ទោសលហុអាចធ្វើការដាក់ទណ្ឌកម្មត្រឹមតែការដាក់ពន្ធនាគារ ឬ ការពិន័យជាប្រាក់ក៏បានដែរ ឬពេលខ្លះអាចពិន័យជាប្រាក់តែមួយមុខក៏មានដែរ ។

### ៣.១.៣. របៀបសម្គាល់នូវប្រភេទនៃទោសចំពោះបទល្មើស

ក្រមព្រហ្មទណ្ឌខេមរៈឆ្នាំ ១៩០៩ និង ឆ្នាំ ២០០៩ បានធ្វើការកំណត់ថា ទោសដែលត្រូវដាក់ទៅលើបទល្មើសត្រូវបានបែងចែកជា ០៣ ប្រភេទ គឺទោសឧក្រិដ្ឋ ទោសមជ្ឈិម និងទោសលហុ ។ ក៏ប៉ុន្តែចំណុចសំខាន់ គឺ របៀបសម្គាល់ថា តើយើងសម្គាល់ទោសណាមួយនោះជាទោសឧក្រិដ្ឋ ជាទោសមជ្ឈិម ឬជាទោសលហុយ៉ាងដូចម្តេច? ដើម្បីអាចសម្គាល់ថាទោសមួយនោះ គឺជាទោសឧក្រិដ្ឋ ជាទោសមជ្ឈិម ជាទោសលហុយ៉ាងម៉េចនោះ គោងយើងពិនិត្យមើលទៅលើ**មូលទោស**នេះឯង។

បើទោះបីជានៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ ពុំបានចែងច្បាស់លាស់អំពីលក្ខណៈសម្គាល់នៃទោសក៏ដោយ ប៉ុន្តែបានចែងអំពីលក្ខណៈសម្គាល់នៃបទល្មើស ហើយទោសដែលបានកំណត់សម្រាប់ដាក់ទៅលើបទល្មើសណាមួយ គឺជាទោសនោះហើយ ។

ឧទាហរណ៍៖ ចំពោះក្នុងបទល្មើសឧក្រិដ្ឋ នៅក្នុងបទល្មើសឧក្រិដ្ឋនោះមានការកំណត់នូវទោសសម្រាប់ដាក់ទណ្ឌកម្មទៅលើទណ្ឌិត ហេតុដូច្នេះទោសដែលត្រូវដាក់សម្រាប់បទល្មើសណាមួយដែលស្ថិតនៅក្នុងប្រភេទនៃបទល្មើសឧក្រិដ្ឋនេះ គឺ ជាទោសឧក្រិដ្ឋតែម្តង ។ ហេតុនេះហើយដើម្បីធ្វើការបកស្រាយឱ្យឃើញនូវលក្ខណៈសម្គាល់នៃទោសនីមួយៗ យើងត្រូវធ្វើការបកស្រាយតាមរយៈលក្ខណៈសម្គាល់នៃបទល្មើសនីមួយៗនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ នេះ ។

ប៉ុន្តែបើយើងក្រឡេកមើលការចែងនៅក្នុងក្រមព្រហ្មទណ្ឌខេមរៈឆ្នាំ ១៩០៩ គឺ ពុំមានចែងអំពីលក្ខណៈសម្គាល់នៃបទល្មើសទេ មានតែការចែងអំពីលក្ខណៈសម្គាល់នៃទោសនីមួយៗ ដែលមានគឺទោសឧក្រិដ្ឋ ទោសមជ្ឈិម និងទោសលហុ ហេតុដូច្នេះហើយ យើងមិនពិបាកក្នុងការបកស្រាយអំពីលក្ខណៈសម្គាល់នៃទោស តាមរយៈបទល្មើសទេ យើងលើកយកនូវមាត្រា ដែលបញ្ជាក់អំពីលក្ខណៈសម្គាល់នៃទោសមកធ្វើការបកស្រាយតែម្តង ។

សូមបញ្ជាក់ជូនជារួមតែម្តងថា ដើម្បីអាចស្គាល់ថាជា ទោសឧក្រិដ្ឋ ឬជា ទោសមជ្ឈិម ឬក៏ជាទោសលហុ នោះគឺក្រៅពីបានស្គាល់អំពីកម្រិតនេះរួចហើយ យើងត្រូវធ្វើការកត់សម្គាល់ថា ច្បាប់កំណត់ជ្រើសរើសយកត្រឹមតែអតិបរមានៃទោសដាក់ពន្ធនាគារប៉ុណ្ណោះ គឺមានន័យថា យើងត្រូវមើលតែទៅលើអតិបរមានៃទោស ដែលមានចែងនៅក្នុងច្បាប់ដើម្បីស្គាល់បានថា ជាទោសឧក្រិដ្ឋ ឬជាទោសមជ្ឈិម ឬជាទោសលហុ ។ បន្តទៅមុខទៀត យើងនឹងលើកបង្ហាញដើម្បី រំលេចជូនអំពីស្ថានភាពទាំងនេះដូចខាងក្រោម ៖

### ៣.១.៣.១. លក្ខណៈសម្គាល់នៃទោសឧក្រិដ្ឋ

ទោសឧក្រិដ្ឋនេះ ត្រូវបានសម្គាល់តាមរយៈការបកស្រាយអំពីលក្ខណៈសម្គាល់នៃបទល្មើសឧក្រិដ្ឋ។

បទឧក្រិដ្ឋ គឺជាបទល្មើសដែលមានទណ្ឌកម្មធ្ងន់ធ្ងរបំផុត។ បទល្មើសនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារមានរយៈពេលលើសពី ៥ (ប្រាំ) ឆ្នាំ និងក្រោម ឬស្មើនឹង ៣០ (សាមសិប) ឆ្នាំ ឬដាក់ពន្ធនាគារអស់មួយជីវិត[92]។

-យោងតាមមាត្រា ៤៦ បានចែងអំពីរបៀបក្នុងការស្គាល់ថាបទល្មើសមួយ គឺជាបទឧក្រិដ្ឋតាមរយៈទោសដាក់ពន្ធនាគារ ។ ដូច្នេះមាត្រា ៤៦ បានកំណត់ថាប្រសិនបើទោសដាក់ពន្ធនាគារដែលមានចែងកំណត់ក្នុងច្បាប់ គឺជាទោសដាក់ពន្ធនាគារអស់មួយជីវិត ឬមួយក៏ជា ទោសដាក់ពន្ធនាគារមានចិរវេលាកំណត់លើសពី ៥ (ប្រាំ) ឆ្នាំ ឡើងទៅដល់ក្រោមឬស្មើ ៣០ (សាមសិប) ឆ្នាំ។ ក្នុងករណីនេះឱ្យតែបទល្មើសមួយចែងក្នុងច្បាប់ផ្តន្ទាទោសក្នុងកម្រិតដូចបាន ជម្រាបជូនអម្បិញមិញច្បាប់បានកំណត់ថានោះហើយជាប្រភេទបទឧក្រិដ្ឋ ។ ជាទូទៅសាធារណៈជន ក៏ដូចជាអ្នកច្បាប់យល់ឃើញថាឱ្យតែទោសកំណត់នោះលើសពី ៥ (ប្រាំ) ឆ្នាំ ឡើងទៅ ចំណុចនេះក្រមឱ្យឈ្មោះថាបទឧក្រិដ្ឋ ។ ក្រៅពីការសម្គាល់នូវចំណុចខាងលើបែបនេះ ទោសដាក់ពន្ធនាគារក៏អាចត្រូវ បន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ[93]។

តាមការបកស្រាយខាងលើ យើងអាចទាញនូវលក្ខណៈសម្គាល់នៃទោសឧក្រិដ្ឋថា ជាទោសមួយប្រភេទដែលរយៈពេលនៃការដាក់ពន្ធនាគារមានរយៈពេលលើសពី ៥ (ប្រាំ) ឆ្នាំ និងក្រោម ឬស្មើនឹង ៣០ (សាមសិប) ឆ្នាំ ឬដាក់ពន្ធនាគារអស់មួយជីវិត។

ចំណែកឯការកំណត់ទៅលើលក្ខណៈសម្គាល់នៃទោសឧក្រិដ្ឋ នៅក្នុងក្រមព្រហ្មទណ្ឌខេមរៈឆ្នាំ ១៩០៩ វិញ ក៏មានលក្ខណៈស្ទើតែដូចគ្នាទាំងស្រុងទៅនឹងលក្ខណៈសម្គាល់នៃទោសឧក្រិដ្ឋដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ ផងដែរ ។ បើយើងធ្វើការពិនិត្យទៅលើការបកស្រាយទៅលើលក្ខណៈសម្គាល់នៃទោសឧក្រិដ្ឋនេះ យើងត្រូវលើកនូវសណ្ឋាននៃឧក្រិដ្ឋទោសមួយចំនួនមកធ្វើការបកស្រាយប្រៀបធៀប ដែលមានចែងនៅក្នុងមាត្រា ៨ នៃក្រមព្រហ្មទណ្ឌខេមរៈឆ្នាំ ១៩០៩ ។ បើយោងតាមមាត្រា ៨ នៃក្រមនេះ ឧក្រិដ្ឋទោសត្រូវបានបែងចែកជា ប្រាំបីសណ្ឋាន ប៉ុន្តែយើងលើកយកមកតែ ៣ សណ្ឋានតែប៉ុណ្ណោះដើម្បីធ្វើការបកស្រាយបង្ហាញនូវលក្ខណៈសម្គាល់នៃ

[92] សទ្ទានុក្រមពាក្យច្បាប់ ផ្នែកក្រមព្រហ្មទណ្ឌ ទីស្តីការគណៈរដ្ឋមន្ត្រី ឆ្នាំ ២០១១ លេខរៀងទី ១៨៣

[93] មាត្រា ៤៦ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ចែងអំពី "និយមន័យនៃបទឧក្រិដ្ឋ"

ទោសឧក្រិដ្ឋនៅក្នុងក្រមនេះ ដែលវាស្មើដូចគ្នាទាំងស្រុងទៅនឹងក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ ។ សណ្ឋានទាំងបីនោះមានដូចជា ៖

- សណ្ឋាន ២ គឺឱ្យដាក់គុកបង្ខំឱ្យធ្វើការជាទម្ងន់អស់មួយជីវិត
- សណ្ឋាន ៥ គឺឱ្យដាក់គុក ទុកពី ៥ ឆ្នាំ ទៅដល់ ២០ ឆ្នាំ ឱ្យនៅដោយពួកមិនឱ្យច្រឡំនឹងគ្នា
- សណ្ឋាន ៦ គឺឱ្យដាក់គុកកន្លែងស្ងាត់នៅតែម្នាក់ឯងពី ៥ ឆ្នាំ ទៅដល់ ១០ ឆ្នាំ ។

យោងទៅតាមសណ្ឋានទាំងបីខាងលើ យើងគ្រាន់តែពិនិត្យទៅលើរយៈពេលនៃការដាក់គុក យើងសង្កេតឃើញថា ទោសឧក្រិដ្ឋ ឬ ឧក្រិដ្ឋទោសនេះ យើងអាចសម្គាល់ដោយគ្រាន់តែពិនិត្យទៅលើរយៈពេលនៃការដាក់គុក ដែលមានកំណត់ចាប់ពី ៥ ឆ្នាំ ទៅដល់ ២០ ឆ្នាំ ឬ អស់មួយជីវិត ។ ចំពោះរយៈពេលនៃការដាក់គុក នៃទោសឧក្រិដ្ឋ យើងអាចទាញលក្ខណៈសម្គាល់ជាទូទៅ ដោយពិនិត្យទៅលើអប្បបរមានៃការដាក់គុកនៃទោសឧក្រិដ្ឋនេះ គឺ ចាប់ពី ៥ ឆ្នាំ ហើយអតិបរមានៃការដាក់គុក គឺ អស់មួយជីវិត ហេតុដូច្នេះ លក្ខណៈសម្គាល់នៃទោសឧក្រិដ្ឋដែលមានចែងក្នុងក្រមព្រហ្មទណ្ឌខេមរៈឆ្នាំ ១៩០៩ គឺដូចគ្នាទៅនឹងលក្ខណៈសម្គាល់ក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ ដែរ ពីព្រោះតែអតិបរមានៃទោសដាក់គុកនៃក្រមទាំងពីរនេះ គឺសុទ្ធតែលើសពី ៥ ឆ្នាំ និងអាចដាក់គុកអស់មួយជីវិតដូចគ្នា។

### ៣.១.៣.២. លក្ខណៈសម្គាល់នៃទោសមជ្ឈិម

ទោសមជ្ឈិមនេះយើងអាចធ្វើការកំណត់សម្គាល់បានដូចនេះ ដោយយោងតាមការបកស្រាយទៅលើលក្ខណៈសម្គាល់នៃបទល្មើសមជ្ឈិម ។

បទមជ្ឈិម គឺជាបទល្មើសដែលមានទណ្ឌកម្មមធ្យមនៃទោស ដែលត្រូវដាក់ពន្ធនាគារមានរយៈពេលលើសពី ៦ (ប្រាំមួយ) ថ្ងៃ ដល់ក្រោម ឬស្មើ ៥ (ប្រាំ) ឆ្នាំ[94] ។

-យោងតាមមាត្រា ៤៧ ដើម្បីអាចស្គាល់ថាបទល្មើសមួយគឺជាបទមជ្ឈិមបាន នោះយើងត្រូវពិនិត្យមើលថាតើអតិបរមានៃទោសដែលមានចែងនៅក្នុងច្បាប់ នោះផ្ដន្ទាទោសគឺមានកម្រិតប៉ុនណា? បើសិនជាអតិបរមានៃទោសដែលមានចែងក្នុងច្បាប់ដោយផ្ដន្ទាទោសលើសពី ៦ ថ្ងៃ ទៅដល់ក្រោមឬស្មើនឹង ៥ ឆ្នាំ ក្នុងក្រមព្រហ្មទណ្ឌត្រង់មាត្រា ៤៧ ចាត់ទុកថាបទល្មើសនោះ គឺជាប្រភេទបទមជ្ឈិម។ ហើយបទមជ្ឈិមនេះ ក្រៅពីទោសដាក់ពន្ធនាគារ ច្បាប់អាចចែងបន្ថែមនូវទោសពិន័យជាប្រាក់បានទៀត[95]។

[94] សទ្ទានុក្រមពាក្យច្បាប់ ផ្នែកក្រមព្រហ្មទណ្ឌ ទីស្ដីការគណៈរដ្ឋមន្ត្រី ឆ្នាំ ២០១១ លេខរៀងទី ១៤០

[95] មាត្រា ៤៧ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ចែងអំពី "និយមន័យនៃបទបជ្ឈិម"

ការបកស្រាយអំពីបទល្មើសមជ្ឈិមខាងលើ បានឆ្លុះបង្ហាញឱ្យឃើញនូវលក្ខណៈសម្គាល់នៃទោសមជ្ឈិមថាជាប្រភេទនៃទោសមួយ ដែលរយៈពេលនៃការដាក់ពន្ធនាគារមានរយៈពេលលើសពី ៦ ថ្ងៃ ដល់ក្រោម ឬស្មើ ៥ ឆ្នាំ ។

ចំពោះការកំណត់នូវលក្ខណៈសម្គាល់នៃទោសមជ្ឈិម នៅក្នុងក្រមព្រហ្មទណ្ឌខេមរៈឆ្នាំ ១៩០៩ វិញ គឺមានលក្ខណៈដូចគ្នាទាំងស្រុងតែម្តងទៅនឹងលក្ខណៈសម្គាល់ដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ ។ ដើម្បីបង្ហាញ ឱ្យឃើញនូវចំនុចដូចគ្នានេះ យើងត្រូវពិនិត្យទៅលើមាត្រា ៣២ នៃក្រមព្រហ្មទណ្ឌខេមរៈឆ្នាំ ១៩០៩ ដែលបានចែងថា *«ទោះឈ្មោះណាមានទោសដាក់គុកនោះត្រូវយកខ្លួនទៅដាក់គុក ហើយត្រូវប្រើឱ្យធ្វើការនីមួយៗ ក្នុងគុកកំណត់ទោសនេះយ៉ាងតិច ៦ (ប្រាំមួយ) ថ្ងៃ យ៉ាង ច្រើន ៥ (ប្រាំ) ឆ្នាំ ។ តែបើត្រូវទោសម្តងហើយមកត្រូវម្តងទៀតនោះ ឬក៏មានទោសផ្សេងទៀតដែលច្បាប់នឹងសម្រេចកំណត់ទោសនោះ ត្រូវធ្វើទោសតាមបញ្ញត្តិ* ។»

បន្ទាប់ពីបានធ្វើការបកស្រាយប្រៀបធៀប នូវលក្ខណៈសម្គាល់នៃទោសមជ្ឈិមរវាងក្រមព្រហ្មទណ្ឌទាំងពីរ យើងសង្កេតឃើញថាលក្ខណៈសម្គាល់ដែលមានចែងក្នុងក្រមទាំងពីរ គឺដូចគ្នាទាំងស្រុងចំពោះទោសមជ្ឈិម ។

#### ៣.១.៣.៣. លក្ខណៈសម្គាល់នៃទោសលហុ

ទោសលហុនេះ កម្រិតរបស់វាយើងត្រូវធ្វើការពិចារណារទៅលើចំនុចពីរសំខាន់ៗ គឺ ការដាក់ពន្ធនាគារ និងការពិន័យជាប្រាក់ ទោសលហុនេះក៏ត្រូវធ្វើការកត់សម្គាល់តាមរយៈលក្ខណៈសម្គាល់របស់បទល្មើសលហុផងដែរ។

បទលហុ គឺជាបទល្មើសដែលមានទណ្ឌកម្មស្រាលជាងគេ ។ បទល្មើសនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារដែលមានរយៈពេលក្រោម ឬស្មើនឹង ៦ (ប្រាំមួយ) ថ្ងៃ ឬពិន័យជាប្រាក់សុទ្ធសាធប៉ុណ្ណោះ[96]។

-យោងតាមមាត្រា ៤៨ របៀបក្នុងការសម្គាល់បទលហុមាន ២ ដូចតទៅ ៖ លក្ខខណ្ឌវិនិច្ឆ័យទីមួយ គឺមើលទៅលើទោសដាក់ពន្ធនាគារ ។ ផ្អែកតាម មាត្រាលើនេះ បទល្មើសមួយត្រូវបានចាត់ទុកថាជាបទលហុ នៅពេលដែលអតិបរមានៃទោសដាក់ពន្ធនាគារដែលមានចែងក្នុងច្បាប់នោះគឺចាប់ពី ១ ថ្ងៃ ទៅដល់ក្រោម ឬ ស្មើនឹង ៦ ថ្ងៃ មានន័យថា ៦ ថ្ងៃចុះមកក្រោម ឱ្យតែមានទោសដាក់ពន្ធនាគារ បទល្មើសហ្នឹងឯង គឺជាប្រភេទបទលហុ នេះហើយ គឺជាលក្ខខណ្ឌវិនិច្ឆ័យទីមួយ ។

លក្ខខណ្ឌវិនិច្ឆ័យទីពីរ គឺបទល្មើសហ្នឹងឯងត្រូវផ្តន្ទាទោសត្រឹមពិន័យជាប្រាក់ តែប៉ុណ្ណោះ គឺគ្មានចែងដាក់ពន្ធនាគារទេ ។ យើងមើលឃើញថាបទល្មើសខ្លះ ដាក់ស្តែងបទល្មើសបរិហារកេរ្តិ៍គឺ

[96] សទ្ទានុក្រមពាក្យច្បាប់ ផ្នែកក្រមព្រហ្មទណ្ឌ ទីស្តីការគណៈរដ្ឋមន្ត្រី ឆ្នាំ ២០១១ លេខរៀងទី ១៦១

មានចែងត្រឹមតែពិន័យជាប្រាក់តែប៉ុណ្ណោះ។ បើសិនផ្តន្ទាទោសត្រឹមតែពិន័យជាប្រាក់សុទ្ធសាធបែប នេះ តាមមាត្រា ៤៨ បទល្មើសប្រភេទនេះគឺជាបទលហុ[97]។

យោងទៅតាមការបកស្រាយអំពីលក្ខណៈសម្គាល់នៃបទលហុ នៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ យើងអាចទាញនូវលក្ខណៈសម្គាល់នៃទោសលហុបានថា ទោសលហុ គឺ ជាទោសដែល ដាក់ទៅលើទណ្ឌិត ដោយរយៈពេលនៃការដាក់ពន្ធនាគារ ចាប់ពី ១ ថ្ងៃ ដល់ ក្រោម ឬស្មើនឹង ៦ ថ្ងៃ ឬ មានតែការពិន័យជាប្រាក់មួយមុខប៉ុណ្ណោះ ។

ចំណែកការកំណត់ចំពោះលក្ខណៈសម្គាល់នៃទោសលហុ នៅក្នុងក្រមព្រហ្មទណ្ឌខេមរៈឆ្នាំ ១៩០៩ វិញ ក៏មានលក្ខណៈស្រដៀងគ្នាទៅនឹងលក្ខណៈ ដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ ផងដែរ ។ ដើម្បីបង្ហាញឱ្យឃើញនូវលក្ខណៈស្រដៀងគ្នានេះ យើងត្រូវពិនិត្យទៅលើការ កំណត់ដែលមានចែងនៅក្នុងមាត្រាចំនួនពីរនៅក្នុងក្រមនេះ៖

***មាត្រា ២៩២.*** សេចក្តីជាលហុទោស ជាប្រដៅបន្តិចបន្តួច នោះនឹងឱ្យតិចជាងពី ១ (មួយ) ថ្ងៃចុះមក ឬឱ្យហួសពី ៥ (ប្រាំ) ថ្ងៃឡើងទៅពុំបានឡើយ ។ ឯកំណត់ថ្ងៃដែលនឹងដាក់ គុកនោះតោង គិតឱ្យគ្រប់ពេញ ២៤ (ម្ភៃបួន) ម៉ោងជាមួយថ្ងៃ ។

យោងតាមការចែងនៅក្នុងមាត្រា ២៩២ នេះ គឺបានបង្ហាញនូវលក្ខណៈសម្គាល់នៃទោសលហុ មួយ គឺ ការដាក់គុក ឬការដាក់ពន្ធនាគារ ដែលមានរយៈពេល ចាប់ពី ១ ថ្ងៃ ទៅដល់ ៥ ថ្ងៃ ។ ការលើក ឡើងនេះមានន័យថា បើសិនជាមានទោសណាមួយត្រូវបានចែងដោយដាក់ទណ្ឌកម្មទៅលើអំពើ ដែលជាបទល្មើស ហើយទោសនេះមានរយៈពេលនៃការដាក់គុកនៅក្នុងចន្លោះពី ១ ថ្ងៃ ទៅដល់ ៥ ថ្ងៃ ទោសនេះគឺជាទោសលហុ ។

***មាត្រា ២៩៦ ខ៩*** ទោះឈ្មោះណាល្មើសនឹងច្បាប់ ដែលរាជការរៀបចំជាត្រឹមត្រូវហើយ មិន ព្រមធ្វើតាមរបៀបច្បាប់រាជការ ដែលតែងបញ្ញត្តិសេចក្តីទោសល្មើសបញ្ញត្តិជាលហុទោស ដូចមាន និយាយខាងលើទាំងនេះត្រូវធ្វើទោសពិន័យជាប្រាក់ពី ២០ (ម្ភៃ) សេន ទៅដល់ ១ (មួយ) រៀល។

ចំណែកឯការចែងនៅក្នុងមាត្រា ២៩៦ ចំនុច ខ៩ ក៏បានបង្ហាញនូវលក្ខណៈសម្គាល់មួយបន្ថែម ទៀតទៅលើលក្ខណៈសម្គាល់ខាងលើ គឺ ទោសដែលមានត្រឹមតែការពិន័យជាប្រាក់តែប៉ុណ្ណោះ ។ ការ បកស្រាយលើចំនុច ខ៩ នៃមាត្រា ២៩៦ នេះមានន័យថា បើសិនជាមានទោសណាមួយត្រូវបានចែង ដោយដាក់ទណ្ឌកម្មទៅលើអំពើដែលជាបទល្មើស ហើយទោសនេះមានត្រឹមតែការពិន័យជាប្រាក់តែ មួយមុខដោយពុំមានការដាក់គុកទេ ទោសនោះគឺជា ទោសលហុ ។

[97] មាត្រា ៤៨ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ចែងអំពី "និយមន័យនៃបទលហុ"

បើយើងពិនិត្យទៅលើការចែងនៅក្នុងមាត្រាទាំងពីរខាងលើ យើងសង្កេតឃើញថាទោសលហុមានលក្ខណៈសម្គាល់ចំនួនពីរដែលដូចគ្នាទៅនឹងការកំណត់នៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ ដែរ គឺការដាក់គុក ឬមានតែការពិន័យជាប្រាក់តែមួយប៉ុណ្ណោះ។ ប៉ុន្តែរវាងក្រមទាំងពីរត្រង់ចំនុចនេះ មានលក្ខណៈខុសគ្នាបន្តិចនៅត្រង់រយៈពេលនៃការដាក់ពន្ធនាគារដែល ក្រមព្រហ្មទណ្ឌខេមរៈឆ្នាំ ១៩០៩ គឺ មានរយៈពេលចាប់ ១ ថ្ងៃ ទៅដល់ ៥ ថ្ងៃ ចំណែកឯ ក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ វិញ មានរយៈពេល ចាប់ពី ១ ថ្ងៃ ទៅដល់ ក្រោមឬស្មើនឹង ៦ ថ្ងៃ ។

**៣.១.៤. បុគ្គលដែលត្រូវទទួលរងនូវប្រភេទទោសជារូបវន្តបុគ្គល**

បុគ្គលដែលត្រូវទទួលរងនូវប្រភេទទោស គឺ ចង់សំដៅទៅលើបុគ្គលដែលបានប្រព្រឹត្តនូវបទល្មើសណាមួយទោះជាដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី ហើយត្រូវបានប្រកាសទោសដោយតុលាការតាមរយៈសេចក្តីសម្រេច ។ ពាក់ព័ន្ធទៅនឹងការបកស្រាយអំពីបុគ្គលដែលត្រូវទទួលរងនូវប្រភេទទោស យើងទាញបាននូវចំនុចដូចគ្នារវាងក្រមព្រហ្មទណ្ឌទាំងពីរ គឺនៅត្រង់ថា បុគ្គលដែលត្រូវទទួលរងនូវប្រភេទទោសដែលមានចែងនៅក្នុងក្រមទាំងពីរនេះជារូបវន្តបុគ្គល ។

មុននឹងឈានទៅដល់ការបកស្រាយទៅលើចំនុចផ្សេងទៀត យើងត្រូវយល់នូវអត្ថន័យនៃរូបវន្តបុគ្គលជាមុនសិនះ

រូបវន្តបុគ្គល គឺជាបុគ្គលម្នាក់ៗដែលមានជីវិតពិត ផ្ទុយពីនីតិបុគ្គល[98]។

រូបវន្តបុគ្គល គឺជាមនុស្សពិតតាមធម្មជាតិ ដែលផ្ទុយនឹងនីតិបុគ្គល[99]។

នៅក្នុងការរៀបរាប់អំពីរូបវន្តបុគ្គលដែលទទួលរងនូវប្រភេទទោសព្រហ្មទណ្ឌ បុគ្គលប្រភេទនេះត្រូវបានធ្វើការបែងចែកជាពីរសំខាន់ៗ គឺ អ្នកប្រព្រឹត្តដោយផ្ទាល់ និងអ្នកប្រព្រឹត្តដោយប្រយោល ។

**៣.១.៤.១. អ្នកប្រព្រឹត្តដោយផ្ទាល់**

អ្នកប្រព្រឹត្តដោយផ្ទាល់ ឬជនដៃដល់ គឺ សំដៅទៅលើបុគ្គលដែលបានចូលរួមដោយផ្ទាល់តាមរយៈសកម្មភាពណាមួយរបស់ខ្លួន ហើយសកម្មភាពនេះបានបង្ករជាបទល្មើសកើតឡើង ។ បុគ្គលដែលជាអ្នកប្រព្រឹត្តដោយផ្ទាល់ក្នុងការបង្ករឡើងជាបទល្មើស ត្រូវបានធ្វើការបែងចែកជាពីរគឺចារី និងសហចារី ។

នៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ មានការចែងកំណត់យ៉ាងច្បាស់លាស់នៅក្នុងមាត្រានៃក្រមនេះអំពីអត្ថន័យនៃចារី និងសហចារី ។ យោងទៅតាមការចែងនៅក្នុងក្រមនេះយើងអាចទាញនូវលក្ខខណ្ឌ ដើម្បីធ្វើការកំណត់នូវលក្ខណៈសម្គាល់នៃពាក្យទាំងពីរនេះដូចខាងក្រោមះ

[98] សទ្ទានុក្រមពាក្យច្បាប់ ផ្នែកក្រមព្រហ្មទណ្ឌ ទីស្តីការគណៈរដ្ឋមន្ត្រី ឆ្នាំ ២០១១ លេខរៀងទី ១៩៩

[99] សទ្ទានុក្រមពាក្យច្បាប់ ផ្នែករដ្ឋប្បវេណី ទីស្តីការគណៈរដ្ឋមន្ត្រី ឆ្នាំ ២០០៧ លេខរៀងទី ១២៧

- **ចារី** សំដៅទៅលើបុគ្គលណាដែលប្រព្រឹត្តបទល្មើសដែលត្រូវចោទប្រកាន់ ហើយនៅក្នុងករណីមួយទៀត ត្រូវចាត់ទុកជាចារីផងដែរ ចំពោះបុគ្គលណាដែលប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋ ឬក្នុងករណីដែលច្បាប់បានចែងទុកចំពោះបទមជ្ឈិម [100]។
- **សហចារី** សំដៅទៅលើបុគ្គលច្រើននាក់បានព្រមព្រៀងប្រព្រឹត្តបទល្មើសរួមគ្នាដោយផ្ទាល់ ហើយនៅក្នុងករណីមួយទៀត ត្រូវចាត់ទុកជាសហចារីផងដែរ កាលណាមានបុគ្គលច្រើននាក់បានព្រមព្រៀងប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមដោយផ្ទាល់ក្នុងករណីដែលច្បាប់បានចែងទុក[101]។

បើយើងក្រលេកមើលនៅក្នុងក្រមព្រហ្មទណ្ឌខេមរៈឆ្នាំ ១៩០៩ វិញ គឺពុំមានការកំណត់ច្បាស់លាស់អំពីចំនុចនេះទេ ។ ទោះជាក្នុងក្រមនេះពុំមានចែងនៅក្នុងមាត្រាច្បាស់លាស់ដូចក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ ខាងលើក៏ដោយ ប៉ុន្តែអ្នកប្រព្រឹត្តដោយផ្ទាល់ដែលជារូបវន្តបុគ្គលនេះ គឺមានទទួលទោសដូចគ្នា ។

### ៣.១.៤.២. អ្នកប្រព្រឹត្តដោយប្រយោល

អ្នកប្រព្រឹត្តដោយប្រយោល គឺ សំដៅទៅលើបុគ្គលដែលបានចូលរួមប្រព្រឹត្តបទល្មើសតាមរយៈមធ្យោបាយផ្សេងៗ ដោយមិនមានវត្តមាននៅក្នុងពេលប្រព្រឹត្តបទល្មើសនោះទេ ។ បុគ្គលដែលបានប្រព្រឹត្តបទល្មើសនៅក្នុងចំនុចនេះត្រូវបានធ្វើការបែងចែកជាពីរ គឺ អ្នកផ្តើមគំនិត និងអ្នកសមគំនិត ។

ចំពោះការបកស្រាយទៅលើនិយមន័យនៃអ្នកផ្តើមគំនិត និងអ្នកសមគំនិត គឺ មានការចែងច្បាស់លាស់នៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ ។ ការចែងនៅក្នុងក្រមនេះ គឺ អាចធ្វើឱ្យយើងអាចកំណត់នូវលក្ខណៈសម្គាល់ចំពោះបុគ្គលណាមួយ ដើម្បីអាចបញ្ជាក់ថាបុគ្គម្នាក់នោះជាអ្នកផ្តើមគំនិត ឬអ្នកសមគំនិត ។

- **អ្នកផ្តើមគំនិត** សំដៅទៅលើបុគ្គលណា ដែលជម្រុញឱ្យប្រព្រឹត្តបទល្មើសតាមការណែនាំ ឬការបញ្ជា ហើយនៅក្នុងករណីមួយផ្សេងទៀតសំដៅទៅលើបុគ្គល ដែលបង្កឱ្យមានបទល្មើសដោយផ្តល់អំណោយដោយការសន្យា ឬការគម្រាមកំហែង ការញុះញង់ ការល្បួងលោមឬក៏ដោយការរំលោភអាជ្ញា ឬអំណាចរបស់ខ្លួន[102]។

---

[100] មាត្រា២៥ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩

[101] មាត្រា២៦ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩

[102] មាត្រា២៨ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩

– **អ្នកសមគំនិត** គឺមានន័យថាជាបុគ្គលណាដែលជួយសម្រួលដោយចេតនាដល់ការប៉ុនប៉ង ឬការសម្រេចបទល្មើស ដោយផ្តល់ជំនួយ ឬការឧបត្ថម្ភរបស់ខ្លួន[103]។

ចំពោះចំនុចដែលនិយាយអំពី អ្នកផ្តើមគំនិត និងអ្នកសមគំនិត នៅក្នុងក្រមព្រហ្មទណ្ឌខេមរៈឆ្នាំ ១៩០៩ ក៏មានចែងអំពីអត្ថន័យរបស់ពាក្យទាំងពីរនេះដែរ ប៉ុន្តែមិនបានបង្ហាញឱ្យចេញជាឈ្មោះចំៗតែម្តងនោះទេ ។ ការកំណត់នូវអត្ថន័យនៃពាក្យទាំងពីរនេះ ត្រូវបានចែងដោយបានបញ្ជាក់នូវលក្ខណៈសម្គាល់ដូចតទៅះ

– **អ្នកផ្តើមគំនិត** សំដៅទៅលើបុគ្គលដែលបានបំពេញនូវលក្ខខណ្ឌដូចតទៅះ

១. គឺមនុស្សដែលទំនុកបម្រុង ឱ្យរបស់ទ្រព្យហើយដោយសន្មតសញ្ញាក្តី ប្រើដោយកំហែងក្តី រំលោភដោយអំណាចក្តី ប្រើកលឧបាយបញ្ឆោតឱ្យកើតជាអំពើអាក្រក់ក្តី បង្គាប់បញ្ជាឱ្យធ្វើ អំពើអាក្រក់ក្តី ។

២. គឺមនុស្សដែលឱ្យគ្រឿងសាត្រាអាវុធក្តី ឱ្យគ្រឿងអ្វីនីមួយ ឬ ឧប្បទេស (ការបញ្ចេះ ការពន្យល់ ការណែនាំ) បង្ហាញដូចម្តេចឱ្យវាទៅធ្វើអាក្រក់ នោះបានដឹងជាគ្រឿងសាត្រាវុធ នោះវានឹងយកទៅធ្វើទុច្ចរិតនោះដែរ [104]។

– **អ្នកសមគំនិត** គឺសំដៅទៅលើបុគ្គលទាំងឡាយណាដែលបានបំពេញទៅតាមលក្ខខណ្ឌដូចខាងក្រោមះ

១. គឺមនុស្សដែលបានដឹងឮ ជាអាចោរកំណាចនឹងទៅធ្វើទុច្ចរិតហើយទៅជួយ ទៅកំដរ ក្នុងកិច្ចកល ដែលគិត ដែលរៀបធ្វើអំពើទុច្ចរិតនោះ ឱ្យកើតដោយងាយក្តី ឬធ្វើហើយទើប ទៅជួយទៅកំដរក្តី ។

២. គឺមនុស្សដែលស្គាល់មនុស្សមារយាទអាក្រក់ ធ្វើជាអាចោរកំណាចប្លន់គេនេះមួយ ធ្វើអំពើទុច្ចរិតមិនឱ្យបានសេចក្តីសុខក្នុងព្រះនគរនេះមួយ ទុច្ចរិតនឹងមនុស្សដទៃ ឬឱ្យវិនាស បង់ទ្រព្យសម្បត្តិអ្នកដទៃនេះមួយ ហើយឱ្យទីសំណាក់អាស្រ័យនៅជាប្រក្រតី ឱ្យទីឋានវា ជ្រកពួន ឬឱ្យទីកន្លែងវាប្រជុំគ្នា ។

៣. គឺមនុស្សដែលដឹងថាជារបស់នីមួយៗ ជារបស់លួចឆក់បំបាត់គេ ឬបានដោយធ្វើអំពើឧក្រិដ្ឋឬមជ្ឈិមទោស បើមនុស្សនោះទទួលយករបស់ទាំងនេះ តិចច្រើនទៅលាក់បំពួនទុកក្តី ។

[103] មាត្រា២៩ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩

[104] មាត្រា ៥៨ ចំនុច ១ និង២ នៃក្រមព្រហ្មទណ្ឌខេមរៈ ចុះថ្ងៃទី ៨ ខែ មេសា ឆ្នាំ ១៩០៩

៤. គឺមនុស្សដែលបានដឹងជាទ្រព្យលួចគេ ហើយទទួលយកលាក់ទុកតិចច្រើនក្តី ទោះជាទ្រព្យលួចគេក្តី ឬជាទ្រព្យបានមកដោយនៅធ្វើអាក្រក់ក្តី ជាឧក្រិដ្ឋទោស ឬមជ្ឈិមទោស (គឺរួមគំនិត) ។ ទោសទាំងប៉ុន្មានសណ្ឋាននេះ ត្រូវធ្វើទោសជាគូកនសមគំនិតនិងអាចោរ [105]។

<u>**បញ្ជាក់៖**</u> ការបកស្រាយនៅក្នុងចំនុចដែលនិយាយអំពីបុគ្គលដែលត្រូវទទួលរងនូវប្រភេទទោសជារូបវន្តបុគ្គលនេះ មានន័យថាជាការបកស្រាយដោយបង្ហាញឱ្យឃើញថា នៅក្នុងក្រមព្រហ្មទណ្ឌទាំងពីរបានកំណត់ចំពោះបុគ្គលដែលត្រូវទទួលរងនូវប្រភេទទោសនេះគឺ រូបវន្តបុគ្គលដូចគ្នា ។ ចំណែកឯការបកស្រាយទៅលើចំនុចដែលនិយាយអំពីបុគ្គលដែលប្រព្រឹត្តដោយផ្ទាល់ និង បុគ្គលដែលប្រព្រឹត្តដោយប្រយោល គឺវាមិនផ្តោតសំខាន់ទៅលើថាចំនុចទាំងពីរនេះមានចែងអំពីលក្ខណៈសម្គាល់ដូចគ្នារវាងក្រមទាំងពីរនោះទេ វាគ្រាន់តែជាការពន្យល់ថាប្រធាននៃបទល្មើសនៅក្នុងក្រមទាំងពីរនេះជារូបវន្តបុគ្គលដូចគ្នាតែប៉ុណ្ណោះ ។

## ៣.២.ចំនុចខុសគ្នានៃប្រភេទទោស

ស្រដៀងគ្នាទៅនឹងការបកស្រាយលើចំនុចដូចគ្នានៃប្រភេទទោសផងដែរ ការបកស្រាយអំពីចំនុចខុសគ្នានៃប្រភេទទោស អាចធ្វើឡើងបានតាមរយៈការសិក្សាទៅលើការបកស្រាយអំពីប្រភេទទោសព្រហ្មទណ្ឌនៅក្នុងឆ្នាំនីមួយៗដែរ ។ បន្ទាប់ពីបានពិនិត្យដោយយកចិត្តទុកដាក់ទៅលើការរៀបរាប់នូវប្រភេទទោសនៅក្នុងឆ្នាំទាំងពីររួចហើយ យើងអាចធ្វើការកត់សម្គាល់នូវចំនុចខុសគ្នាមួយចំនួនរវាងក្រមទាំងពីរ ។ ការបកស្រាយទៅលើចំនុចខុសគ្នានៃប្រភេទទោសនេះ ត្រូវបានបង្ហាញតាមរយៈការបកស្រាយទៅលើចំនុចធំៗមួយចំនួនដូចជា៖ ការកំណត់ឈ្មោះ និងការបង្កើតថ្មីនៃប្រភេទទោស (៣.២.១.) សណ្ឋាននៃប្រភេទទោសដែលលុបចេញពីក្រមចាស់ (៣.២.២.) បុគ្គលដែលទទួលរងនូវប្រភេទទោសជានីតិបុគ្គល (៣.២.៣.) និងអាជ្ញាយុកាលនៃប្រភេទទោស (៣.២.៤.) ។

### ៣.២.១. ការកំណត់ឈ្មោះ និងការបង្កើតថ្មីនៃប្រភេទទោស

ការបកស្រាយអំពី ការកំណត់ឈ្មោះ និងការបង្កើតថ្មីនៃប្រភេទទោស គឺចង់សំដៅទៅលើការលើកឡើងនូវលក្ខណៈខុសគ្នានៃក្រមទាំងពីរទៅលើឈ្មោះនៃប្រភេទទោស និង ប្រភេទទោសផ្សេងទៀតដែលត្រូវបានបង្កើតថ្មីនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ ។ នៅក្នុងបញ្ហានេះ គឺត្រូវបានលើកយកមកបង្ហាញតាមរយៈការបកស្រាយទៅលើចំនុចពីរសំខាន់ៗ គឺការកំណត់ឈ្មោះនៃប្រភេទទោស និង ការបង្កើតថ្មីនៃប្រភេទទោស ។

[105] មាត្រា ៥៨ ចំនុច ៣,៤,៥ និង៦ នៃក្រមព្រហ្មទណ្ឌខេមរៈ ចុះថ្ងៃទី ៨ ខែ មេសា ឆ្នាំ ១៩០៩

**៣.២.១.១. ការកំណត់ឈ្មោះនៃប្រភេទទោស**

ចំនុចដែលលើកឡើងអំពីការកំណត់ឈ្មោះនៃប្រភេទទោសនេះ ត្រូវបានបកស្រាយដោយបង្ហាញពីភាពខុសគ្នានៅក្នុងក្រមទាំងពីរចំពោះការកំណត់ឈ្មោះនៃប្រភេទទោស ។ នៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ ចំពោះប្រភេទទោសត្រូវបានបែងចែកជា ៣ (បី)ប្រភេទ គឺ មូលទោស ទោសបន្ថែម និង ទោសជំនួស ។ ភាពខុសគ្នានៃការកំណត់ឈ្មោះចំពោះប្រភេទនៃក្រមទាំងពីរ យើងសង្កេតឃើញថាមានប្រភេទទោសចំនួនពីរដែលមាននៅក្នុងក្រមថ្មី ហើយប្រភេទទាំងពីរនេះគឺ ពុំមានបញ្ជាក់ឈ្មោះច្បាស់លាស់នៅក្នុងក្រមចាស់នោះទេ ។ ប្រភេទទោសទាំងពីរនោះគឺ មូលទោស និងទោសបន្ថែម ។

**ក.មូលទោស**

មូលទោស គឺជាប្រភេទមួយក្នុងចំណោមប្រភេទទោសទាំងបីដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ ហើយមូលទោសនេះមានផ្ទុកនូវទោសពីរបន្ថែមទៀត គឺទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់ ។ យើងសង្កេតឃើញថា នៅក្នុងក្រមថ្មីនេះបានធ្វើការកំណត់រួមគ្នានូវទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់ស្ថិតនៅក្រោមឈ្មោះនៃប្រភេទទោសតែមួយ គឺ**មូលទោស ។**

ផ្ទុយទៅវិញបើយើងធ្វើការពិនិត្យទៅលើក្រមព្រហ្មទណ្ឌខេមរៈឆ្នាំ ១៩០៩ វិញ ក៏មានការកំណត់អំពីទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់ដែរ បើយើងមើលទៅវាមានដូចនៅក្នុងក្រមថ្មីដែរ ប៉ុន្តែ នៅក្នុងក្រមចាស់ពុំបានយកទោសទាំងពីរនេះដាក់បញ្ចូលស្ថិតក្រោមការកំណត់ឈ្មោះតែមួយច្បាស់លាស់ដូចក្រមថ្មីនោះទេ គឺ វាមាននៅក្នុងប្រភេទទោសទាំងបី គឺ ឧក្រិដ្ឋទោស មជ្ឈិមទោស និងលហុទោស ដែលផ្ទុយពីក្រមថ្មីត្រង់ថា នៅក្នុងក្រមថ្មីទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់ស្ថិតនៅក្នុងប្រភេទទោសមួយក្នុងចំណោមប្រភេទទោសទាំងបី គឺមូលទោស។

**ខ.ទោសបន្ថែម**

នៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ ទោសបន្ថែមត្រូវបានធ្វើការកំណត់យ៉ាងច្បាស់លាស់ដោយចាត់ទុកទោសបន្ថែមនេះជាប្រភេទទោសមួយផងដែរ ។ ពិសេសជាងនេះទៅទៀត ភាពច្បាស់លាស់នៃទោសបន្ថែមដែលត្រូវបានចែងនៅក្នុងក្រមថ្មីនេះ គឺសំដៅទៅលើការកំណត់អំពីនិយមន័យ និងការបង្ហាញនូវទោសមួយចំនួនដែលធ្វើឱ្យមានភាពងាយស្រួលក្នុងការសិក្សា និងធ្វើការសម្គាល់ថាទោសណាជាទោសបន្ថែម ។ ទោសបន្ថែមមានចំនួនច្រើនរហូតទៅដល់ ១៩ ប៉ុន្តែនៅក្នុងការបកស្រាយអំពីភាពខុសគ្នានៃការកំណត់ឈ្មោះប្រភេទទោស យើងលើកយកតែទោស

បន្ថែមមួយចំនួនដែលមានរូបភាពនៅក្នុងក្រមព្រហ្មទណ្ឌខេមរៈឆ្នាំ ១៩០៩ តែប៉ុណ្ណោះ ។ ទោសបន្ថែមទាំងនោះមានដូជា៖ ការដកសិទ្ធិខ្លះជាពលរដ្ឋ ការហាមឃាត់ចំពោះការស្នាក់នៅ ការរឹបអូស និងការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស ។

ចំណែកឯនៅក្នុងក្រមព្រហ្មទណ្ឌខេមរៈឆ្នាំ ១៩០៩ វិញ ក៏មានចែងអំពីទោសដែលរៀបរាប់ខាងលើនេះដែរ បើទោះបីជាការចែងនោះពុំមានលក្ខណៈដូចគ្នាទាំងស្រុងទៅនឹងការចែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ ក៏ដោយក៏យើងអាចចាត់ទុកការចែងនេះជារូបភាពនៃទោសបន្ថែម ។ ប៉ុន្តែនៅក្នុងក្រមនេះពុំមានកំណត់ថាទោសដែលរៀបរាប់ខាងលើនេះជាទោសបន្ថែមនោះទេ ហើយក៏មិនមានការបញ្ជាក់នូវនិយមន័យនៃទោសបន្ថែមផងដែរ ។ ហេតុនេះក្រមព្រហ្មទណ្ឌខេមរៈឆ្នាំ ១៩០៩ ពុំបានកំណត់នូវឈ្មោះជាក់លាក់នោះទេសម្រាប់ទោសខាងលើដូចក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ ដែលមានឈ្មោះថា **ទោសបន្ថែម** ។

### ៣.២.១.២. ការបង្កើតថ្មីនៃប្រភេទទោស

ការបកស្រាយស្តីអំពីការបង្កើតថ្មីនៃប្រភេទទោស គឺសំដៅទៅដល់ការបកស្រាយទៅលើប្រភេទទោសដែលត្រូវបានបង្កើតថ្មីនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ ដែលពុំមានចែងនៅក្នុងក្រមព្រហ្មទណ្ឌខេមរៈឆ្នាំ ១៩០៩ នោះទេ ។

ឆ្លងតាមការពិនិត្យទៅលើការបកស្រាយទាំងឡាយខាងលើ យើងសង្កេតឃើញថានៅក្នុងចំណោមប្រភេទទោសទាំងបីដែលមានចែងក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ គឺមានប្រភេទទោសចំនួន ២ ហើយដែលមានរូបភាពនៅក្នុងក្រមព្រហ្មទណ្ឌខេមរៈឆ្នាំ ១៩០៩ ។ ប្រភេទទោសទាំងពីរនោះគឺ មូលទោស និងទោសបន្ថែម ហេតុនេះនៅមានទោសមួយទៀតដែលមិនមានរូបភាពដូចទោសទាំងពីរនេះទេ គឺ **ទោសជំនួស** ហើយទោសជំនួសនេះផងដែរជាសញ្ញាណមួយថ្មីដែលវាត្រូវបានបង្កើតឡើងក្នុងគោលបំណងដើម្បីប្រកាសដាក់ជំនួសឱ្យមូលទោស ។

## ៣.២.២. សណ្ឋាននៃប្រភេទទោសដែលលុបចេញពីក្រមចាស់

នៅក្នុងការបកស្រាយនូវ សណ្ឋាននៃប្រភេទទោសដែលលុបចេញពីក្រមចាស់ គឺចង់សំដៅទៅលើការលើកឡើងនូវសណ្ឋានមួយចំនួននៃប្រភេទទោសដែលមានកំណត់នៅក្នុងក្រមចាស់ មកធ្វើការបកស្រាយហើយបង្ហាញពីភាពខុសគ្នា និងមូលហេតុដែលនាំឱ្យមានការលុបចោល ។ សណ្ឋាននៃប្រភេទទោសនៅក្នុងក្រមចាស់ដែលលុបចោល មានចំនួនពីរសណ្ឋានគឺ សណ្ឋានទោសប្រហារជីវិត និង សណ្ឋាននៃទោសដាក់ពន្ធនាគារ ។

### ៣.២.២.១. ទោសប្រហារជីវិត

ទោសប្រហារជីវិត គឺជាសណ្ឋានមួយក្នុងចំណោមសណ្ឋានទាំងប្រាំបីនៃឧក្រិដ្ឋទោស ដែលវាជាសណ្ឋានទីមួយ នៅក្នុងក្រមចាស់ចែងថា ឱ្យពិឃាតជីវិតបង់ ។ មូលហេតុដែលនាំឱ្យទោសប្រហារជីវិតស្ថិតនៅក្នុងសណ្ឋានទីមួយនេះដោយសារតែ វាមានលក្ខណៈធ្ងន់ធ្ងរជាងគេទាំងអស់ ។ កម្រិតធ្ងន់ធ្ងរនៃទោសនេះ យើងអាចមើលឃើញដោយការកំណត់ទណ្ឌកម្មទៅលើទណ្ឌិត ដែលមានការសម្លាប់ទណ្ឌិតដោយកាត់ក្បាល ហើយនៅពេលដែលស្លាប់រួច សពដែលត្រូវបានសម្លាប់នោះបើសិនជាមានសាច់ញាតិចង់យកទៅធ្វើបុណ្យឱ្យមានភាពធំដុំពុំបានឡើយ ។

ដោយសារតែកម្រិតនៃទោសប្រហារជីវិតដែលមានចែងនៅក្នុងក្រមចាស់ មានលក្ខណៈធ្ងន់ធ្ងរបែបនេះហើយ ទើបក្រមថ្មីបានកំណត់ចែងដោយលុបបំបាត់នូវទោសនេះចោលទៅ ។ មូលហេតុនៃការលុបចោលនៅក្នុងក្រមថ្មី គឺ ដោយសារតែមានការចែងនៅក្នុងរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជាដែលមានចែងនៅក្នុងមាត្រា ៣២ « ជនគ្រប់រូប មានសិទ្ធិរស់រានមានជីវិត មានសេរីភាព និងមានសន្តិសុខផ្ទាល់ខ្លួន ។ ទោសប្រហារជីវិតមិនត្រូវឱ្យមានឡើយ ។»

ការហាមឃាត់ចំពោះការប្រហារជីវិតនេះមិនត្រឹមតែមានចែងក្នុងច្បាប់ជាតិនោះ សូម្បីតែច្បាប់អន្តរជាតិក៏មានចែងផងដែរ គឺមានដូចជាសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ដែលមានចែងក្នុងមាត្រា ៣ ដោយលើកឡើងថា « បុគ្គលម្នាក់ៗ មានសិទ្ធិរស់រានមានជីវិត សេរីភាព និងសន្តិសុខផ្ទាល់ខ្លួន» ។ លើសពីនេះក៏មានច្បាប់ អន្តរជាតិមួយទៀតដែរ គឺ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ក៏មានចែងអំពីសិទ្ធិនេះដែរ គឺ មាត្រា ៦ បានចែងថា«ជនគ្រប់រូបមានសិទ្ធិរស់រានមានជីវិតជាប់ពីកំណើត ។ សិទ្ធិនេះ ត្រូវការពារដោយច្បាប់ ។ គ្មានជនណាម្នាក់ត្រូវគេប្រហារជីវិតតាមអំពើចិត្តបានឡើយ»។

### ៣.២.២.២. សណ្ឋាននៃទោសដាក់ពន្ធនាគារ

នៅក្នុងការបកស្រាយចំនុចនេះ មានគោលបំណងក្នុងការបង្ហាញនូវលក្ខណៈខុសគ្នាបន្តិចរវាងទោសដាក់ពន្ធនាគារដែលមានចែងក្នុងក្រមទាំងពីរ ។ ចំនុចខុសគ្នានេះ គឺមិនមែនសំដៅទៅលើការលុបចោលនូវទោសដាក់ពន្ធនាគារនោះទេ គឺយើងចង់បង្ហាញអំពីការលុបចោលនូវលក្ខណៈនៃទោសដាក់ពន្ធនាគារដែលត្រូវបានបែងចែកជាច្រើនសណ្ឋាននៅក្នុងក្រមចាស់ ហើយត្រូវបានកំណត់នៅក្នុងក្រមព្រហ្មទណ្ឌថ្មីនេះត្រឹមតែទោសដាក់ពន្ធនាគារ ដោយពុំមានបញ្ជាក់នូវលក្ខណៈបន្ថែមទៅលើទោសនេះទេ ។

ចំពោះចំនុចនេះ នៅក្នុងក្រមចាស់បានធ្វើការបែងចែកនូវសណ្ឋានជាច្រើនដែលពាក់ព័ន្ធនឹងទោសដាក់ពន្ធនាគារនេះ ។ ការបែងចែកនេះ គឺមាននៅក្នុងសណ្ឋានចំនួនបួនក្នុងចំណោមសណ្ឋានទាំងប្រាំបីនៃឧក្រិដ្ឋទោស ដូចខាងក្រោមៈ

- សណ្ឋាន ២ គឺឱ្យដាក់គុកបង្ខំឱ្យធ្វើការជាទម្ងន់អស់មួយជីវិត
- សណ្ឋាន ៤ គឺឱ្យដាក់គុកបង្ខំឱ្យធ្វើការជាទម្ងន់មានកំណត់
- សណ្ឋាន ៥ គឺឱ្យដាក់គុក ទុកពី ៥ (ប្រាំ) ឆ្នាំ ទៅដល់ ២០ (ម្ភៃ) ឆ្នាំ ឱ្យនៅដោយពួកមិនឱ្យច្រឡំនឹងគ្នា
- សណ្ឋាន ៦ គឺឱ្យដាក់គុកកន្លែងស្ងាត់នៅតែម្នាក់ឯង ពី ៥(ប្រាំ)ឆ្នាំ ទៅដល់ ១០(ដប់)ឆ្នាំ

នៅក្នុងសណ្ឋានទាំងបួនខាងលើនេះ បានបង្ហាញនូវលក្ខណៈបន្ថែមទៅលើទោសដាក់ពន្ធនាគារ ព្រោះថាមិនត្រឹមតែការដាក់ពន្ធនាគារទេ ថែមទាំងបន្ថែមនូវចំនុចមួយចំនួនទៀតដូចជា៖ ការបង្ខំឱ្យធ្វើការជាទម្ងន់ ការដាក់ឱ្យនៅជាពួកមិនច្រឡំនឹងគ្នា និង ការដាក់ឱ្យនៅកន្លែងស្ងាត់តែម្នាក់ឯងជាដើម ។

### ៣.២.៣.បុគ្គលដែលត្រូវទទួលរងនូវប្រភេទទោសជានីតិបុគ្គល

ចំពោះការបកស្រាយដែលលើកឡើងអំពី បុគ្គលដែលត្រូវទទួលរងនូវប្រភេទទោសជានីតិបុគ្គលនេះ គឺជាការបកស្រាយមួយដែលរៀបរាប់អំពីការទទួលខុសត្រូវរបស់នីតិបុគ្គលក្នុងរឿងព្រហ្មទណ្ឌ ។ នីតិបុគ្គល គឺជាសញ្ញាណមួយថ្មីនៃប្រធាននៃបទល្មើស ដែលពុំមានចែងនៅក្នុងក្រមព្រហ្មទណ្ឌខេមរៈឆ្នាំ ១៩០៩ ទេ។ បន្ទាប់ពីបញ្ជាក់នូវភាពខុសគ្នារវាងក្រមទាំងពីរទៅលើចំនុចនេះ យើងសូមលើកយកនូវការបកស្រាយអំពីនីតិបុគ្គល ដែលត្រូវទទួលរងនូវប្រភេទទោសព្រហ្មទណ្ឌដូចខាងក្រោម៖

នីតិបុគ្គល គឺជាក្រុមមនុស្ស ឬមូលនិធិ ដែលមានបុគ្គលភាពគតិយុត្ត ហើយជាម្ចាស់ ឬប្រធាននៃសិទ្ធិ និងកាតព្វកិច្ច[106]។

យើងឃើញថា ច្បាប់ចែងអំពីប្រភេទនៃទោសសម្រាប់នីតិបុគ្គលមានតែ ២ (ពីរ) ប្រភេទប៉ុណ្ណោះ ៖ គឺទី១-**មូលទោស** និង ទី២-**ទោសបន្ថែម**។

ខាងក្រោមនេះគឺ ជាការលើកឡើងនូវសេចក្ដីពន្យល់នូវអត្ថន័យទាំងស្រុងដូចតទៅ ៖

#### ៣.២.៣.១. មូលទោសក្នុងប្រភេទជាទោសពិន័យ

យើងធ្លាប់បានសិក្សារួចមកហើយអំពី ប្រភេទនៃមូលទោសសម្រាប់ រូបវន្តបុគ្គល មាន ០២ (ពីរ) ប្រភេទ គឺប្រភេទទី១-ទោសដាក់ពន្ធនាគារ និង ប្រភេទទី២-ទោសពិន័យជាប្រាក់។ ក៏ប៉ុន្តែ

[106] មាត្រា ៤ កថាខណ្ឌទី ៧ នៃច្បាប់ស្ដីពីការប្រឆាំងអំពើពុករលួយ ចុះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០១០
និង សទ្ទានុក្រមពាក្យច្បាប់ ផ្នែកក្រមព្រហ្មទណ្ឌ ទីស្ដីការគណៈរដ្ឋមន្ត្រី ឆ្នាំ ២០១១ លេខរៀងទី ៥៦
និង សទ្ទានុក្រមពាក្យច្បាប់ ផ្នែករដ្ឋប្បវេណី ទីស្ដីការគណៈរដ្ឋមន្ត្រី ឆ្នាំ ២០០៧ លេខរៀងទី ៧១

សម្រាប់នីតិបុគ្គលវិញ គឺមានតែមួយប៉ុណ្ណោះ ពីព្រោះបើយោងតាមមាត្រា ១៦៧ កថាខណ្ឌទី ១ ចែងត្រឹមតែ ទោសពិន័យក្នុងឋានៈជាមូលទោសប៉ុណ្ណោះ។

ដោយសារស្ថានភាពនៃនីតិបុគ្គល ដែលសំដៅដល់នីតិបុគ្គលដែលបង្កើតឡើងដោយច្បាប់ ដូចជាសំដៅដល់ក្រុមហ៊ុន សំដៅដល់សមាគម សំដៅដល់អង្គការជាដើម។ល។ គេហៅថានីតិបុគ្គលនោះដោយសារតែគាត់ គឺជាបុគ្គលដែលអរូបិយ៍ បានន័យថា មិនដូចបុគ្គលជាមនុស្សពីព្រោះថាគាត់ មិនមែនជាមនុស្សទេ ។ ដូច្នេះហើយគេត្រូវសម្រេចអំពីទណ្ឌកម្មចំពោះគាត់ តើសម្រេចរបៀបម៉េច ? ជាក់ស្តែងដូចជាទោសដាក់ពន្ធនាគារ គឺគេមិនអាច ចាប់ក្រុមហ៊ុនដាក់ពន្ធនាគារបានទេ ។ ហេតុនេះ គេសម្រេចទោសដែលអាច ប្រើប្រាស់សម្រាប់នីតិបុគ្គលបានគឺមានតែ**ទោសពិន័យជាប្រាក់**ប៉ុណ្ណោះ។

ចំណែកឯបែបបទដែលមានចែងទាក់ទងជាមួយនឹងទោសទាំងពីរនេះ គឺមានចែងចាប់ពីមាត្រា ១៦៧ ទៅដល់ មាត្រា ១៨២ នៃក្រមព្រហ្មទណ្ឌ។ ហើយចាប់ពីមាត្រាទាំងនេះទៅ យើងសង្កេតឃើញថាទោសពិន័យក្នុងឋានៈ ជាមូលទោសនេះ គឺយើងប្រើប្រាស់ដូចគ្នាជាមួយនឹងទោសពិន័យសម្រាប់ រូបវន្តបុគ្គលដែរ ។ ដូច្នេះដើម្បីចង់ដឹងថាតើទោសពិន័យនេះមានប៉ុន្មាន ? ត្រូវពិនិត្យក្នុងអត្ថបទច្បាប់ ហើយជាទូទៅទោសពិន័យមានកំណត់ពីអប្បបរមា និងកំណត់ពីអតិប្បរមាដូចគ្នាជាមួយរូបវន្តបុគ្គលដែរ ។

### ៣.២.៣.២. ទោសបន្ថែមទាំង ១៤ ចំនុច

ចំណែក**ទោសបន្ថែម**សម្រាប់នីតិបុគ្គលវិញ មានចែងយ៉ាងជាក់លាក់ ក្នុងមាត្រា ១៦៨ ដែលនៅក្នុងមាត្រាមួយនេះ មានចែងចំនួន ១៤ ចំណុច ដែលចំណុចទាំងនេះគឺមានកន្លែងខ្លះខុសគ្នាពីរូបវន្តបុគ្គល ។ ម្យ៉ាងវិញទៀត ទោសបន្ថែមនេះ ក៏បានបង្ហាញនៅក្នុងមាត្រា ១៦៧ កថាខណ្ឌទី ២ ផងដែរ ដោយបានបញ្ជាក់ឱ្យយើងយល់ថា ទោសដែលត្រូវរងដោយនីតិបុគ្គលក៏មាន ទោសបន្ថែមដែលមានចែងរៀបរាប់នៅក្នុងមាត្រា ១៦៨ (ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ ផងដែរ ។ ប៉ុន្តែដើម្បីបានជាព័ត៌មានខ្លះៗ យើងសូមអនុញ្ញាតសរសេរជូនទាំងស្រុងតែម្តងនូវមាត្រា ១៦៨ ថាតើទោសបន្ថែមត្រូវអនុវត្តចំពោះនីតិបុគ្គលមានអ្វីខ្លះ ? បើយើងយោងតាម មាត្រា ១៦៨ ទោសបន្ថែមដែលត្រូវអនុវត្តចំពោះនីតិបុគ្គលមានដូចតទៅ ៖

ទី១-ការរំលាយចោល និងការជំម្រះបញ្ជីនៃនីតិបុគ្គល (មាត្រា ១៧០)

ទី២-ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដាន
របស់តុលាការ (មាត្រា ១៧១)

ទី៣-ការហាមឃាត់ចំពោះការធ្វើសកម្មភាព (មាត្រា ១៧២)

ទី៤-ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ (មាត្រា ១៧៣)

ទី៥-ការហាមឃាត់ចំពោះការអំពាវនាវជាសាធារណៈឱ្យធ្វើ ការសន្សំសំចៃ (មាត្រា ១៧៤)

ទី៦-ការហាមឃាត់ចំពោះការចេញឧបករណ៍អាចជួញដូរបានក្រៅពី ឧបករណ៍អាចជួញដូរបានដែលកំណត់ដោយធនាគារ (មាត្រា ១៧៥)

ទី៧-ការហាមឃាត់ចំពោះការប្រើប្រាស់ បណ្ណទូទាត់ (មាត្រា ១៧៥ កថាខណ្ឌទី ២)

ទី៨-ការបិទគ្រឹះស្ថានដែលប្រើប្រាស់សម្រាប់ធ្វើការរៀបចំ ឬប្រព្រឹត្តបទល្មើស (មាត្រា ១៧៦)

ទី៩-ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថានដែលបើកចំហដល់ សាធារណជនឬដែលបានប្រើប្រាស់សម្រាប់សាធារណជន (មាត្រា ១៧៧)

ទី១០-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយដែលប្រើសម្រាប់ ប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅសម្រាប់ ប្រព្រឹត្តបទល្មើស (មាត្រា ១៧៩ កថាខណ្ឌទី ១)

ទី១១-ការរឹបអូសវត្ថុ ឬមូលនិធិដែលជាកម្មវត្ថុ នៃបទល្មើស (មាត្រា ១៧៩ កថាខណ្ឌទី ២)

ទី១២-ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាផល កើតចេញពីបទល្មើស (មាត្រា ១៧៩ កថាខណ្ឌទី ៣)

ទី១៣-ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬចលនវត្ថុនៅក្នុងទីកន្លែង ដែលបទល្មើសបានប្រព្រឹត្ត (មាត្រា ១៧៩ កថាខណ្ឌទី ៤)

ទី១៤-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ឬការផ្សាយតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ (មាត្រា ១៨០ និងមាត្រា ១៨១) ។

<u>**ចំណាំ**</u> **៖ ការរំលាយចោល** គឺបើនិយាយប្រៀបធៀបទៅនឹងរូបវន្តបុគ្គល ឬ សម្រាប់មនុស្សវិញ គឺ ហាក់បីដូចជាការសម្រេចប្រកាស*ទោសប្រហារជីវិត* អញ្ចឹង បានន័យថា រំលាយអត្ថិភាពនៃនីតិបុគ្គលទៅ

តាមផ្លូវច្បាប់ ។ ទោសនេះគឺជា ទោសដ៏ធ្ងន់ធ្ងរជាងគេសម្រាប់នីតិបុគ្គល ពីព្រោះក្រៅពីពិន័យជាប្រាក់ហើយ ចៅក្រម គាត់ក៏អាចរំលាយក្រុមហ៊ុនហ្នឹងចោល រំលាយសមាគមហ្នឹងចោល រំលាយអង្គការហ្នឹងចោលបាន ដូច្នេះទោសបន្ថែមត្រង់ចំណុចទីមួយខាងលើមានសារៈសំខាន់ខ្លាំងណាស់ ។

### ៣.២.៤.អាជ្ញាយុកាលនៃប្រភេទទោស

ចំពោះអាជ្ញាយុកាលនៃប្រភេទទោសនេះ គឺមានចែងយ៉ាងច្បាស់លាស់នៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ ប៉ុន្តែវាពុំមានចែងនៅក្នុងក្រមព្រហ្មទណ្ឌខេមរៈឆ្នាំ ១៩០៩នោះទេ ។ ហេតុនេះ យើងសូមលើកយកនូវការបកស្រាយអំពីអាជ្ញាយុកាលនេះ ដោយយោងទៅតាមក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ ដូចខាងក្រោមនេះ ។

អាជ្ញាយុកាលនៃប្រភេទទោសមានន័យថា ជារយៈពេលដែលកំណត់អំពីអត្ថិភាពនៃទោសដែលអាចយកទៅអនុវត្តបានចំពោះទណ្ឌិតដែលត្រូវបានប្រកាសដោយតុលាការ ។ នៅពេលដែលសេចក្តីសម្រេចរបស់តុលាការចូលជាស្ថាពរហើយ ទោះបីជា តាមរូបភាពជាសាលក្រមឬសាលដីកាក៏ដោយ ទោសដែលត្រូវបានសម្រេច ប្រកាសដោយតុលាការនោះ ត្រូវតែយកមកអនុវត្ត ។ ក៏ប៉ុន្តែដោយសារតែ អំឡុងពេលនៃការផ្តន្ទាទោស ដែលចូលជាស្ថាពរនោះ ជននេះអត់ត្រូវបាន ទទួលរងនូវទណ្ឌកម្មសោះ មានន័យថា ដំបូងគាត់គេចខ្លួនដើម្បីឱ្យរួចផុតពី អាជ្ញាយុកាលនៃបទល្មើស ប៉ុន្តែវាអត់ផុត ស្រាប់តែដល់ពេលដែលចៅក្រម សម្រេចឱ្យមានទោសរួចហើយ គាត់ក៏រត់ពួនទៅទៀត ដូច្នេះគាត់ត្រូវរស់នៅ ក្នុងស្ថានភាពមួយដែលលំបាកវេទនារហូតទាល់តែរយៈពេល ដូចក្នុងច្បាប់នេះចែងកំណត់ថារយៈពេល ២០ ឆ្នាំសម្រាប់បទឧក្រិដ្ឋ ដែលមានលក្ខណៈជា ប្រភេទបទល្មើសធ្ងន់ធ្ងរ អញ្ចឹង២០ឆ្នាំនេះ បើគិតតាំងពីពេលវេលាដែលគាត់ ប្រព្រឹត្តបទល្មើស បើបូកទៅប្រហែលជាអាចខ្ទង់លើសពី ២០ ឆ្នាំ ឬរហូតទៅ ដល់ ៣០ ផ្លាយឆ្នាំដែលគាត់បានរត់ពួនលាក់គេចខ្លួនដោយអ្វីៗទាំងអស់ដែល បន្សល់ទុកនៅលើសង្គមនោះ គឺវាហាក់បីដូចជាបានសាបរលាបអស់ទៅវិញបាត់ទៅហើយ។

<u>ឧទាហរណ៍</u> ៖ នៅពេលដែលមានគ្រួសារណាមួយស្លាប់ ប្តី ឬ ប្រពន្ធ ឬ កូន ដែលនៅរស់នោះមានទុក្ខសោកខ្លាំងណាស់ ប៉ុន្តែ ដល់រយៈពេលវែងកន្លងផុតទៅវាក៏រសាយបាត់អស់ទៅវិញដែរ ។ ប៉ុន្តែក៏មានការហាមឃាត់សម្រាប់ បទល្មើសមួយចំនួនដែលមិនកំណត់អាជ្ញាយុកាលទេ ដោយសារតែឥទ្ធិពល នោះបន្សល់ទុកនៅក្នុងសង្គមជានិច្ច ដូចជា បទឧក្រិដ្ឋប្រល័យពូជសាសន៍ បទប្រឆាំងនឹងមនុស្សជាតិ ឬមួយក៏ បទឧក្រិដ្ឋសង្គ្រាម ដែលគេមិនគិតអំពី អាជ្ញាយុកាលទេ បើទោះបីជាជននោះបានប្រព្រឹត្តក្នុងអំឡុងពេលប៉ុន្មានក៏ដោយ ក៏ត្រូវតែទទួលនូវការផ្តន្ទាទោសទៅតាមច្បាប់ដែរ នេះ

ដោយសារថា ឥទ្ធិពលនៃគ្រោះថ្នាក់វា គឺធ្ងន់ធ្ងរខ្លាំងណាស់សម្រាប់សង្គម ។ បើយោងទៅតាមមាត្រា ១៤៣ ស្តីពី "ភាពមិនអាចផុតរលត់អាជ្ញាយុកាលនៃទោសចំពោះ បទឧក្រិដ្ឋមួយចំនួន" បានបញ្ជាក់យ៉ាងច្បាស់ថា ក្រៅពីបទល្មើសធំៗទាំងបីខាងលើ ក៏នូវមានច្បាប់ពិសេសដូចជាច្បាប់ស្តីពីការប្រឆាំងអំពើភេរវកម្ម ជាគម្រូអាចកំណត់អំពីភាពមិនអាចផុតរលត់អាជ្ញាយុកាលនៃទោសចំពោះបទឧក្រិដ្ឋផ្សេងទៀតបានដែរ។

ម្យ៉ាងវិញទៀត បើធ្វើការសិក្សាពាក់ព័ន្ធជាមួយនឹងអ្វីដែលជាមូលហេតុ ទូទៅហ្នឹង គឺឃើញថាប្រសិនបើអំឡុងពេលបានកន្លងផុតទៅហើយ ក្រោយ ពីពេលដែលសាលក្រម ឬសាលដីកាសម្រេចជាស្ថាពរ ២០ ឆ្នាំ សម្រាប់ បទឧក្រិដ្ឋ, ៥ ឆ្នាំ សម្រាប់បទមជ្ឈិម, ១ ឆ្នាំ សម្រាប់បទលហុទោសទាំងអស់នេះមិនត្រូវយកមកអនុវត្តបានទេ ពីព្រោះមាត្រា ១៤២ បានចែងថា នៅពេលផុតអាជ្ញាយុកាលហើយ ទោសលែងអនុវត្តបានទៀតហើយ។

ចំពោះចំណុចចាប់ផ្តើមនៃចិរវេលាវិញ បើផ្អែកទៅលើមាត្រា ១៤៥ បានកំណត់ថាចិរវេលា ២០ (ម្ភៃ) ឆ្នាំ ៥ (ប្រាំ) ឆ្នាំ និង ១ (មួយ) ឆ្នាំ ខាងលើ ដែលមានចែងនៅក្នុងមាត្រា ១៤៤ ( អាជ្ញាយុកាលនៃទោស ) នៃក្រមនេះ ចាប់គិតពីថ្ងៃដែលសេចក្តីសម្រេចផ្តន្ទាទោសបានក្លាយទៅជាស្ថាពរ ។

យើងសូមធ្វើការបញ្ចប់នូវការបកស្រាយទៅលើប្រធានបទស្តីពី ការប្រៀបធៀបប្រភេទទោសព្រហ្មទណ្ឌតែត្រឹមប៉ុណ្ណេះ ។ ប៉ុន្តែជាចុងក្រោយ យើងខ្ញុំទាំងពីរនាក់សូមធ្វើសេចក្តីសន្និដ្ឋាន និងផ្តល់អនុសាសន៍មួយចំនួនដើម្បីបញ្ចប់ជាស្ថាពរនូវសារណានេះ ។ សូមអរគុណ!!

# សេចក្តីសន្និដ្ឋាន

ឆ្លងតាមការសិក្សាទៅលើប្រធានបទខាងលើនេះ យើងសង្កេតឃើញថាមុននឹងឈានទៅដល់ការបង្ហាញនូវចំណុចដូចគ្នា និងចំណុចខុសគ្នានៃប្រភេទទោសព្រហ្មទណ្ឌនៅក្នុងឆ្នាំ ១៩០៩ និងឆ្នាំ ២០០៩ យើងបានធ្វើការសិក្សាទៅលើការបកស្រាយនូវលក្ខណៈនៃប្រភេទទោសនៅក្នុងឆ្នាំនីមួយៗជាមុនសិន ។

ប្រភេទទោសព្រហ្មទណ្ឌនៅក្នុងឆ្នាំ ១៩០៩ ត្រូវបានចែងនៅក្នុងក្រមព្រហ្មទណ្ឌខេមរៈឆ្នាំ ១៩០៩ ដោយបានធ្វើការបែងចែកទោសព្រហ្មទណ្ឌជាបីប្រភេទ គឺ ឧក្រិដ្ឋទោស មជ្ឈិមទោស និង លហុទោស ។ ចំពោះប្រភេទទោសទាំងបីនេះ ត្រូវបានបញ្ជាក់តាមរយៈការលើកឡើងនូវសណ្ឋានដែលមានចែងនៅក្នុងក្រមនេះតែម្តង។ នៅក្នុងឧក្រិដ្ឋទោសមានប្រាំបីសណ្ឋាន នៅក្នុងមជ្ឈិមទោសមានបីសណ្ឋាន ចំណែកឯលហុទោសវិញ មានបីសណ្ឋាន ប៉ុន្តែនៅក្នុងសណ្ឋាននីមួយៗពុំមានបញ្ជាក់ឈ្មោះទេ គឺមានតែបញ្ជាក់អំពីបទល្មើសដែលត្រូវចាត់ចូលនៅក្នុងសណ្ឋានណាមួយប៉ុណ្ណោះ។

ជារួមមកយើងសង្កេតឃើញថា ប្រភេទទោសដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌខេមរៈឆ្នាំ ១៩០៩ មានគុណវិប្បត្តិ និងគុណសម្បត្តិរបស់វាដែលមាននៅក្នុងប្រភេទទោសតែម្តង ។

ពាក់ព័ន្ធទៅនឹងទោសប្រហារជីវិត ដែលជាសណ្ឋានលំដាប់ថ្នាក់ទីមួយនៃឧក្រិដ្ឋទោសវាមានគុណសម្បត្តិនៅត្រង់ថា វាធ្វើឱ្យមានការខ្លាចរអារពីសំណាក់បុគ្គលដែលរស់នៅក្នុងសង្គម មិនហ៊ានប្រព្រឹត្តនូវអំពើដែលជាបទល្មើសដែលត្រូវផ្តន្ទាទោសប្រហារជីវិតនោះទេ ។ ប៉ុន្តែវាមានគុណវបត្តិនៅត្រង់ថា ទោះបីជាមានការដាក់ទោសយ៉ាងធ្ងន់ធ្ងររហូតដល់ការដកហូតជីវិតក៏ដោយ ប៉ុន្តែបទល្មើសនោះនៅតែកើតមានហើយវាមានលក្ខណៈកាន់តែសាហាវជាងមុនទៅទៀត ។

ចំណែកឯនៅក្នុងសណ្ឋាននៃឧក្រិដ្ឋទោសនេះផងដែរ ក៏មានការកំណត់អំពីរការដាក់គុក ប៉ុន្តែការដាក់គុកនេះមានការបែងចែកជាច្រើនប្រភេទបន្ថែមទៀត ដូចមានកំណត់នៅក្នុងសណ្ឋាន ២ សណ្ឋាន ៤ សណ្ឋាន ៥ និងសណ្ឋាន ៦ ។ ការកំណត់បែបនេះវាមានចំណុចល្អនៅត្រង់ថា ងាយស្រួលនៅក្នុងការបែងចែកទណ្ឌិតទៅតាមប្រភេទនីមួយៗនៃបទល្មើស ហើយមានការកំណត់ច្បាស់លាស់នូវការងារដែលត្រូវធ្វើនៅពេលដែលទណ្ឌិតកំពុងអនុវត្តទោស ។ ប៉ុន្តែការកំណត់នេះក៏មានចំណុចអវិជ្ជមានផងដែរ គឺ វាមានផលវិបាកសម្រាប់ចៅក្រមនៅក្នុងការកំណត់ដាក់ទោស ពីព្រោះត្រូវពិនិត្យទៅលើបទល្មើសដែលទណ្ឌិតបានប្រព្រឹត្ត ហើយបានធ្វើការកំណត់នូវទោសទៅតាមសណ្ឋានដែលបទល្មើសនោះត្រូវទទួលរង ។

ចំណុចដែលគួរឱ្យកត់សម្គាល់ផងដែរនោះ គឺ ការចែងអំពីលហុទោស ។ នៅក្នុងការចែងអំពីលហុទោសនេះ ត្រូវបានកំណត់ដោយលើកឡើងនូវឈ្មោះបទល្មើសតែម្តងមិនដូចការចែងអំពីឧក្រិដ្ឋទោស និងមជ្ឈិមទោសនោះទេ ។ ការចែងបែបនេះវាមានភាពងាយស្រួលនៅក្នុងការកំណត់ទោសទៅលើបទល្មើសណាមួយដោយគ្រាន់តែពិនិត្យទៅលើឈ្មោះបទល្មើសនោះ យើងដឹងថាត្រូវកំណត់ទោសយ៉ាងណានៅក្នុងសណ្ឋាននៃលហុទោស ពីព្រោះនៅក្នុងសណ្ឋាននីមួយៗមានរៀបរាប់នូវឈ្មោះបទល្មើសរួចជាស្រេច ។ ប៉ុន្តែការចែងបែបនេះក៏មានផលវិបាកផងដែរ គឺ នៅត្រង់ថាវាពិបាក់ក្នុងការកំណត់អោយបានច្បាស់លាស់ទៅលើបទល្មើសនីមួយៗ ពីព្រោះនៅក្នុងនោះមានការរៀបរាប់ខ្លីៗមិនមានការលម្អិតទេ ។

ចំពោះប្រភេទទោសព្រហ្មទណ្ឌនៅក្នុងឆ្នាំ ២០០៩ នេះវិញ ត្រូវបានចែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ ដោយធ្វើការបែងចែកជាបីប្រភេទ គឺមូលទោស ទោសបន្ថែម និងទោសជំនួស ។ មូលទោស គឺជាទោសមូលដ្ឋានដែលយកទៅប្រើប្រាស់សម្រាប់ការប្រកាសទោសចំពោះជនជាប់ចោទដែលបានប្រព្រឹត្តបទល្មើស ហើយមូលទោស ត្រូវបានកំណត់ដោយក្រមព្រហ្មទណ្ឌមានទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់ ។ ទោសបន្ថែម គឺជាទោសដែលត្រូវបានកំណត់សម្រាប់ដាក់បន្ថែមទៅលើមូលទោសចំពោះទណ្ឌិតដែលបានអនុវត្តមូលទោសរួចហើយ ហើយទោសបន្ថែមនេះ អាចត្រូវបានយកទៅអនុវត្តបានលុះត្រាតែមានចែងយ៉ាងច្បាស់លាស់នៅក្នុងក្រមព្រហ្មទណ្ឌ ។ ចំពោះទោសជំនួសនេះវិញ គឺជាប្រភេទទោសមួយដែលត្រូវបានបង្កើតឡើង ដើម្បីដាក់ជំនួសឱ្យមូលទោសកាលណាលក្ខខណ្ឌនៃទោសជំនួសនេះត្រូវបានបំពេញ ហើយទោសជំនួសនេះត្រូវបានបែងចែកជាពីរ គឺ ទោសការងារសហគមន៍ និងទោសស្តីបន្ទោស ។

ចំណែកលក្ខណៈសម្បត្តិរបស់ប្រភេទទោសនៅក្នុងឆ្នាំ ២០០៩ នេះក៏មានទាំងគុណវិប្បត្តិ និងគុណសម្បត្តិផងដែរ ។

ជាដំបូងយើងលើកឡើងអំពីកម្រិតនៃការដាក់ទោស គឺសំដៅទៅលើមូលទោសនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ ។ ចំពោះកម្រិតនៃការដាក់ទោសនេះ គឺមានលក្ខណៈល្អច្រើន ដោយសារតែក្រមនេះបានដកចេញនូវទោសប្រហារជីវិត ។ លើសពីនេះទៅទៀត ការដាក់ទោសទៅលើទណ្ឌិត គឺ ត្រូវបានកំណត់ដោយគោរពសិទ្ធិមនុស្សជាចម្បង ទោះជាបុគ្គលនោះជាបុគ្គលដែលបានប្រព្រឹត្តនូវអំពើដែលធ្វើឱ្យសង្គមពើបប្រទះភាពអសកម្មក៏ដោយ ក៏ត្រូវបានធានាផលប្រយោជន៍ និងការពារនូវសិទ្ធិផងដែរ ។ ប៉ុន្តែទោះយ៉ាងនេះក្តី ក៏នៅតែមានចំណុចខ្វះខាតដោយសារបទល្មើសនៅតែកើតមានដដែល ពីព្រោះតែប្រជាពលរដ្ឋមិនខ្លាចរអារ និងមិនរៀងចាលឡើយ ។ ការមិនរៀងចាល និង

ការមិនខ្លាចរអានេះ គឺ កើតឡើងដោយសារការមើលងាយទៅលើទណ្ឌកម្មដែលកំណត់ ពីព្រោះតែពួកគាត់យល់ថា វាមានលក្ខណៈស្រាលមិនមានការដាក់ទណ្ឌកម្មធ្ងន់ធ្ងរដូចជា ការប្រហារជីវិត និងការធ្វើការធ្ងន់ធ្ងរជាដើម ។ បន្ថែមលើសពីនេះទៅទៀត ការដាក់មូលទោសបានធ្វើឱ្យប៉ះពាល់ដល់ប្រជាពលរដ្ឋដូចជាជីវភាព ព្រមទាំងធនធានមនុស្សផងដែរ ពីព្រោះតែនៅពេលដែលដាក់ទោសពន្ធនាគារចំពោះបុគ្គលម្នាក់ដែលជាមេគ្រួសារ ហើយគាត់ជាអ្នករកនូវចំណូលសម្រាប់ផ្គត់ផ្គង់គ្រួសារ ហេតុនេះពេលដែលគាត់ជាប់ពន្ធនាគារគ្រួសាររបស់គាត់អស់ទីពឹង ហើយកូនរបស់គាត់អាចខូចអនាគតធ្វើឱ្យបាត់បង់នូវធនធានមនុស្សសម្រាប់សង្គមផងដែរ ។

ចំណែកឯទោសបន្ថែមវិញ ក៏ជាយន្តការមួយដ៏ល្អផងដែរ នៅក្នុងការដាក់ទោសទៅលើទណ្ឌិតពីព្រោះវាជាស្ពានទម្ងន់មួយបន្ថែមទៀតទៅលើមូលទោសនៅពេលដែលទណ្ឌិតអនុវត្តមូលទោសរួចហើយ ។ ការធ្វើបែបនេះនៅក្នុងគោលដៅឱ្យទណ្ឌិតមានការរៀងចាល និងបង្ការកុំឱ្យបទល្មើសដដែលនោះកើតឡើងម្តងទៀត ។ លើសពីនេះទៅទៀតនោះ ចំពោះទោសបន្ថែមអាចធ្វើការប្រកាសក៏បានមិនប្រកាស ក៏បានចំពោះរូបវន្តបុគ្គលវាអាស្រ័យទៅតាមឆន្ទានុសិទ្ធិរបស់ចៅក្រមប៉ុន្តែចំពោះនីតិបុគ្គលវិញត្រូវតែប្រកាស ។

ទោសជំនួសជាប្រភេទទោសមួយ ដែលជាសញ្ញាណថ្មី ។ ការបង្កើតនូវទណ្ឌកម្មថ្មីនេះមានចំណុចល្អនៅត្រង់ថា ទណ្ឌិតមិនចាំបាច់ទទួលរងនូវមូលទោសទេដោយគ្រាន់តែទទួលរងនូវការស្តីបន្ទោស និងផ្តល់ជាប្រយោជន៍ដល់សាធារណៈផងដែរតាមរយៈការទទួលរងនូវទោសការងារសហគមន៍ ។ ប៉ុន្តែការដាក់ទោសជំនួសនេះ គុណវិបត្តិរបស់វា ក៏ដូចទៅនឹងមូលទោសផងដែរ គឺវាមានលក្ខណៈស្រាល ដែលធ្វើឱ្យពលរដ្ឋមិនសូវខ្លាចរអា និងមិនរៀងចាល ហើយបទល្មើសទាំងនោះនៅតែកើតមានដដែល ។

បើយើងធ្វើការពិនិត្យទៅលើការប្រៀបធៀបរវាងប្រភេទទោសនៅក្នុងឆ្នាំទាំងពីរនេះ យើងសង្កេតឃើញថា មានចំណុចមួយចំនួនដែលដូចគ្នា និងខុសគ្នា ។ ចំណុចដូចគ្នានៃប្រភេទទោសទាំងពីរមានដូចជា៖ រូបភាពនៃប្រភេទទោស ទម្ងន់នៃប្រភេទទោស របៀបសម្គាល់នូវប្រភេទនៃទោសចំពោះបទល្មើស និងបុគ្គលដែលត្រូវទទួលរងនូវប្រភេទទោសជារូបវន្តបុគ្គល ។ ចំណែកឯចំណុចខុសគ្នានៃប្រភេទទោសទាំងពីរមានដូចជា៖ ការកំណត់ឈ្មោះនិងការបង្កើតថ្មីនៃប្រភេទទោស សណ្ឋាននៃប្រភេទទោសដែលលុបចេញពីក្រមចាស់ បុគ្គលដែលទទួលរងនូវប្រភេទទោសជានីតិបុគ្គល និងអាជ្ញាយុកាលនៃប្រភេទទោស ។

ការប្រៀបធៀបទៅលើប្រភេទទោសទាំងពីរមានចំណុចដូចគ្នា និងចំណុចខុសគ្នាច្រើន ។ បើទោះបីជាប្រភេទទោសទាំងពីរត្រូវបានចែងនៅក្នុងក្រមពីរផ្សេងគ្នា ហើយមានគម្លាតពីគ្នាដល់

ទៅមួយរយឆ្នាំក៏ដោយ ក៏មានចំណុចជាច្រើនដែលមានចែងនៅក្នុងក្រមចាស់បានបន្សល់ជាមូលដ្ឋានក្នុងការចែងនៅក្នុងក្រមថ្មីផងដែរ ។ មូលហេតុដែលមានចំណុចដូចគ្នាបែបនេះ គឺ ដោយសារតែក្រមទាំងពីរត្រូវបានបង្កើតឡើងនៅក្នុងគោលបំណងបង្ការ បង្ក្រាប និងដាក់ទណ្ឌកម្មទៅលើបុគ្គលដែលបានប្រព្រឹត្តបទល្មើសដែលប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ទ្រព្យសម្បត្តិ ក៏ដូចជាអាយុជីវិតរបស់មនុស្សផងដែរ ។ ចំណែកឯចំណុចខុសគ្នាវិញនោះ គឺដោយសារតែមានការវិវត្តនៃសង្គមដែលជាហេតុនាំឱ្យអំពើ ដែលបង្ករឱ្យមានភាពល្អក់កករដល់សង្គមក៏មានការប្រែប្រួលផងដែរ។ នៅពេលដែលមានការប្រែប្រួលនៃអំពើល្មើស នាំឱ្យមានការរិះរកនូវវិធានច្បាប់ថ្មីៗ ជាឧទាហរណ៍ដូចជានៅក្នុងក្រមព្រហ្មទណ្ឌថ្មីនេះមានការបង្កើតនូវទោសជំនួស ដែលជាសញ្ញាណថ្មីនៃវិធានច្បាប់ព្រហ្មទណ្ឌ និងការធ្វើការកែសម្រួលនូវវិធានច្បាប់ដែលមានស្រាប់ឱ្យសមស្របទៅតាមការប្រែប្រួលនោះផងដែរ ដូចជានៅក្នុងក្រមថ្មីមានការកំណត់នូវមូលទោស ដែលមានទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់ដែលមាននៅក្នុងក្រមចាស់ផងដែរ ប៉ុន្តែនៅក្នុងក្រមចាស់ពុំមានកំណត់ថាជាមូលទោសនោះទេ គឺ មានតែការដាក់គុក និងការពិន័យតែប៉ុណ្ណោះ ។

# អនុសាសន៍

ឆ្លងតាមការសិក្សាទៅលើការប្រៀបធៀបប្រភេទទោសព្រហ្មទណ្ឌ ដែលមាននៅក្នុងចែងនៅក្នុងក្រមព្រហ្មទណ្ឌខេមរៈឆ្នាំ ១៩០៩ និង ក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ យើងសង្កេតឃើញថាការប្រែលប្រួលនៃសង្គម បានជះឥទ្ធិពលទៅលើវិធានច្បាប់យ៉ាងខ្លាំង។ ហេតុនេះហើយនៅពេលដែលមានវិធានច្បាប់ព្រហ្មទណ្ឌជាធរមានហើយ ត្រូវធ្វើការអនុវត្តឱ្យបានប្រសើរ ព្រមទាំងត្រូវគិតពីការប្រែប្រួលនៃបទល្មើសដែលកើតមានថ្មីៗទៀត ។ តទៅនេះយើងសូមលើកឡើងនូវចំណុចពីរសំខាន់ដើម្បីធានាឱ្យការអនុវត្តច្បាប់ប្រកបដោយភាពរលូន ហើយចំណុចទាំងពីរនោះ គឺ **ទិសដៅអនុវត្ត** និង **ការបណ្តុះបណ្តាល និងការផ្សព្វផ្សាយ** ។

- **ទិសដៅអនុវត្តៈ**
  - ពង្រឹងការអនុវត្តច្បាប់ ដោយធានាឱ្យមានការចូលរួមពីប្រជាពលរដ្ឋអនុវត្តឱ្យជាអតិបរមា ហើយធ្វើការពិនិត្យរកឱ្យឃើញនូវចំណុចខ្វះខាត និងចំណុចមិនល្អ ដើម្បីកែសម្រួលសារជាថ្មី ។
  - ពិនិត្យទៅលើមូលទោសជាពិសេសការដាក់ពន្ធនាគារ ហើយព្យាយាមធ្វើយ៉ាងណាកាត់បន្ថយការអនុវត្តទោសដាក់ពន្ធនាគារ កុំឱ្យមានការអនុវទោសនេះលើសលុបពេក ដោយអនុវត្តនូវវិធានដែលជួយសម្រាលដល់ទណ្ឌិត ពីព្រោះការប្រព្រឹត្តបទល្មើសមិនមែនសុទ្ធតែកើតឡើងដោយចេតនាពេញទីរបស់ជនល្មើសនោះទេ ពេលខ្លះក៏វាបណ្តាលមកពីជនរងគ្រោះផងដែរ ។
  - ត្រូវពិនិត្យទៅលើទោសជំនួស ហើយយកវាមកអនុវត្តឱ្យបានច្រើន ពីព្រោះទោសនេះត្រូវបានបង្កើតឡើងក្នុងគោលបំណង ជំនួសឱ្យមូលទោសក្នុងករណីបំពេញទៅតាមលក្ខខណ្ឌ ប៉ុន្តែនៅក្នុងការអនុវជាក់ស្តែងមិនសូវឃើញមានការយកមកប្រកាស់លើទណ្ឌិតពីសំណាក់តុលាការនោះទេ ។ យើងមិនត្រូវបង្កើតតែបញ្ញត្តិច្បាប់ដោយគ្រាន់តែមាននៅក្នុងក្រមនោះ ត្រូវយកវាមកអនុវត្តធ្វើការសិក្សាទៅលើគុណសម្បត្តិ និងគុណវិបត្តិរបស់វា ដើម្បីងាយឱ្យយើងធ្វើការកែសម្រួលវានៅពេលអនាគត់ បើយើងមិនយកមកអនុវត្តទេ យើងមិនអាចសិក្សាស៊ីជម្រៅទៅលើវាបានទេ ។
- **ការបណ្តុះបណ្តាល និងការផ្សព្វផ្សាយ**

ដើម្បីធានាឱ្យមានការចូលរួមក្នុងការអនុវត្តទោសព្រហ្មទណ្ឌ ចាំបាច់ត្រូវតែមានការយល់ដឹងពីទោសព្រហ្មទណ្ឌពីសំណាក់ប្រជាពលរដ្ឋ ។ ដើម្បីឱ្យប្រជាពលរដ្ឋអាចយល់ដឹងនូវទោសនេះ

បាន យើងត្រូវចាត់វិធានការនៅក្នុងការផ្តល់នូវពត៌មាននេះ តាមរយៈការបណ្តុះបណ្តាល និងការផ្សព្វផ្សាយ ។

**១.ការបណ្តុះបណ្តាល** គឺជាចំណែកមួយយ៉ាងសំខានដែលចូលរួមនៅក្នុងការផ្តល់នូវចំណេះដឹងអំពីប្រភេទទោសព្រហ្មទណ្ឌនេះ ប្រសិនបើពុំមានការយល់ដឹងអំពីប្រភេទទោសព្រហ្មទណ្ឌ ការចូលរួមអនុវត្តក៏មិនមានភាពខ្លាំងក្លាដែរ។បុគ្គលដែលត្រូវទទួលការបណ្តុះបណ្តាលមានដូចខាងក្រោម៖

- **ចៅក្រម៖** ចៅក្រមជាអ្នកអនុវត្តច្បាប់ និងជាអ្នកកាត់សេចក្តីដែលធ្វើឡើងទៅតាមឆន្ទានុសិទ្ធិរបស់ខ្លួន ហេតុនេះហើយចៅក្រមត្រូវតែយល់ដឹងឱ្យច្បាស់លាស់ទៅលើប្រភេទទោស ដើម្បីជៀសវៀងការដាក់ទណ្ឌកម្មទៅលើបុគ្គលណាម្នាក់ផ្តល់វិបាក់ជាច្រើនដល់ក្រុមគ្រួសារបុគ្គលនោះ និងសង្គមជាតិទាំងមូល ។
- **មន្ត្រីសាធារណៈ៖** សំដៅទៅលើមន្ត្រីដែលមានសមត្ថកិច្ចនៅក្នុងការបង្រ្កាប់បទល្មើស ហេតុនេះហើយត្រូវតែមានការយល់ដឹងពីប្រភេទទោសព្រហ្មទណ្ឌដើម្បីអនុវត្តឱ្យបានល្អប្រសើរ ។

**២.ការផ្សព្វផ្សាយ** ជាផ្នែកមួយសំខាន់ដើម្បីបង្កើននូវប្រសិទ្ធិភាពដល់ការអប់រំបណ្តុះបណ្តាល។ ការផ្សព្វផ្សាយនូវចំណេះដឹងអំពីប្រភេទទោសព្រហ្មទណ្ឌទៅដល់ប្រជាពលរដ្ឋធម្មតា គឺវាមានសារៈសំខាន់ខ្លាំងណា ព្រោះយើងមិនអាចធ្វើការបណ្តុះបណ្តាលឱ្យដល់ព្រជាពលរដ្ឋគ្រប់គ្នា ហើយណាមួយពួកគាត់មិនមែនជាអ្នកអនុវត្តច្បាប់ទេ ហេតុនេះហើយមិនចាំបាច់ឱ្យពួកគាត់យល់ដឹងច្បាស់លាស់ស៊ីជម្រៅនោះទេ ។ យើងគ្រាន់តែបង្ករលក្ខណៈងាយស្រួលក្នុងការផ្សព្វផ្សាយ និងព្យាយាមធ្វើឱ្យវិសាលភាពទូទាំងប្រទេស ។

# ឯកសារយោង

- **លិខិតបទដ្ឋានគតិយុត្តថ្នាក់ជាតិ**
  - រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានប្រកាសឱ្យប្រើនៅ ថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ និងការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញនានា
  - ក្រមព្រហ្មទណ្ឌខេមរៈ ប្រកាសឱ្យប្រើនៅថ្ងៃទី ៨ ខែ មេសា ឆ្នាំ ១៩០៩
  - ព្រះរាជក្រម នស/រកម/១១០៩/០២២ ស្តីពីការប្រកាសឱ្យប្រើ ក្រមព្រហ្មទណ្ឌ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩ *(សូមអាន**រាជកិច្ច** ឆ្នាំទី ១០ លេខ ០១ ថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០១០ រហូតដល់**រាជកិច្ច** ឆ្នាំទី ១០ លេខ ០៤ ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១០)*
  - ព្រះរាជក្រម នស/រកម/០៤១០/០០៤ ស្តីពីការប្រកាសអោយប្រើ ច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ចុះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០១០ *(សូមអាន**រាជកិច្ច** ឆ្នាំទី ១០ លេខ ២៩ ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១០)*
- **លិខិតបទដ្ឋានគតិយុត្តថ្នាក់អន្តរជាតិ**
  - កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៦៦
  - សេចក្តីប្រកាស់ជាសកលស្តីពី សិទ្ធិមនុស្ស ចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៤៨
- **ឯកសារដែលបានចងក្រងជាសៀវភៅ និងការសិក្សាផ្សេងទៀតៈ**
  - ឯកឧត្តម សាស្ត្រាចារ្យ **បណ្ឌិត សាយ បូរី ៖** *វិធីសាស្ត្រនៃការបកស្រាយច្បាប់ព្រហ្មទណ្ឌ* ឆ្នាំ ២០១២-២០១៣
  - សៀវភៅនីតិរដ្ឋបាលទូទៅ របស់បណ្ឌិត សាយ បូរី ឆ្នាំ២០០៦ ទំព័រទី៤០៣
  - ឯកឧត្តមសាស្ត្រាចារ្យ **ហ៊ី សោភា** រដ្ឋលេខាធិការក្រសួងយុត្តិធម៌ ៖ *នីតិព្រហ្មទណ្ឌ*
  - លោកសាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** និង លោកស្រីសាស្ត្រាចារ្យ **ចាំង ស៊ីណាត** (ចៅក្រម រាជធានី) ៖ *នីតិព្រហ្មទណ្ឌទូទៅ*, ឆ្នាំ ២០១២
  - សទ្ទានុក្រមពាក្យច្បាប់ ផ្នែកក្រមព្រហ្មទណ្ឌ ទីស្តីការគណៈរដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១១
  - សទ្ទានុក្រមពាក្យច្បាប់ ផ្នែករដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណីទីស្តីការគណៈរដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧
  - វចនានុក្រម**សម្តេចព្រះសង្ឃរាជ ជួន ណាត** របស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ ២០០៩

- សន្ធានុក្រមនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០០៨
- ប្រសាសន៍របស់ **ឯកឧត្តម ហ៊ី សោភា** ប្រធានក្រុមការងារ ចូលរួមតាក់តែង និងការពារសេចក្តីព្រាងក្រមព្រហ្មទណ្ឌ សម័យប្រជុំរដ្ឋសភាលើកទី ៣ នីតិកាលទី ៤ របៀបវារៈទី ៣ សេចក្តីព្រាងច្បាប់ស្តីពីក្រមព្រហ្មទណ្ឌ ថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០០៩
- ប្រសាសន៍របស់ **ឯកឧត្តម ហ៊ី សោភា** នាកាលបង្រៀនដល់ អ្នករៀបរៀងស្តីពី "ក្រមព្រហ្មទណ្ឌ" នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច គិតចាប់ពីថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០១១ រហូតដល់ ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១
- ឯកសាររបស់ **ឯកឧត្តម ហ៊ី សោភា**រដ្ឋលេខាធិការលំដាប់ថ្នាក់ទីមួយនៃក្រសួងយុត្តិធម៌ ស្តីពីប្រភេទនៃទោស ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១០

❖ **ឯកសារសិក្ខាសាលា ព្រឹត្តិប័ត្រ និងសារព័ត៌មានផ្សេងៗ**

- ឯកសារសិក្ខាសាលាស្តីពី "ក្រមព្រហ្មទណ្ឌថ្មី" ផ្តល់បទបង្ហាញដល់សមាជិក-សមាជិកាព្រឹទ្ធសភា ដោយ **ឯកឧត្តមប្រធាន ហ៊ី សោភា** ចាប់ពីថ្ងៃទី ០២ ដល់ ២៥ ខែ សីហា ឆ្នាំ ២០១០
- ព្រឹត្តិប័ត្ររបស់ព្រឹទ្ធសភាស្តីពី "ការផ្សព្វផ្សាយក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា" ដោយ **ឯកឧត្តម ហ៊ី សោភា**
- ព្រឹត្តិប័ត្ររបស់រដ្ឋសភាស្តីពី "ការផ្សព្វផ្សាយក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា" ដោយ **ឯកឧត្តម ហ៊ី សោភា**
- ព្រឹត្តិប័ត្ររបស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ស្តីពី "ការផ្សព្វផ្សាយក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា"
- សារព័ត៌មានដើមអម្ពិល, កោះសន្តិភាព, រស្មីកម្ពុជា, កម្ពុជាថ្មី និង ភ្នំពេញប៉ុស្ដិ៍ ស្តីពីការផ្សព្វផ្សាយ "ក្រមព្រហ្មទណ្ឌ"

❖ **គេហទំព័រ**

- The Bar Association of the Kingdom of Cambodia :

  (http://www.bakc.org.kh/lawdocument.php)
- The Research and Promotion Khmer Laws Association :

(http://www.khmerlaws.com, http://www.khmerlaws.org,http://www.khmerlaws.info)

- Khmer Law Compilation, Office of the United Nations High Commissioner for Human Rights in Cambodia :

  (http://cambodia ohchr.org/klc pages/klc khmer.htm)

# សេចក្ដីផ្ដើម

# ជំពូកទី១

# ប្រភេទទោស ឆ្នាំ១៩០៩

# ជំពូកទី២

# ប្រភេទទោស ឆ្នាំ២០០៩

# ជំពូកទី៣

# ការប្រៀបធៀបប្រភេទ
# សោល

# សេចក្ដីសន្និដ្ឋាន

# អនុសាសន៍

# ឯកសារយោង

# ឧបសម្ព័ន្ធ